ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## “ ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល (SBM)នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ”

## IMPLEMENTTATION OF SCHOOL MANAGEMENT COMPARE TO SCHOOL BASED MANAGEMENT (SBM) STANDARDS BY HIGH SCHOOL PRINCIPALS IN SVAY CHRUM DISRICT, SVAY RIENG PROVINCE.


រស់ សារ៉ង

ROS SARONG


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## “ ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល (SBM)នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ”

## IMPLEMENTTATION OF SCHOOL MANAGEMENT COMPARE TO SCHOOL BASED MANAGEMENT (SBM) STANDARDS BY HIGH SCHOOL PRINCIPALS IN SVAY CHRUM DISRICT, SVAY RIENG PROVINCE.

**រស់ សារ៉ង**

ROS SARONG

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

# **លិខិតបញ្ជាក់**

**លោកស្រី ប៊ុន សុផានី** គ្រូដឹកនាំបង្គោល

**បណ្ឌិត ឈាង សង្វាត** គ្រូដឹកនាំរង

## **សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក *រស់ សារ៉េង* ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបាន សរសេរនិក្ខេបបទស្រាវជ្រាវ “ **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល** (SBM) **នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** ” ពិតប្រាកដមែន ។

ថ្ងៃ....................ខែ...........ឆ្នាំ.............ពុទ្ធសករាជ២៥៦៥

រាជធានីភ្នំពេញថ្ងៃទី........ខែ...............ឆ្នាំ២០២១

.......................................... ..................................................

**លោកស្រី ប៊ុន សុផានី** **បណ្ឌិត ឈាង សង្វាត**

នាយិការងវិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៣២០៥ **អយក.** [illegible]

(**ការសម្រាត់**)

## លិខិតឧទ្ទេសនាម

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៅ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ រ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ីងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ រដអ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ *រស់ សារ៉េង* ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២១ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ ។ ជាមួយលទ្ធផលដ៏ល្អនេះខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះការជួយជ្រោម ជ្រែងគាំទ្រនឹងយកចិត្តទុកដាក់ខ្ពស់ពីមជ្ឈដ្ឋាននានាជាច្រើន ។ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ៖

- លោកអ្នកមានគុណទាំងពីរគឺលោកឪពុក រស់ ស៊ាម និងអ្នកម្តាយ មោគ នារី ដែលបានផ្តល់កំណើត ផ្តល់ជំបូន្មាន អប់រំទូន្មាន ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងបានលះបង់កម្លាំងកាយចិត្តតស៊ូឧបត្ថម្ភផ្គត់ផ្គង់គាំ ទ្រទាំងសម្ភារៈ និងកម្លាំងចិត្តដល់កូនបានសិក្សារហូតជោគជ័យដូចសព្វថ្ងៃនេះ ។
- ឧត្តមភរិយា ជា សុវណ្ណនី ដែលបានផ្តល់ពេលវេលា ផ្តល់កម្លាំងចិត្តលើកទឹកចិត្ត ព្រមទាំងសន្សំសំចៃ ថវិកាផ្គត់ផ្គង់ដល់ការសិក្សារបស់ខ្ញុំជាស្វាមី ។
- បងប្រុសបងស្រី និងប្អូនៗបង្កើតទាំងប្រាំបួននាក់ ដែលតែងតែលើកទឹកចិត្ត និងផ្តល់ជាថវិកា និងជួយ គាំទ្រដល់ដំណើរការសិក្សាតាំងពីដំបូងរៀងមក ។
- ក្រសួងអប់រំ យុវជន និងកីឡា និង វិទ្យាស្ថានជាតិអប់រំ ដែលបានបង្កើតកម្មវិធីសិក្សានេះ និងបានផ្តល់ ឱកាសឲ្យរូបខ្ញុំបាទបានចូលមកសិក្សា និងទទួលការបណ្តុះបណ្តាលថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់នៅ វិទ្យាស្ថានជាតិអប់រំ ។
- គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថាន ជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ មក

បង្ហាត់ បង្រៀន និងពន្យល់គ្រប់មេរៀនដល់ខ្ញុំបាទព្រមទាំងនិស្សិតទាំងអស់ ដោយមិនគិតពីការលំបាកនឿយ ហត់ឡើយ ។

- លោកស្រី **ប៊ុន សុផានី** ជាសាស្ត្រាចារ្យដឹកនាំបង្គោល លោកបណ្ឌិត **ឈាង សង្វាត** ជាសាស្ត្រាចារ្យដឹក នាំរងដែលតែងតែចំណាយពេលវេលា ដ៏មានតម្លៃដើម្បីជួយពន្យល់ណែនាំ និងផ្តល់អនុសាសន៍ល្អៗ ដល់រូបខ្ញុំបាទតាំងពីការចាប់ផ្តើមធ្វើការស្រាវជ្រាវរហូតរៀងមក ទើបធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំ បាទទទួលបានលទ្ធផលជោគជ័យនៅពេលនេះ ។
- លោកគ្រូ អ្នកគ្រូដែលបានជួយបង្រៀនខ្ញុំបាទតាំងពីថ្នាក់បឋមសិក្សា មធ្យមសិក្សា មហាវិទ្យាល័យរហូតដល់បរិញ្ញាបត្រជាន់ខ្ពស់ ។
- មិត្តភក្តិទាំងអស់ ព្រមទាំងមិត្តរួមថ្នាក់ រួមជំនាន់ទី៨ទាំងអស់ ដែលតែងតែផ្តល់កម្លាំងចិត្ត ចែករំលែកឯកសារ ចំណេះដឹងនានាដល់រូបខ្ញុំបាទ ។
- លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៃសាលាគោលដៅទាំងអស់ដែលបានជួយបំពេញកម្រងសំណួរ របស់ខ្ញុំបាទ ។
- លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យ ហ៊ុនសែន ស្វាយជ្រំដែលបានជួយរៀបចំ និង ជួយសម្រួលកាលវិភាគសិក្សា ឲ្យមានភាពងាយស្រួលដល់ខ្ញុំបាទមានឪកាសបន្តការសិក្សា ។

ខ្ញុំបាទសូមប្រសិទ្ធពជ័យជូនចំពោះ លោកអ្នកមានគុណទាំងពីរ ភរិយាជាទីស្រឡាញ់ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី លោកគ្រូ អ្នកគ្រូទាំងអស់ ជួបប្រទះនូវពុទ្ធពរ បួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតចាកឡើយ ជាពិសេសជូនពរ ឲ្យរួចផុតពីជម្ងឺ កូវ៉ូណា(Covid 19)និងសម្រេចភារៈកិច្ចការងារគ្រប់ៗគ្នា ។

# មូលន័យសង្ខេប

ចំណេះដឹងជាអាហាររូបត្ថម្ភ ប្រចាំកាយក្នុងជីវិតរបស់បុគ្គលគ្រប់រូប បុគ្គលដែលមានចំណេះដឹងតិច ឬគ្មាន ចំណេះដឹង ប្រៀបបីដូចជារូបកាយដែលតែងតែជួបនូវបញ្ហាដែលញាំញីទៅដោយ រោគាច្រើនអណេក ពេញខ្លួនប្រាណ គឺទទួលការរងសំពាធន៍ ផ្លូវចិត្តផ្លូវកាយ ការប្រមាត្រាប់រយជំពូក មូលហេតុទាំងនេះហើយ ទើបបុគ្គលគ្រប់រូបតែង ប្រឹងប្រែងរៀនសូត្រ ស្វែងរកចំណេះដឹងតាមលទ្ធភាពដែលខ្លួនអាចទៅរួចរៀងៗខ្លួន ។ មានចំណេះដឹងល្អ នាំឲ្យ បុគ្គលគ្រប់រូបជោគជ័យ ឬឯមានភាពជាអ្នកដឹកនាំ និងគ្រប់គ្រងល្អធ្វើឲ្យគ្រប់អង្គភាព ទាំងអស់ទទួលបាននូវភាព  ជោគជ័យដូចគ្នា ។ ដូចគ្នាផងដែរនៅក្នុងវិស័យអប់រំការដឹកនាំ និងគ្រប់គ្រងល្អជា ផ្នែកមួយដ៏សំខាន់ដែលអាចធ្វើឲ្យ វិស័យអប់រំទូទាំងសាកលលោកមានការរីកច្រើន ។ ដោយឡែកនៅកម្ពុជា ក៏ ដូចគ្នាផងដែរ ការរីកចម្រើនក្នុងវិស័យអប់រំ ក៏ ទាមទារនូវភាពជាអ្នកដឹកនាំ និងគ្រប់គ្រងល្អ ជាសំខាន់ផងដែរ ។ ដោយចង់ឲ្យភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់ នាយកសាលារៀននៅកម្ពុជា និងចង់បង្កើតប្រសិទ្ធភាពនៃ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន ដើម្បីធ្វើឲ្យ ការអប់រំនៅកម្ពុជាកាន់តែមានគុណភាព  អ្នកស្រាវជ្រាវ បានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយមកសិក្សាស្រាវជ្រាវ គឺ  ៖ «ការអនុវត្តការគ្រប់គ្រងរបស់នាយក សាលា នៅមធ្យមសិក្សាទុតិយភូមិធៀបទៅ នឹងការដឹកនាំ   និងគ្រប់គ្រងផ្អែកលើលទ្ធផល ( SBM) ក្នុងស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង » យកមកសិក្សា  ។

ការសិក្សាស្រាវជ្រាវនេះ  នឹងប្រព្រឹត្តទៅនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀងដោយជ្រើសរើសយកវិទ្យាល័ យ ចំនួន ០៣ ក្នុងចំណោមវិទ្យាល័យដែលមានក្នុងស្រុក ហើយជាសាលារៀនមិនស្ថិតក្នុងគំរោងរបស់ SEIP ។ អ្នកស្រាវជ្រាវ បានសម្រេចជ្រើសរើសយកតែលោកគ្រូ អ្នកគ្រូ  និងគណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះដើម្បីចូល រួមវាយតម្លៃកម្រិត សកម្មភាពអនុវត្ត ការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ដោយអ្នកស្រាវជ្រាវមិនបាន ជ្រើសរើសសិស្សយក មកជួយវាយតម្លៃនាយកទេ ។ អ្នកស្រាវជ្រាវបានជ្រើសរើសយកលោកគ្រូ អ្នកគ្រូដែល បង្រៀននៅវិទ្យាល័យតែ ប៉ុណ្ណោះ ដែលបង្រៀននៅថ្នាក់ទី ១០ ទី ១១ និង ទី ១២  សរុបមាន ៥៥ នាក់ និង

គណៈគ្រប់គ្រងជានាយក ០៣ នាក់  នាយករងផ្នែកបច្ចេកទេស ០៣ នាក់ និងបុគ្គលិករដ្ឋបាលចំនួន ០៤ នាក់ សរុប មាន៦៥ នាក់ ដើម្បី ជួយបំពេញកម្រងសំណួរ ។ ដោយឡែកកម្រងសំណួរ អ្នកស្រាវជ្រាវបានបែងចែកជាបី ផ្នែក ដែលផ្នែកទី១ អ្នកស្រាវជ្រាវចង់ដឹងពីព័ត៌មានផ្ទាល់ខ្លួនរបស់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលារៀនទាំងនាយក នាយករង និង បុគ្គលិករដ្ឋបាល ផ្នែកទី ២ អ្នកស្រាវជ្រាវចង់ដឹងពីការវាយតម្លៃរបស់ គ្រូបង្រៀនលើសកម្មភាពនៃការអនុវត្ត ការងារដឹកនាំ និងគ្រប់គ្រង របស់នាយកសាលា និងការវាយតម្លៃរបស់គណៈគ្រប់គ្រងសាលា លើការអនុវត្តការងារ ដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា  និងផ្នែកទី៣ និយាយពីបញ្ហាប្រឈមនានាដែលនាយកសាលាជួប ប្រទះក្នុងដំណើរកាដឹកនាំ និង គ្រប់គ្រងសាលារៀន។ ការវាយតម្លៃការអនុវត្តនេះអ្នកស្រាវជ្រាវផ្តោតលើគោលគំនិត នៃការដឹកនាំ និងគ្រប់គ្រង ៤ យ៉ាង សំខាន់គឺ ១ ) ការគ្រប់គ្រងការបង្រៀន និងរៀន  ២ )ការគ្រប់គ្រងរដ្ឋបាល  ៣)ការគ្រប់គ្រងថវិកាសាលារៀន និង ៤) ការគ្រប់គ្រងធនធានមនុស្ស ។ បន្ទាប់មកអ្នកស្រាវជ្រាវបានយកចម្លើយ ដែលបានមកពីកម្រងសំណួរទាំងនោះយកមកវិភាគតាមកម្មវិធី Excel គណនារកតម្លៃ Mean សម្រាប់សិក្សាប្រៀប ធៀបពីកម្រិតនៃការអនុវត្តការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា ធៀបជាមួយការដឹកនាំ និងគ្រប់គ្រងផ្អែកលើ លទ្ធផល (SBM)នៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដោប្រើវិធីសាស្ត្របែបបរិមាណវិស័យ ។

តាមលទ្ធផលនៃការវិភាគបានបង្ហាញថាការអនុវត្តការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលានៅមធ្យម សិក្សាទុតយភូមិ ក្នុងស្រុកស្វាយជ្រំ លើ ៤ ចំណុចខាងលើរួមមាន ១) ការគ្រប់គ្រងការបង្រៀន និងរៀន ២) ការ គ្រប់គ្រងរដ្ឋបាលសាលារៀន  ៣) ការគ្រប់គ្រងថវិកា និង ៤)ការគ្រប់គ្រងធនធានមនុស្ស  គឺនាយកសាលាអនុវត្ត  បានកម្រិតល្អបើធៀបជាមួយ ការដឹកនាំ និងគ្រប់គ្រងដោយផ្អែកលើលទ្ធផល (SMB) ។  ទន្ទឹមនឹងការអនុវត្តការ ដឹកនាំ និងគ្រប់គ្រងបានល្អនេះ អ្នកស្រាវជ្រាវបានរកឃើញបញ្ហាប្រឈមមួយចំនួនរបស់នាយកសាលាដែលជា ហេតុបង្កជាឧបសគ្គដល់ការអនុវត្តការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាគឺ គ្រូបង្រៀនមួយចំនួនបង្រៀនមិនទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ ,គ្រូបង្រៀនមិនទាន់មានកិច្ចតែងការគ្រប់មុខវិជ្ជា

ចំនួនសិស្សអវត្តមាន និងបោះបង់ច្រើន  សហគមន៍មិនបានចូលរួមក្នុងដំណើរការដឹកនាំ និងគ្រប់គ្រងសាលារៀនបានល្អ  ជាពីសេសចំណូលថវិកាប្រចាំឆ្នាំ មានចំនួនតិចបើធៀបជាមួយចំណាយរបស់សាលារៀន ក្នុងមួយឆ្នាំ ។

ដូចនេះ ផ្អែកលើលទ្ធផលនៃការស្រាវជ្រាវនេះ នាយកសាលារៀនត្រូវពង្រឹងការអនុវត្តការងារ គ្រប់គ្រងបន្ថែមទៀតឲ្យរិតតែមានប្រសិទ្ធភាព  ជាពិសេសគឺការគ្រប់គ្រងរដ្ឋបាល   ជាមូលហេតុធ្វើឲ្យដំណើរ ការនៃការគ្រប់គ្រង របស់នាយកកាន់តែមានប្រសិទ្ធភាព និងទទួលបានបរសិទ្ធផលល្អ ការនេះជាមូលហេតុធ្វើឲ្យការអប់រំនៅកម្ពុជាកាន់តែទទួលបានលទ្ធផលល្អ សិស្សានុសិស្សនៅកម្ពុជាប្រកបដោយចំណេះជំនាញ  ច្បាស់លាស់សមជាធនធាននៃការប្រកួតប្រជែងសម័យកាលនៃការរីកចម្រើនបដិវត្តឧស្សាហកម្មថ្មី ៤.០ នេះ  ។

# មាតិកា


**លិខិតបញ្ជាក់** ...... i

**សេចក្តីថ្លែងអំណរគុណ** ...... iv

**មូលន័យសង្ខេប** ...... vi

**ជំពូកទី១** ...... 1

**សេចក្តីផ្តើម** ...... 1

១.១ សាវតា ...... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ...... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ...... 4

១.៤ សំណួរនៃការស្រាវជ្រាវ ...... 5

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ...... 5

១.៦ ដែនកំណត់នៃការស្រាវជ្រាវ ...... 6

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... 7

**ជំពូក២** ...... 10

**រំឭកទ្រឹស្តី** ...... 10

២.១ និយមន័យ ...... 10

២.១.១ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ...... 12

២..២ ស្ថានភាពសាលារៀនមធ្យមសិក្សានៅខេត្តស្វាយរៀង ...... 13

២.៣ ដំណើរការនៃការដឹកនាំនិងគ្រប់គ្រង ...... 14

២.៤ ការអនុវត្តន៍ការងារគ្រប់គ្រង ( SBM ) ...... 15

២.៥ ដំណើរការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា ...... 17

២.៦ ការគ្រប់គ្រងការបង្រៀននិងរៀន ...... 18

២.៧ ការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន ...... 19

២.៨ ការគ្រប់គ្រងថវិកាសាលារៀន ........ 22

២.៨.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងថវិកាសាលារៀន ........ 23

២.៩ ការគ្រប់គ្រងធនធានមនុស្ស ........ 24

២.១០ ការពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ........ 25

២.១១ ប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រង បុគ្គលិក ........ 25

**ជំពូកទី៣** ........ 28

**វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ 28

៣.១ ពត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ........ 28

៣.២ ទីកន្លែងត្រូវស្រាវជ្រាវ ........ 28

៣.៣ ក្រុមគោលដៅស្រាវជ្រាវ ........ 29

៣.៤ ទំហំសំណាក ........ 30

៣.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 31

៣.៦ ការជ្រើសរើសសំណាក ........ 31

៣.៧ ឧបករណ៍ស្រាវជ្រាវ ........ 31

៣.៨ ការប្រមូលពត៌មាន ........ 35

៣.៩ ការវិភាគទិន្នន័យ ........ 35

៣.១០ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 36

៣.១១ ព្រំដែននៃការស្រាវជ្រាវ ........ 36

**ជំពូកទី៤** ........ 39

**លទ្ធផល និងការពិភាក្សា** ........ 39

៤.១ ការកំណត់កម្រិតនៃការវាយតម្លៃ ........ 39

៤.២ សំណួរស្រាវជ្រាវទី១ ការចង្អុលបង្ហាញរបស់គ្រូ និងគណៈគ្រប់គ្រង ........ 40

៤.២.៦ ការពិភាក្សាលើកម្រងសំណួរទី១ ........ 51

៤.៣ បញ្ហាប្រឈមក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនរបស់នាយកសាលា ........ 59
៤.៣.១ សំណួរស្រាវជ្រាវទី២ បញ្ហាប្រឈម ........ 60
៤.៣.២ ការពិភាក្សាលើកម្រងសំណួរទី២ ........ 62
**ជំពូកទី៥** ........ 65
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 65
៥.១ សេចក្តីសន្និដ្ឋាន ........ 65
៥.២ សំណូមពរ ........ 67
ក្រសួងអប់រំ យុវជន និងកីឡា ........ 67
មន្ទីរអប់រំ យុវជន នងកីឡា ខេត្ត និង ការិយាល័យអប់រំ យុវជន និង កីឡាស្រុក ........ 67
សាលារៀន ........ 68
សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត ........ 68
ឯកសារយោង ........ 69
ក្រសួងអប់រំយុជន និង កីឡា(២០១៩), ឯកសារស្តីពី យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ ........ 69
២០១៨ -២០២៣.រាជធានីភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា ។ ........ 69
ឧបសម្ព័ន្ធ ........ 71
កម្រងសំណួរស្ទាយជ្រាវសម្រាប់គ្រូ ........ 71
ផ្នែកទី១៖ ពត៌មានទូទៅ ........ 71
ផ្នែកទី២ ៖ ការបំពេញការងារនិងការគ្រប់គ្រងដឹកនាំរបស់នាយកសាលារៀន ........ 72
មតិយោបល់បន្ថែម៖ ........ 75
ផ្នែកទី៣៖បញ្ហាប្រឈមរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ ........ 76
មតិយោបល់បន្ថែម៖ ........ 77
កម្រងសំណួរស្រាវជ្រាវសម្រាប់គណៈគ្រប់គ្រងសាលា ........ 78

ផ្នែកទី១៖ ព័ត៌មានទូទៅ ........................................................................................................... 78
ផ្នែកទី២ ៖ ការបំពេញការងារនិងការគ្រប់គ្រងដឹកនាំរបស់នាយកសាលារៀន .................................. 79
មតិយោបល់បន្ថែម៖ ......................................................................................................................... 82
ផ្នែកទី៣៖បញ្ហាប្រឈមរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ..................... 82
មតិយោបល់បន្ថែម៖ ......................................................................................................................... 84
ព័ត៌មានទូទៅរបស់គ្រូបង្រៀន នៅមធ្យមសិក្សាទុតយភូមិ............................................................. 84
ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង នៅមធ្យសិក្សាទុតយភូមិ ......................................................... 85

# បញ្ជីតារាង

តារាង ៣.៣.១ ក្រុមគោលដៅ និងអ្នកចូលរួម........................................................................30

តារាង ៤.២.១ ការគ្រប់គ្រងការបង្រៀននិងរៀន....................................................................40

តារាង ៤.២.២ ការគ្រប់គ្រងរដ្ឋបាលសាលារៀន..................................................................43

តារាង ៤.២.៣ ការគ្រប់គ្រងហិរញ្ញវត្ថុ.......................................................................................45

តារាង ៤.២.៤ ការគ្រប់គ្រងធនធានមនុស្ស............................................................................47

តារាង ៤.២.៥ មធ្យមភាគរួមសរុបគ្រូបង្រៀន និងគណៈគ្រប់គ្រង......................................................49

តារាង ៤.២.៦លទ្ធផលមធ្យមភាគរួមសរុបគ្រូ និងគណៈគ្រប់គ្រង ......................................................56

តារាង៤.៣.១បញ្ហាប្រឈមរបស់នាយកសាលារៀន..............................................................60

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ សាវតា

ការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន មានការអភិវឌ្ឍលូតលាស់យ៉ាងឆាប់រហ័ស ។ ការរីកចម្រើនទាំងនេះមានល្បឿនលឿនប្រៀបបីដូចជាផ្លេកបន្ទោ រហូតដល់មានមនុស្សមួយចំនួនភ្លេចទាំងចាប់អារម្មណ៍ ផងដែរ ។ មានបុគ្គលមួយចំនួន ស្ទើរតែមិនជឿថា រឿងខ្លះអាចកើតមានឡើងទៅបាន ដែលស្ទើរតែមិនគួរឲ្យជឿ ។ ជាការពិតបើតាមការសង្កេតជាក់ស្តែងយើងរំពៃឃើញថាបុគ្គលមួយចំនួន ធំបាននឹងកំពុងញាប់ ដៃញាប់ជើងព្យាយាមសិក្សា ចង់ដឹងចង់ស្វែងយល់ពីការរីកចម្រើននៃការប្រើប្រាស់បច្ចេកវិទ្យា ក្នុងជីវភាពដែលខ្លួន បានជួបប្រទះនាពេលបច្ចុប្បន្ននេះ ទាំងការងារ និងការរកទទួលទានប្រចាំថ្ងៃ ។ ប៉ុន្តែគេក៏សង្កេតឃើញថា មានបុគ្គលមួយចំនួនតូច គឺនៅតែដេកលង់លក់ មិនព្រមភ្ញាក់រលឹក មិនព្រមរៀនសូត្រសិក្សាស្រាវជ្រាវ និងមិនអើពើចំពោះការរីកចម្រើននៃបច្ចេកវិទ្យាទាំងនេះទៅវិញ តែក៏មានបុគ្គលមួយចំនួនគាត់ មានបំណងចង់ចេះចង់ដឹងដូចគ្នា តែអាស្រ័យដោយហេតុផលផ្សេងៗ ជាឧបសគ្គសម្រាប់ពួកគាត់ដូចជា កត្តាវ័យជ្រៀលជ្រេ កត្តាកម្រិតជីវភាពក្រីក្រលំបាកខ្វះលទ្ធភាព កត្តាតំបន់ភូមិសាស្ត្រជនបទដាច់ស្រយ៉ាលជាដើម ក៏ជាដើមហេតុក្នុងការផ្តល់ផលលំបាកមួយដល់ពួកគាត់ ពិបាកក្នុងការសិក្សាស្វែងយល់ពីបច្ចេកវិទ្យា ឲ្យបានល្អ ប្រសើរបើធៀបជាមួយបុគ្គលផ្សេងៗទៀត ។ តែទោះជាយ៉ាងណាក្តី ការរីកចម្រើននៃពិភពលោកបានបន្ត ធ្វើ ដំណើរ ទៅមុខជានិច្ច មិនរង់ចាំអ្នកខ្វះលទ្ធភាពឡើយ ដាក់ស្តែងនាពេលបច្ចុប្បន្នភាពនេះពិភពលោកបានឈានដល់**សម័យបដិវត្តឧស្សាហកម្មថ្មី ៤.០** ។ គ្រប់ប្រទេស ទាំងអស់លើពិភពលោកបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការពង្រឹងការក៏សាងធនធានមនុស្ស ឲ្យក្លាយជាមនុស្ស ពោរពេញទៅដោយសមត្ថភាព ក្នុងគោលបំណងជម្រុញការក៏សាងប្រទេសរបស់ខ្លួន ឲ្យស្របតាមការរីកចម្រើន នៃពិភពលោកនាពេលបច្ចុប្បន្ននេះ ។ ដូចគ្នាផងដែរ ប្រទេសកម្ពុជាដែលមាន**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខនៃរាជរដ្ឋាភិបាល លោកមាន ចក្ខុវិស័យដឹកនាំប្រទេសវែងឆ្ងាយដោយមាន បំណងចង់ប្រែក្លាយកម្ពុជាប្រទេស ឲ្យមានការរីកចម្រើន

អភិវឌ្ឍន៍ ជឿនលឿនដូចប្រទេសអភិវឌ្ឍន៍នានានៅក្នុងតំបន់ និងប្រទេសមហាអំណាចទាំងឡាយនៅក្នុងពិភពលោកផងដែរ ។ ដើម្បីសម្រេចមហិច្ឆតានេះរដ្ឋាភិបាលបានរៀប ចំគោលនយោបាយ និងកំណត់ចក្ខុវិស័យជាច្រើន ។ ជាការពិតនាពេលថ្មីៗនេះរដ្ឋាភិបាលបានកំណត់ទិសដៅប្រែក្លាយកម្ពុជារដ្ឋជាប្រទេសមានចំណូលជាមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ ដោយរដ្ឋាភិបាលខិតខំ ប្រឹងប្រែងបង្កើនកំណើតសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំៗ ។ កំណើនសេដ្ឋកិច្ចគឺមានទំនាក់ទំនងយ៉ាងជិត ស្និទជាមួយវិស័យអប់រំ ស្របពេលដែលមានប្រទេសជាច្រើន ពិសេសគឺប្រទេសអភិវឌ្ឍន៍ គឺបាននឹងកំពុងយកចិត្តទុកដាក់វិនិយោគលើវិស័យអប់រំ ពី៥% ទៅ ៦% នៃចំណូលជាតិសរុប របស់ប្រទេស ។ ដោយឡែករាជរដ្ឋាភិបាលកម្ពុជាក៏ នាពេលបច្ចុប្បន្នក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការពង្រឹង និងបង្កើនគុណភាពប្រសិទ្ធភាពគ្រប់វិស័យ ជាពិសេសគឺផ្តល់អទិភាពលើវិស័យពីរសំខាន់គឺ វិស័យអប់រំ និងវិស័យសុខាភិបាល ជាទឡ្ហីករណ៍នៅក្នុងអាណត្តិទី ៦នេះរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ គឺ ផ្តោតទៅលើការអភិវឌ្ឍធនធានមនុស្សជាអទិភាពទី១ (**យុទ្ធសាស្រ្តកំណែទម្រង់ វិស័យអប់រំ យុវជន និង កីឡា ២០១៦-២០២៣ ឯកឧត្តម ហង់ ជួន ណារ៉ុន** )។

ក្រសួងអប់រំយុវជននិងកីឡានៃប្រទេសកម្ពុជាដែលមានឯកឧត្តម**បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** ជារដ្ឋមន្ត្រី លោកបានដង្ហែរនិងគាំទ្រតាមគោលនយោបាយរបស់រដ្ឋាភិបាល ។ លោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្កើនយុទ្ធសាស្ត្រ និងគោលនយោបាយជាច្រើនក្នុងនោះរួមមានទាំង ការធ្វើកំណែទម្រង់១៥ ចំណុចលើវិស័យអប់រំចាប់តាំងពីឆ្នាំ ២០១៤ មកដើម្បីធ្វើឲ្យវិស័យអប់រំនៅកម្ពុជាប្រកបដោយប្រសិទ្ធភាព បរិយាបន្ន សមធម៌ និងធនធានមនុស្សក្លាយជាមនុស្សពេញលេញ ។ កំណែទម្រង់ទាំង ១៥ ចំណុចរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមានៈ ១) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំ ២) ការពង្រាយគ្រូបង្រៀន ៣) កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ៤)លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៥) ការងារអធិការកិច្ច ៦)ការវាយតម្លៃលទ្ធផលសិក្សា ៧)កំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ ៨)

កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ៩) ការសាងសង់អគារសិក្សា និងការជួសជុល ១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ១១)ការលើកកម្ពស់វិស័យកីឡា ១២)ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន ។ ១៣)ការអប់រំបច្ចេកទេស ១៤) ការបង្កើនសាលារៀនជំនាន់ថ្មី ១៥)ការរៀបចំគន្លងអាជីពគ្រូបង្រៀន និងបណ្តុះបណ្តាលនាយកសាលា ។ **(បទបង្ហាញរបស់ឯកឧត្តមបណ្ឌិតសភាចារ ហង់ ជួនណារ៉ុន ២០១៥ )** ក្នុងចំណោមការដាក់ចេញនូវ យុទ្ធសាស្ត្រ និងគោលនយោបាយជាច្រើនរបស់ឯកឧត្តមរដ្ឋមន្ត្រីក៏ដូចជាក្រសួងអប់រំ ក្នុងនោះមានគោលនយោបាយសំខាន់មួយ ដែលជាអទិភាពក្នុងការពង្រឹងគុណភាពអប់រំនៅកម្ពុជាគឺ "**ការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលាដោយផ្អែកលើលទ្ធផល** ( SBM= School based Management )" **។ ( យុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ )**

ដោយមើលឃើញពីសារៈសំខាន់នៃគោលនយោបាយនេះ ទើបអ្នកស្រាវជ្រាវបានសម្រេចចិត្តបង្កើតប្រធានបទស្រាវជ្រាវមួយមកសិក្សាស៊ីជម្រៅបន្ថែមនោះគឺ " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល( SBM ) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង " ។** ដែលជាប្រធានបទថ្មីមិនទាន់មាននិស្សិត ឬអ្នកសិក្សាណាធ្វើការស្រាវជ្រាវនៅឡើយ ។

### ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់គ្រប់ប្រទេសទាំងអស់នៅលើសកលលោក ត្រូវការប្រព័ន្ធអប់រំជាចាំបាច់ដើម្បី ផលិតនូវធនធានមនុស្សពេញលេញយកមកអភិវឌ្ឍន៍ប្រទេសជាតិ របស់ប្រទេសពួកគេរៀងៗខ្លួន ។ ការបង្កើតធនធានមនុស្សប្រកបដោយគុណភាព ប្រសិទ្ធភាព និងក្រមសីលធ៌ម គេត្រូវពឹងផ្អែកយ៉ាងសំខាន់លើវិស័យអប់រំនេះឯង ។ ការអប់រំជាបញ្ហាសំខាន់ដែលជាមូលហេតុផ្តល់ផលចំណេញជាផ្លែផ្កា ដល់បុគ្គលគ្រប់រូប និងសង្គម ជាតិទាំងមូល សមស្របនឹងទ្រឹស្តីមួយលើកឡើងថា " **ការអប់រំគឺជាអាវុធដ៏មានអំណាចបំផុត ដែលអ្នកអាចប្រើប្រាស់ដើម្បីផ្លាស់ប្តូរពិភពលោក** " ( Nelson Mandela ) ។ ដូចគ្នាផងដែរដើម្បីធ្វើឲ្យប្រព័ន្ធអប់រំនៅកម្ពុជាមាន ការរីកចម្រើនប្រកបដោយគុណភាព និងមានប្រសិទ្ធភាពតម្រូវទាមទារឲ្យមានការចូលរួមយ៉ាងសំខាន់ពី

គ្រប់ភាគីដែលពាក់ព័ន្ធ ទាំងឡាយរួមមាន អ្នករៀបចំគោលនយោបាយអប់រំ អ្នកបច្ចេកទេសអប់រំ ការរៀបចំកម្មវិធីសិក្សា វិស័យសេដ្ឋកិច្ច នយោបាយ និងការអនុវត្តការគ្រប់គ្រងការអប់រំជាដើម ។ ការគ្រប់គ្រងការអប់រំប្រកដោយប្រសិទ្ធភាព និងប្រសិទ្ធផល គឺជាមូលហេតុចម្បងសំខាន់មួយដែលមិនអាចខ្វះបានដើម្បីបង្កើនប្រសិទ្ធភាពក្នុងវិស័យអប់រំ ជាពិសេសបរិបទនៃប្រទេសកម្ពុជា នេះឯង ។

ការគ្រប់គ្រងការងារអប់រំប្រកបដោយប្រសិទ្ធភាព និង ប្រសិទ្ធផលនៅតែជាបញ្ហារសើបនៅក្នុងបរិបទនៃកម្ពុជា ជាក់ស្តែងគឺការអនុវត្តការងារគ្រប់គ្រង របស់ថ្នាក់មូលដ្ឋាន រួមមានការអនុវត្តការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលារៀននេះតែម្តង ដោយផ្តោតលើការគ្រប់គ្រងនិងដឹកនាំបួនចំណុចសំខាន់គឺៈ១) ការគ្រប់គ្រង ការបង្រៀន និងរៀន ២) ការគ្រប់គ្រងរដ្ឋបាល សាលារៀន ៣)ការគ្រប់គ្រងថវិកាសាលារៀន និង ៤) ការគ្រប់គ្រងធនធានមនុស្ស **(ការដឹកនាំ និងគ្រប់គ្រងដោយផ្អែកលើលទ្ធផល SBM)** ។ ដោយចង់ប្រៀបធៀប ពីកម្រិតនៃភាពខុសគ្នាលើដំណើរការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលារៀន ជាមួយនឹងការដឹកនាំនិងគ្រប់គ្រងដោយផ្អែកលើលទ្ធផល (SBM) ទើបខ្ញុំបាទជា អ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសប្រធានបទ " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែក លើលទ្ធផល (SMB) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " យកមកសិក្សាពីកម្រឹតភាពខុសគ្នា ដើម្បីធ្វើជាពន្លឺនៃការពង្រឹងគុណភាពនៃការគ្រប់គ្រងនិងដឹកនាំ របស់នាយកសាលារៀន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធផល ដែលជាមាគ៌ាធ្វើឲ្យវិស័យអប់រំនៅ កម្ពុជាមានការរីកចម្រើនកាន់តែប្រសើរបន្ថែមទៀត អាចប្រកួតប្រជែងជាមួយប្រទេសនានាក្នុងតំបន់ ក៏ដូចជា សកលលោកទាំងមូលផងដែរ ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងពីរសំខាន់ដូចខាងក្រោមៈ

១)សិក្សាស្វែងយល់ពីដំណើរការការអនុវត្តការគ្រប់គ្រងសាលារៀនតធៀបជាមួយស្តង់ដាការគ្រប់គ្រងសាលារៀន ដោយផ្អែកលើលទ្ធផល (SBM) ក្នុងបរិបទនៃស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

២) សិក្សាស្វែងយល់ពីបញ្ហាប្រឈម នៃការដឹកនាំ និងគ្រប់គ្រង របស់នាយកសាលាមធ្យមសិក្សាទុតិយភូមិក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

### ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការសិក្សាលើប្រធានបទខាងលើនេះ កាន់តែទទួលបានលទ្ធផលស្រាវជ្រាវល្អ អ្នកស្រាវជ្រាវបានរិះរក និងបង្កើតសំណួរស្រាវជ្រាវ ឲ្យសាកសមជាមួយប្រធានបទនេះ ។ អ្នកស្រាវជ្រាវបាន សម្រិតសម្រាំងសម្រេច ចិត្តជ្រើសរើសយកសំណួរពីរសំខាន់យកមកដាក់ជាបញ្ហាក្នុងប្រធានបទស្រាវជ្រាវនេះ ។ សំណួរស្រាវជ្រាវទាំងពីរដែលត្រូវលើកយកមកសិក្សាឲ្យស្របតាមប្រធានបទខាងលើគឺ៖

១) តើការបំពេញការងារដឹកនាំនិងគ្រប់គ្រង ឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) មាន ប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ?

២) តើការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មានជួបបញ្ហាប្រឈមអ្វីខ្លះ?

### ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ជាទូទៅគេសង្កេតឃើញថា គ្រប់បញ្ហាដែលកើតមានឡើងតែងតែមានដំណោះស្រាយ រីឯដំណោះស្រាយខ្លះមានប្រសិទ្ធភាពល្អ ប៉ុន្តែដំណោះស្រាយមួយចំនួនក៏ទទួលបានបរាជ័យដែរ ។ គេមើលឃើញថា ការដោះស្រាយបញ្ហាបានជោគជ័យគឺផ្តើមចេញពី ការទទួលយក និងអនុវត្តតាមបទពិសោធន៍ដែលគេធ្លាប់ជួបប្រទះកន្លងមក ដែលបទពិសោធន៍ទាំងនោះត្រូវបានរៀបចំឬចងក្រងជាឯកសារ ខ្លឹមសារជាសៀវភៅនានាដែលកើតចេញពីការសិក្សាស្រាវជ្រាវត្រឹមត្រូវច្បាស់លាស់ និងមានលក្ខណៈវិទ្យាសាស្ត្រ ។ ទាំងនេះបានបញ្ជាក់ថា ការសិក្សាស្រាវជ្រាវទាំងអស់សុទ្ធតែមានសារៈសំខាន់បំផុតដែលអ្នកសិក្សាទាំងអស់ ត្រូវតែបង្កើនការស្រាវជ្រាវបែបវិទ្យាសាស្ត្រឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។

ដូចគ្នាផងដែរអ្នកសិក្សាស្រាវជ្រាវលើប្រធានបទ៉ ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលា ធៀបទៅនឹងការដឹកនាំនិងគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM)៉ គឺមានជំនឿជាក់ថាប្រធាន បទខាងលើនេះ គឺនឹងផ្តល់សារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការពង្រឹងការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលារៀននៅ

មធ្យមសិក្សាទុតិយភូមិ ឲ្យកាន់តែមានប្រសិទ្ធភាព បន្ថែមទៀតលើ ការដឹកនាំ និងគ្រប់គ្រងការបង្រៀននិងរៀន ការងាររដ្ឋបាល ការប្រើប្រាស់ថវិកាសាលារៀន និងការគ្រប់គ្រងធនធានមនុស្សក្នុងសាលារៀន ។ ការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលារៀន បានល្អគឺជាបច្ច័យ មួយធ្វើឲ្យវិស័យអប់រំនៅកម្ពុជាកាន់តែមានប្រសិទ្ធភាព និងគុណភាព ដែលជាហេតុបង្កឱកាសក្នុងកាបង្កើត ធនធានមនុស្សកាន់តែសម្បូរបែប ប្រកប ដោយសក្តានុពល និងជាមនុស្សពេញលេញ ។ ការស្រាវជ្រាវនេះក៏ បានជួយជម្រុញបន្ថែមនូវកំណែទម្រង់ ១៥ ចំណុចរបស់ក្រសួងអប់រំផងដែរ ។ មួយវិញទៀតឯកសារថ្មីនេះជាពន្លឺ សម្រាប់បងប្អូននិស្សិត ឬអ្នកសិក្សាជំនាន់ក្រោយៗទៀត ក្នុងការបន្តការស្រាវជ្រាវនានាដែលពាក់ព័ន្ធ ទៅនឹងប្រធានបទខាងលើនេះ និងជាឯកសារជំនួយដ៏សំខាន់សម្រាប់អ្នកសិក្សា ដែលទាក់ទងទៅនឹងការដឹកនាំនិងគ្រប់គ្រងរបស់ នាយកសាលានៅក្នុងវិស័យអប់រំនៃកម្ពុជាទាំងមូល ។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការស្រាវជ្រាវមួយបានល្អគឺត្រូវទាមទារកត្តារួមផ្សំជាច្រើន ក្នុងនោះការកំណត់ពីដែនកំណត់ ឬ ទំហំវិសាលភាពស្រាវជ្រាវជាភាគផ្សំមួយយ៉ាងសំខាន់ ជាដើមចមដែលធ្វើឲ្យការសិក្សាស្រាវជ្រាវបានកាន់តែច្បាស់ និងទទួលយកបាន ។ ដូចនេះដើម្បីជៀសវាងការស្រាវជ្រាវដែលប្រាសចាកពីប្រធានបទ អ្នកស្រាវជ្រាវលើប្រធានបទ " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែក លើលទ្ធផល (SMB) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " ។ អ្នកស្រាវជ្រាវសូមធ្វើការកំណត់យកដែនកំណត់ត្រឹមតែ ដំណើរការដឹកនាំគ្រប់គ្រងរបស់នាយកសាលា ដោយប្រៀបធៀបជាមួយការដឹកនាំនិងគ្រប់គ្រងនាយកសាលាផ្អែកលើលទ្ធផល ដោយសិក្សាស្រាវជ្រាវលើដំណើរការ ៤ចំណុចសំខាន់ រួមមាន៖ ១)ការគ្រប់គ្រង ការបង្រៀន និងរៀន ២) ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣)ការគ្រប់គ្រងថវិកាសាលារៀន និង ៤)ការគ្រប់គ្រងធនធានមនុស្ស តែប៉ុណ្ណោះ ហើយធ្វើការជ្រើសរើសយកតែបីវិទ្យាល័យក្នុងចំណោមវិទ្យាល័យទាំង ៥ ដែលមាននៅក្នុងស្រុកស្វាយជ្រំ ដែលវិទ្យាល័យ ទាំង ៣ នេះអ្នកសិក្សាជ្រើសរើសយកតែ ជាវិទ្យាល័យដែលមិនស្ថិតក្រោមគម្រោង SEIP ក្នុងនោះរួមមានៈ ១) វិទ្យាល័យ ហ៊ុន សែន សាមគ្គី

ដូនសរ ២) វិទ្យាល័យគោកព្រីង និង ៣ ) វិទ្យាល័យពោធិ៍ធំ ។  ដោយស្ថានភាពនាពេលបច្ចុប្បន្ន ការរាតត្បាតនៃជម្ងឺ Covid 19 នៅតែបន្តរីករាលដាលមិនឈប់ឈរធ្វើឲ្យថ្នាក់ដឹកនាំកំពូលនៃរដ្ឋាភិបាលកម្ពុជា បានធ្វើសេចក្តីសម្រេចចិត្តបិទខ្ទប់នៅតាមតំបន់មួយចំនួនដែលមានហានិភ័យខ្ពស់ងាយឆ្លងជម្ងឺ ។  ការបិទខ្ទប់នេះក្នុងគោលបំណង ទប់ស្កាត់ការឆ្លង និងចម្លងនៃ ជម្ងឺ Covid 19 នេះ ។ ដោយឡែកស្ថានភាព Covid 19 នៅខេត្តស្វាយរៀងក៏  មានការរីករាលដាលខ្លាំងផងដែរ ជាមូលហេតុធ្វើឲ្យអាជ្ញាធរមូលដ្ឋានក្នុងខេត្តបានសម្រេចចិត្តបិទខ្ទប់តំបន់ មួយចំនួនក្នុងខេត្ត ស្វាយរៀងផងដែរនេះជាហេតុផលធ្វើឲ្យអ្នកស្រាវជ្រាវមានផលលំបាកខ្លាំងក្នុងការចុះប្រមូលទិន្នន័យ ដោយមូលហេតុនេះហើយទើបអ្នកស្រាវជ្រាវបានសម្រេច កំណត់ជាគុសំណាកតាមស្ថានភាពជាក់ស្តែងដោយ ប្រមូលទិន្នន័យតាមប្រព័ន្ធ Online គឺធ្វើតាម Google form ដោយជ្រើសរើសយកតែលោកគ្រូអ្នកគ្រូដែលបង្រៀននៅ មធ្យមសិក្សាទុតិយភូមិ ដែលបង្រៀននៅថ្នាក់ទី ១០ , ទី១១ , និង ទី១២ មានចំនួន ៥៥ នាក់ គណៈគ្រប់គ្រងជានាយកសាលា ០៣នាក់  ជានាយករងបច្ចេកទេស  ០៣នាក់  និង បុគ្គលិករដ្ឋបាលចំនួន ០៤ នាក់ សរុបគណៈគ្របគ្រងសាលារៀន មាន១០ នាក់ដូចនេះជាគុសំណាកសរុបទទួលបានគឺចំនួន ៦៥ នាក់ ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១៖** សេចក្តីផ្តើមរួមមាន  លំនាំបញ្ហានៃការស្រាវជ្រាវ  ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវគោល បំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ  និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

**ជំពូកទី២៖** រំឭកទ្រឹស្តី ពិនិត្យមើលឯកសារ និងការសិក្សាពីមុនៗ ដើម្បីស្វែងយល់ពីភាពខុសគ្នារវាងការសិក្សាស្រាវជ្រាវដែលកំពុងធ្វើជាមួយនឹងការសិក្សាស្រាវជ្រាវពីមុនមក ។

**ជំពូកទី៣៖** រៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវដែលអ្នកសិក្សាស្រាវជ្រាវ យកមកប្រើប្រាស់ក្នុងដំណើរការស្រាវជ្រាវនេះ ។ នៅក្នុងជំពូកនេះផងដែរអ្នកស្រាវជ្រាវ នឹងបង្ហាញពីរបៀបនៃការសិក្សា ការប្រមូលសំណាក ការប្រមូលពត៌មាន ការវិភាគពត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើប្រាស់រូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ ។

**ជំពូកទី៤៖** លទ្ធផលនិងការពិភាក្សា ក្នុងជំពូកនេះ អ្នកស្រាវជ្រាវ នឹងលើកឡើងពីលក្ខណៈជាក់ស្តែងដែលខ្លួនបានធ្វើការសិក្សាស្រាវជ្រាវរួចហើយគឺ ត្រូវឆ្លើយតបទៅនឹងចំណុចដែលចោទសួរ នៅក្នុងចំណោទបញ្ហា ។ ការពិភាក្សា គឺត្រូវធ្វើយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការ ស្រាវជ្រាវទ្រឹស្តី ឬ ខ្លឹមសារដែលមានក្នុងកម្រងសំណួរ ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវត្រូវធ្វើការសង្ខេបការ សិក្សាស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ ឬសំណូមពរទៅ លើចំណុចដែលត្រូវកែលម្អ ។

# ជំពូកទី២

# រំឭកទ្រឹស្តី

# ជំពូក២

## រំឭកទ្រឹស្តី

តាមសៀវភៅ ការគ្រប់គ្រងថវិការសាលារៀន ២០១៧ របស់ក្រសួងអប់រំយុវជន និងកីឡា បានលើកឡើងថា ការងារគ្រប់គ្រងអាចសំដៅទៅដល់សកម្មភាពខុសៗគ្នាជាច្រើន ។ ឧទាហរណ៍៖ ការគ្រប់គ្រងរបស់រដ្ឋាភិបាល ដឹកនាំប្រទេស ការគ្រប់គ្រងគ្រួសារ ការគ្រប់គ្រងអង្គភាព ...។ ប៉ុន្តែការងារ និងវិធីគ្រប់គ្រងមានប្រព័ន្ធខុសគ្នា មានការងារ និងជំនាញដោយឡែកពីគ្នា ។ ប្រភេទនៃការគ្រប់គ្រងខុសគ្នា តាមអង្គភាព និងស្ថាប័ននីមួយៗ គឺអាស្រ័យទៅតាមគោលបំណង ទំហំ សីលធម៌របស់អង្គភាព ទៅតាមការទទួលខុសត្រូវ និងភារកិច្ចរបស់ អ្នកកគ្រប់គ្រង ។ ជាទូទៅការងារគ្រប់គ្រង គ្មានរូបមន្តងាយស្រួលណាមួយ ដែលក្រោយពេលរៀនរួចចេះអាច យក ទៅជួយអ្នកគ្រប់គ្រងឲ្យធ្វើអ្វីត្រូវជានិច្ច ឬសម្រេច និងគ្រប់គ្រងត្រូវរហូតនោះទេ សិល្បៈនៃការគ្រប់គ្រងទាមទារឲ្យអ្នកគ្រប់គ្រងមានជំនាញច្រើន ហើយដឹងច្បាស់ថាជំនាញណាដែលគប្បីយកមកប្រើក្នុងកាលៈទេសៈណាមួយដែលសាកសម ។

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវផ្តោតខ្លាំងទៅលើ និយមន័យនៃពាក្យគន្លឹះដែលទាក់ទងទៅ នឹង ការអនុវត្តការងារគ្រប់គ្រង របស់នាយកសាលាធៀបទៅនឹង ការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល (SMB) ពាក្យគន្លឹះដែលត្រូវលើកយកមកធ្វើការពន្យល់បកស្រាយលំអិតនោះ គឺ ការគ្រប់គ្រង និង លទ្ធផល ។

### ២.១ និយមន័យ

- **ការងារគ្រប់គ្រង**(Management) គឺសំដៅដល់ការធ្វើផែនការ ការរៀបចំចាត់ចែង ការដឹកនាំ និង ការត្រួតពិនិត្យធនធានមនុស្ស និងធនធានដ៏ទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័នប្រកបដោយប្រសិទ្ធភាព ។ (ក្រសួងអប់រំ យុវជន និងកីឡា ,ការគ្រប់គ្រងថវិការសាលារៀន ២០១៧) ។

- **ការគ្រប់គ្រង** គឺជាដំណើការ នៃការធ្វើផែនការ ដឹកនាំ រៀបចំ ចាត់ចែងត្រួតពិនិត្យ ទៅលើការ ប្រើប្រាស់ ធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចដល់គោលដៅរបស់អង្គភាព ។ **ការគ្រប់គ្រង** សំដៅ

លើការ ធ្វើផែនការ  ការរៀបចំចាត់ចែង  ការដឹកនាំ ការត្រួតពិនិត្យ ធនធានមនុស្ស  និងធនធានផ្សេងៗ ទៀតដើម្បី   សម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័នប្រកបដោយប្រសិទ្ធភាព**(ក្រសួងអប់រំ  យុវជន និងកីឡា ២០១៦)។**

**អ្នកគ្រប់គ្រង** (Management) សំដៅដល់អ្នកទទួលខុសត្រូវអភិបាលកិច្ចក្នុងការប្រើប្រាស់ ធនធាននានា របស់អង្គភាពឲ្យសម្រេចដល់គោលដៅ (ក្រសួងអប់រំ យុវជន និងកីឡា ,ការគ្រប់គ្រងថវិការសាលារៀន ២០១៧) ។

**ការគ្រប់គ្រងធនធានមនុស្ស** គឺជាមុខងារមួយនៅក្នុងអង្គភាពដែលជួយសម្រួលដល់ការប្រើប្រាស់ មនុស្សយ៉ាងមានប្រសិទ្ធភាពបំផុត ដើម្បីសម្រេចបានគោលបំណងអង្គភាព និងគោលបំណងផ្ទាល់ខ្លួនរបស់ និយោជិកម្នាក់ៗ  ។ អ៊ីវ៉ាន់ស៊ីវិក (Ivancevic) និង កូណូផាស្គេ (Konopaske) ,២០១៣ ។

**លទ្ធផល** សំដៅទៅលើផលដែលបានរួចមកហើយ ,  ផលនៃការដែលបានសម្រេចហើយ ,  កម្រៃ ដែលបាន សម្រេចមកពីការប្រកបកិច្ចការផ្សេងៗ**(វចនានុក្រមខ្មែរសង្ឃរាជជួនណាតភាគទី១  បោះពុម្ពគ្រាទី៥ , ១៩៦៧)។**

ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺផ្តល់ជូននាយកសាលា គ្រូបង្រៀន សិស្ស និងមាតាបិតា អាណាព្យាបាលសិស្ស ឬសហគមន៍ ចូលរួមលើដំណើរការនៃការអប់រំបានប្រសើឡើង ដោយផ្តល់ឲ្យពួកគេ នូវការសម្រេចចិត្តសំខាន់ៗ មាន ការចំនាយថវិកា បុគ្គលិក និងកម្មវិធីសិក្សា  ។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) អាចបង្កើត នូវបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាពសម្រាប់សិស្សានុសិស្ស  ។  ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធមានធាតុ ៤ យ៉ាងសំខាន់ៗរួមមាន ៖១) ការគ្រប់គ្រងការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤)ការគ្រប់គ្រងបុគ្គលិក(ក្រសួងអប់រំយុជន និងកីឡា ,ការគ្រប់គ្រង សាលារៀនផ្អែកលើលទ្ធផល (២០១៧)

តាមអត្ថន័យនៃពាក្យ "**ការគ្រប់គ្រង**" និងពាក្យ"**លទ្ធផល**"ប្រធានបទនៃការសិក្សាស្រាវជ្រាវចង់រំលេចបង្ហាញឲ្យ ឃើញពីការប្រតិបត្តិការងារ ធ្វើផែនការ រៀបចំចាត់ចែង ការដឹកនាំ ការត្រួតពិនិត្យ របស់នាយកសាលានៅ មធ្យមសិក្សាទុតិយភូមិ នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ត្រូវប្រៀបធៀប នឹងលទ្ធផលនៃអ្នកគ្រប់គ្រងបែប SBM ដែលក្រសួង អប់រំ យុវជន និងកីឡា បានធ្វើការកំណត់លទ្ធផលនៃការគ្រប់គ្រងរបស់នាយកសាលារៀនទុកជា មុនតាម " **សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងតាមសាលារៀន** " ក្នុងឆ្នាំ ២០១៨ ។

## ២.១.១ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល

តាមសៀវភៅ ការគ្រប់គ្រងសាលារៀនផ្អែក លើលទ្ធផល ឆ្នាំ២០១៧ របស់ ក្រសួងអប់រំ យុវជន និងកីឡា បានសរសេររៀបរាប់ដូចខាងក្រោមនេះថា ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល គឺជារបៀបឬយុទ្ធសាស្ត្រ ដើម្បីកែលម្អការអប់រំដោយផ្ទេរអំណាចនៃការសម្រេចចិត្តសំខាន់ៗ ពីការិយាល័យថ្នាក់កណ្តាល និងថ្នាក់ស្រុកទៅសាលារៀនដោយផ្ទាល់ ។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SMB) ផ្តល់ជូននាយក គ្រូបង្រៀន សិស្សានុសិស្ស និងអាណាព្យា បាលសិស្ស ចូលរួមក្នុងការគ្រប់គ្រងលើដំណើរការនៃការអប់រំបានប្រសើឡើង ដោយផ្តល់ឲ្យពួកគេនូវការទទួល ខុសត្រូវដើម្បីធ្វើការសម្រេចចិត្តអំពីថវិកា បុគ្គលិក និងកម្មវិធីសិក្សា (ការសម្រេចចិត្តសំខាន់ៗ) ។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) អាចបង្កើតនូវបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាពសម្រាប់ សិស្សានុសិស្ស ។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលមានសមាសធាតុសំខាន់ៗ ៤ គឺ ៖ ការគ្រប់គ្រងការ បង្រៀន និងរៀន , ការគ្រប់គ្រងរដ្ឋបាលសាលារៀន , ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការការគ្រប់គ្រងធនធាន មនុស្ស ។

គោលការណ៍ទូទៅនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលគឺ ៖ **អំណាច** : ដើម្បីធ្វើការសម្រេចចិត្តដែលជះឥទ្ធិពលទៅលើការអនុវត្ត គោលនយោបាយ និងទិសដៅ របស់អង្គភាព ។ **ចំណេះដឹង** : ដែលអាចឲ្យនិយោជិកយល់ដឹង និងរួមចំណែកនៅក្នុងប្រតិបត្តិការរបស់អង្គភាព រួមទាំង ចំណេះដឹងបច្ចេកទេសដើម្បីធ្វើការងារ ឬផ្តល់សេវាកម្ម ជំនាញអន្តរបុគ្គល ចំណេះដឹង និងជំនាញគ្រប់គ្រង ។ **ព័ត៌មាន ៖** ស្តីអំពីការ

ប្រតិបត្តិការរបស់អង្គភាព រួមមានប្រាក់ចំណូល ប្រាក់ចំណាយ ប្រតិបត្តិការផ្សេងៗ ហើយនិងព័ត៌មានយុទ្ធសាស្រ្តស្តីអំពីគោលការណ៍អប់រំ និងសេដ្ឋកិច្ចឲ្យកាន់តែទូលំទូលាយ ។ **រង្វាន់លើកទឹកចិត្ត** ៖ រង្វាន់លើកទឹកចិត្តផ្អែកលើប្រតិបត្តិការរបស់អង្គភាព និងការរួមវិភាគទានរបស់ បុគ្គលម្នាក់ៗ ។ **លក្ខណៈរួមនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល** : យន្តការសាលារៀនគួរមាន៖ ១)ផ្តល់កម្មវិធីសិក្សាដើម្បីបង្កើនកម្មវិធីសិក្សារបស់សិស្សឲ្យប្រសើរឡើង ២) ផែនការអនុវត្ត និងទទួលនូវគណនេយ្យភាព ៣) តម្រូវការប្រព័ន្ធតុល្យភាព និងតម្រូវការសហគមន៍ ៤)ធ្វើការសម្រេចចិត្តតាមបែបប្រជាធិបតេយ្យ និងជាក្រុម ៥) ធ្វើការគ្រប់គ្រងធនធានមូលដ្ឋាន ៦) បង្កើនសមត្ថភាព និងប្រសិទ្ធភាព ។

## ២..២ ស្ថានភាពសាលារៀនមធ្យមសិក្សានៅខេត្តស្វាយរៀង

សាលារៀនគឺជាបញ្ហាចម្បងដែលនាំឲ្យការអប់រំនៅទូទាំងសកល មានការរីកសម្រើន ។ដូចគ្នា ផងដែរបញ្ហាអគារសិក្សាជាមូលហេតុសំខាន់ជួយជម្រុញប្រសិទ្ធភាព និងគុណភាពឲ្យកាន់តែប្រសើរ ដោយឡែករាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំប្រឹងប្រែងកសាង និងសាងសង់អគារសិក្សាដើម្បីស្របតាមតម្រូវការ នៃចំនួនសិស្សានុសិស្ស ដែលមានសន្ទុះកើនឡើងគ្រប់កម្រិតថ្នាក់ ជាពិសេសគឺ សិស្សានុសិស្សរៀននៅមធ្យមសិក្សា ។ រដ្ឋាភិបាលកម្ពុជាបានបង្កើតអគារសិក្សាបានយ៉ាងច្រើន ដើម្បី បង្កភាពងាយស្រួលដល់ប្អូនៗសិស្សានុសិស្ស ធ្វើយ៉ាងណាធ្វើឲ្យសាលារៀនកាន់តែនៅជិតផ្ទះរបស់ សិស្សឲ្យបានគ្រប់ៗគ្នា ដូចនេះរដ្ឋាភិបាលអនុវត្តការបង្កើតគ្រឹះស្ថានសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ (បង្កើតអនុវិទ្យាល័យ) ឲ្យបានមួយឃុំ/សង្កាត់ត្រូវមានអនុវិទ្យាល័យមួយ រួមជាមួយការបង្កើតអគារសិក្សា នៅមធ្យមសិក្សាទុតិយភូមិជាច្រើនខ្នងផងដែរ ។ ដូចគ្នាផងដែរបើតាមសូចនាករអប់រំក្នុងឆ្នាំ ២០១៨ បានបង្ហាញថា ក្នុងខេត្តស្វាយរៀងដែលជាខេត្តជាប់ព្រំដែនខាងកើត សាលារៀននៅមធ្យមសិក្សា ទុតិយភូមិ ឬវិទ្យាល័យក្នុងខេត្តសរុបមានចំនួន ១៩ សាលា ដែលមានចំនួនថ្នាក់មាន ៨៦ និងចំនួនបន្ទប់ស្មើនឹង ៨៦ បន្ទប់ ។ ដោយឡែកក្នុងស្រុកស្វាយជ្រំមានវិទ្យាល័យចំនួន ៥ គឺ ១ វិទ្យាល័យ វិទ្យាល័យហ៊ុនសែន ស្វាយជ្រំ ២. វិទ្យាល័យ ហ៊ុនសែន សាមគ្គីដូនស ៣.វិទ្យាល័យពោធិ៍ធំ ៤. វិទ្យាល័យ

ហ៊ុនសែន ក្រោលគោ និង ៥.វិទ្យាល័យគោកព្រីង ។ ទាំងនេះបាន បង្ហាញឲ្យឃើញថាស្ថានភាពសាលារៀននៅមធ្យមសិក្សាក្នុងខេត្តស្វាយរៀងមានភាពល្អប្រសើរជាងមុន រួមទាំងនៅស្រុកស្វាយជ្រំ ផងដែរ ។

## ២.៣ ដំណើរការនៃការដឹកនាំនិងគ្រប់គ្រង




បុគ្គលិកលក្ខណៈទាំង៥របស់បុគ្គលិក និងកត្តាដែលអ្នកគ្រប់គ្រងគួរប្រតិបត្តិ( គង់ ឆាយឡេង May 15, 2020 )

ទ្រឹស្តីនៃការគ្រប់គ្រងបានចែងថា រាល់អង្គភាព ឬសហគ្រាសត្រូវការការគ្រប់គ្រងដើម្បីសម្រេចគោលដៅសំខាន់ៗរបស់ខ្លួន ជាមួយនឹងការប្រើប្រាស់ប្រាស់ធនធាន ទាំងឡាយឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។ រីឯទ្រឹស្តីសេដ្ឋកិច្ចវិញក៏អះអាងដែរថា ធនធានទាំងនោះតែងមានតម្លៃកាលានុវត្តភាព ( Opportunity Cost) របស់ខ្លួន។ ដូចនេះអ្នកទទួលខុសត្រូវរបស់អង្គភាព ត្រូវចេះគ្រប់គ្រង និងប្រើប្រាស់ធនធានដែលមានឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលមកវិញច្រើនតាមរយៈការធ្វើផែនការ ចាត់ចែង ការទទួលបាន ការចែកចាយ ការដឹកនាំ និងការត្រួតពិនិត្យលើការប្រើប្រាស់ធនធាន ទាំងនោះឲ្យជាប្រយោជន៍ដល់អង្គភាព ។ ដូច្នេះហើយគេត្រូវការ ការគ្រប់គ្រង វាឲ្យបានល្អប្រសើរ ។

ក្នុងបណ្តាធនធានខាងលើដែលអង្គភាពប្រើប្រាស់ មានតែធនធានមនុស្សប៉ុណ្ណោះដែលជាធនធានមានជីវិត។ សភាពជាមនុស្សជាសភាវៈដែលចេះគិត និងពិចារណា មានអារម្មណ៍ មនោសញ្ចេតនា ដូចនេះពួកគេ

អាចនឹងបំពេញការងារមានប្រសិទ្ធភាពខ្ពស់ កាលណាគេពេញចិត្តអង្គភាព ផ្ទុយទៅវិញ គេអាចនឹងចាកចេញពីអង្គភាពនៅពេលដែលគេមិនពេញចិត្ត។ ម្យ៉ាងទៀតដោយសារនេះជាធនាធានដែលមាន លក្ខណៈពិសេស វាទាមទារការគ្រប់គ្រងឲ្យបានល្អ ដើម្បីទទួលបានវិភាគទានពីធនធាននេះត្រលប់មកវិញ សម្រាប់ការរីកចម្រើនរបស់អង្គភាព។

មាននិយមន័យច្រើនណាស់អំពីការគ្រប់គ្រងធនធានមនុស្ស ។ ការផ្តល់នូវនិយមន័យផ្សេងៗទាំងនោះដោយសារបទពិសោធន៍ និងការមើលមកការគ្រប់គ្រងធនធានមនុស្សក្នុងទស្សនៈផ្សេងៗពីគ្នា ។ បើតាម អ៊ីវ៉ាន់ស៊ីវិក (Ivancevic) និង កូណូផាស្កេ (Konopaske) (២០១៣) ៖ ការគ្រប់គ្រងធនធានមនុស្ស គឺជាមុខងារមួយនៅក្នុងអង្គភាពដែលជួយសម្រួលដល់ការប្រើប្រាស់ មនុស្សយ៉ាងមានប្រសិទ្ធភាពបំផុត ដើម្បីសម្រេចបានគោលបំណងអង្គភាព និងគោលបំណងផ្ទាល់ខ្លួនរបស់និយោជិកម្នាក់ៗ។ មាននិយមន័យផ្សេងៗជាច្រើន មិនបានបញ្ជាក់ពីការគិតគូរទៅលើផលប្រយោជន៍ និងតម្លៃរបស់កម្មករនិយោជិកនោះទេ ។ ប៉ុន្តែការធ្វើព្រងើយកន្តើយ និងធ្វើមិនដឹងមិនលឺពីចំណុចនេះ ជាការខុសឆ្គងដែលអង្គភាព និងសហគ្រាសធនតូច និងមធ្យម (ធំមួយចំនួន) នៅបរទេស និងនៅប្រទេសកម្ពុជាយើងមិនសូវចាប់អារម្មណ៍ប៉ុន្មាននោះទេ ហើយក៏មិនដែលទទួលបានការតបស្នងឲ្យអស់ពីចិត្តពីថ្លើមពីសំណាក់បុគ្គលិក កម្មករនិយោជិកចំពោះខ្លួនវិញដែរ។ ដូចនេះវាសំដៅទៅលើនយោបាយ បទពិសោធន៍ និងប្រព័ន្ធដែលជះឥទ្ធិពលទៅលើឥរិយាបថ អាកប្បកិរិយា និងលទ្ធផលរបស់បុគ្គលិក កម្មករនិយោជិក។ វាក៏រាប់បញ្ចូលនូវសកម្មភាពទាំងឡាយរបស់អ្នកគ្រប់គ្រងក្នុងការទាក់ទាញ បណ្តុះបណ្តាល និងអភិវឌ្ឍ និងរក្សាបុគ្គលិកដើម្បីធានាថា ពួកគេបំពេញការងារមានប្រសិទ្ធភាពខ្ពស់ និងរួមចំណែកក្នុងការសម្រេចគោលដៅរបស់អង្គភាព។

## ២.៤ ការអនុវត្តន៍ការងារគ្រប់គ្រង (SBM)

ធនធានមនុស្ស ជាពិសេស ធនធានមនុស្សល្អ គឺជាសរសៃឈាមនៃស្ថាប័ន។ បើគ្មានធនធានមនុស្សល្អទេ ក្រុមហ៊ុន ឬអង្គភាព ឬស្ថាប័ននោះ មិនអាចអភិវឌ្ឍទៅមុខលឿនបានឡើយ។

ផ្ទុយទៅវិញ ស្ថាប័នទាំងនោះ ប្រឈមនឹងការបិទទ្វារដោយសារតែកង្វះធនធានមនុស្សធ្វើការ ។ យ៉ាងណាមិញ មនុស្សយើងម្នាក់ៗកើតមកមានបុគ្គលិកលក្ខណៈផ្សេងៗគ្នា ហើយបុគ្គលិកក៏ដូច្នេះដែរ។ ខាងក្រោមនេះគឺជាបុគ្គលិកលក្ខណៈទាំង ៥ របស់បុគ្គលិកដែលអ្នកគួរស្វែងយល់៖




- អ្នកប្តេជ្ញាចិត្ត ខិតខំប្រឹងប្រែងធ្វើការ ដើម្បីអង្គភាព
- អ្នកជួយលើកទឹកចិត្ត និងជម្រុញការងារឲ្យមានប្រសិទ្ធភាព
- អ្នកខ្ជិល ធ្វើការតិចតួច តែអួតច្រើន
- អ្នកធ្វើការងារស្រួលៗ ជាអ្នកជួយ ហើយក៏អាចក្លាយជាអ្នកបំផ្លាញ
- អ្នកបំផ្លាញអង្គភាព ជាមនុស្សបំបែកបំបាក់ ចាក់រុក មួលបង្កាច់បុគ្គលិកល្អៗ

យើងឃើញថាធនធានមនុស្សល្អ ពិតជាមានសារៈសំខាន់ណាស់ ដូច្នេះហើយអ្នកគ្រប់គ្រងគួរមានយុទ្ធសាស្រ្ត ក្នុងការរក្សាពួកគេអោយនៅបន្តធ្វើការអោយស្ថាប័នរបស់ខ្លួនដោយអ្នកគ្រប់គ្រង់ត្រូវ៖

១. ចេះអោយតម្លៃលើធនធានមនុស្ស តាមរយៈពាក្យសម្ដី ឬកាយវិការ។

២. ចេះគោរពធនធានមនុស្ស តាមពាក្យសម្ដី និងកាយវិការ។

៣. បើកសេរីភាពអោយពួកគេ តែពួកគេត្រូវគោរពកាតព្វកិច្ចការងាររបស់ខ្លួន។

៤. ផ្ដល់ចំណេះដឹងថ្មីៗបន្ថែមដល់ពួកគេ។ ជាគោលការណ៍ បុគ្គលិក ត្រូវការចំណេះដឹងបន្ថែមជារៀងរាល់ថ្ងៃ។ ប្រសិនបើអ្នកដឹកនាំគ្មានចំណេះសម្រាប់ផ្ទេរ និងផ្ដល់ទេនោះ បុគ្គលិកថ្នាក់ក្រោមនឹងដើរចេញនៅថ្ងៃណាមួយ។

៥. ត្រូវមើលតារាងប្រាក់ខែ និងអត្ថប្រយោជន៍ផ្សេង។ ប្រាក់ខែជារឿងសំខាន់ ប៉ុន្តែពេលខ្លះ វាមិនមែនជាដើមហេតុដែលនាំអោយបុគ្គលិកដើរចេញនោះទេ។ តាមពិត ពេលខ្លះ បុគ្គលិកដើរចេញ ដោយសារ កំហុសនៃការគ្រប់គ្រងទូទៅតែប៉ុណ្ណោះ។

អ្នកគ្រប់គ្រងក៏ត្រូវចៀសវាងផងដែរនូវកត្តាមួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់បុគ្គលិកដូចជា៖

១. ចៀសវាងការដឹកនាំតាមរបៀបបញ្ជា ហើយការបញ្ជាទៀតសោតនោះ ធ្វើឡើងតាមអារម្មណ៍។

២. ចៀសវាងការស្តីបន្ទោសបុគ្គលិកគ្រប់ពេលវេលា ហើយពួកគេធ្វើអ្វីក៏មិនត្រូវចិត្តខ្លួន។ ហើយពេលខ្លះ ការស្តីបន្ទោសរបស់ខ្លួន ធ្វើឡើងដោយមិនមានទឡ្ហីករណ៍ត្រឹមត្រូវទាល់តែសោះ។

៣. ចៀសវាងការមើលងាយធនធានមនុស្ស តាមរយៈពាក្យសម្តី ឬកាយវិការ។

៤. ចៀសវាងបង្កើតភាពអយុត្តិធម៌រវាងបុគ្គលិក និងបុគ្គលិក។

៥. ចៀសវាងដឹកនាំតាមរបៀប«ត្រចៀកស» មានន័យថា ចាប់ជឿគេ និងឆាប់ខឹង។

៦. ចៀសវាងគំនិតធ្វើអាជីវកម្មលើបុគ្គលិក-កម្មករ

( https://www.thehrdaily.com/hr/fivepersonalitiesofemployee/ )

## ២.៥ ដំណើរការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា

បើតាមសៀវភៅ យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំយុវជន និងកីឡា ២០១៨-២០២៣ បានលើកឡើងថា សាលារៀនជាថ្នាលបណ្តុះធនធានមនុស្ស និងជាទីកន្លែងផ្តល់ចំណេះដឹងដល់មនុស្សគ្រប់ៗ គ្នាជាពិសេសគឺសិស្សានុសិស្សដែលបាន នឹងកំពុងសិក្សា ។ សាលារៀនទាមទារយ៉ាងសំខាន់នូវភាពជា អ្នកដឹកនាំនិងគ្រប់គ្រងល្អរបស់នាយកសាលា ។ នាយកសាលារៀនល្អគឺត្រូវចេះរៀបចំផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាព ផែនការអភិវឌ្ឍន៍សាលារៀនឲ្យបានកាន់តែប្រសើរ ។ នាយកសាលារៀនល្អ ដែលមានភាពជាអ្នកដឹកនាំបែប

(SBM)ត្រូវអនុវត្តការងារឲ្យមានប្រសិទ្ធផលដោយផ្តោតទៅលើដំណើរ ការគ្រប់គ្រងបួនចំណុចគឺ ១) ការគ្រប់គ្រងការបង្រៀននិងរៀន ២) ការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង ៤) ការគ្រប់គ្រងធនធានមនុស្ស ។

## ២.៦ ការគ្រប់គ្រងការបង្រៀននិងរៀន

តាមសៀវភៅ យុទ្ធសាស្ត្រកំណែទម្រង់វិ ស័យអប់រំយុវជន និងកីឡា ឆ្នាំ ២០១៨-២០២៣ បានចងក្រងឡើងថា ការគ្រប់គ្រងការបង្រៀន និងរៀនជាតួនាទី យ៉ាងចាំបាច់បំផុតមួយរបស់នាយកសាលារៀន ក្នុងនោះទាមទារឲ្យនាយកសាលារៀន យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើដំណើរការដូចខាងក្រោម៖

-រៀបចំបន្ទប់ឧបករណ៍បច្ចេកវិទ្យា ដូចជាម៉ាស៊ីនបញ្ចាំង LCD កុព្យូទ័រ និងសម្ភារៈបង្រៀន ផ្សេងៗទៀតដើម្បីបញ្ជ្រាបភាពជាពលរដ្ឋមានគណភាពក្នុងការបង្រៀន ។

-កែលម្អបណ្ណាល័យឲ្យស្របតាមបណ្ណាល័យសិក្សាស្តង់ដាបណ្ណាល័យសតវត្សទី ២១ ដើម្បី ផ្តលឳកាសដល់សិស្សសានុសិស្សបានរៀនសូត្រ ស្រាវជ្រាវ និងជួយដល់ការវិភាគផ្សេងៗឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ។

-រៀបចំប្រព័ន្ធគ្រប់គ្រងសៀវភៅសិក្សាគោលឲ្យមានប្រសិទ្ធភាព ដើម្បីធានាថាគ្រប់សិស្សទាំង អស់មានសៀវភៅសិក្សាគោលសម្រាប់រៀនសូត្រតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់បានគ្រប់គ្រាន់ ព្រមទាំងទទួលបានគ្រប់ៗគ្នា។

-នាយកសាលារៀនត្រូវធ្វើការវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ។

-នាយកសាលារៀន ត្រូវជួយសម្របសម្រួលការវាយតម្លៃសាលារៀន ត្រូវឆ្លើយតបទៅ នឹង ស្តង់ដា

- នាយកសាលារៀនត្រូវប្រមូលចងក្រងទិន្នន័យ និងព័តមានសម្រាប់រៀបចំ និងបញ្ជូនរបាយការណ៍វឌ្ឍភាពប្រចាំត្រីមាស ស្តីពីការវាយតម្លៃការសិក្សារបស់សិស្ស ។

-នាយកសាលាត្រូវប្រមូល ចងក្រងទិន្នន័យ ពត៌មានសម្រាប់រៀបចំ និងបញ្ជូនរបាយការណ៍ សមិទ្ធកម្ម ប្រចាំត្រីមាសស្តីពីការសម្រេចបានសូចនាករផលសម្រេច ។

-នាយកសាលាត្រូវបញ្ចូលលទ្ធផលសិក្សារបស់សិស្សនៅក្នុងរបាយការណ៍សាលារៀន ។

-នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្ស ឲ្យតាមដានលទ្ធផលសិក្សារបស់សិស្ស ។

-សាលារៀនត្រូវផ្តល់សម្ភារៈសម្រាប់គ្រូដើម្បីផលិតសម្ភារឧបទេស សម្រាប់ការបង្រៀន និងរៀនឲ្យបាន គ្រប់គ្រាន់តាមតម្រូវរបស់គ្រូ ។

-សាលាត្រូវបង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូ ស្តីពីការគ្រប់គ្រងសាលារៀនរកបដោយប្រសិទ្ធភាព ការ គ្រប់គ្រងថ្នាក់រៀន និងការផ្ទង់អារម្មណ៍របស់សិស្សក្នុងម៉ោងបង្រៀន ។

-ផ្តល់ ឬបណ្តុះបណ្តាលបច្ចេកវិទ្យាថ្មីៗជូនលោកគ្រូ អ្នកគ្រូ ដើម្បីឲ្យគ្រូបង្រៀនប្រើប្រាស់ក្នុងការអនុវត្តន៍ វិធីសាស្រ្តថ្មីៗ ។

ចំណុចទាំងអស់នេះ ថ្នាក់ សាលារៀន ក៏ដូចជានាយកសាលារៀនត្រូវតែជួយជម្រុញ និងលើក ទឹកចិត្ត ជាប្រចាំដើម្បីជម្រុញប្រសិទ្ធភាពនៃកាអនុវត្តន៍បានកាន់តែប្រសើរ ។

## ២.៧ ការគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន

ក្នុងសៀវភៅ យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំយុវជន និងកីឡា ឆ្នាំ ២០១៨-២០២៣ ក៏បានលើក ឡើងបន្ថែមទៀតថា ក្រៅពីការគ្រប់គ្រងការបង្រៀន និងរៀន នាយកសាលារៀនក៏ត្រូវតែបន្ថែមការយកចិត្តទុក ដាក់លើការគ្រប់គ្រងរដ្ឋាបាលសាលារៀនផងដែរ គឺតម្រូវឲ្យនាយកសាលារៀនត្រូវពង្រឹងលើចំណុចមួយចំនួន ដែលគួរយកចិត្តទុកដាក់ដូចខាងក្រោម៖

-ត្រួតពិនិត្យតាមដានរាល់ការបង្រៀន និងរៀនរបស់គ្រូបង្រៀន ឲ្យបានញឹកញាប់ ។

-ចុះធ្វើអធិការកិច្ចផ្ទៃក្នុង ឲ្យបានញឹកញាប់តាមមុខវិជ្ជា នីមួយៗ និងផ្តល់មតិយោបល់ពន្យល់ ណែនាំរាល់ចំណុចខ្វះខាត និងជួយផ្តល់ការស្តាបនាកែលម្អរាល់ចំណុចខ្វះខាតទាំងនោះ ។

-លើកទឹកចិត្តការកែលម្អវិធិសាស្ត្របង្រៀនថ្មីៗ ធ្វើឲ្យសិស្សទទួលបានចំណេះដឹងលើបញ្ហា ផ្សេងៗដែលកើតមានជាសកល ។

-ជម្រុញឲ្យគ្រូបង្រៀនប្រើប្រាស់បច្ចេកវិទ្យាពត៌មានវិទ្យា និងវិធីសាស្ត្របង្រៀនថ្មីៗដើម្បីអនុវត្ត កម្មវិធីសិក្សាភាពជាពលរដ្ឋល្អ និងធ្វើឲ្យមានគុណភាពនៅក្នុងថ្នាក់រៀន ។

-ជម្រុញគ្រូឲ្យបង្រៀនបែបសិក្សាគម្រោង និងធ្វើការបំផុសគំនិតឲ្យអនុវត្តកម្មវិធីសិក្សាភាពជា ពលរដ្ឋដែលមានគុណភាព។

-លើកទឹកចិត្តគ្រូបង្រៀនឲ្យរៀបចំសម្ភារៈសិក្សា ស្របតាមបរិបទភាពជាពលរដ្ឋមានគុណភាព ដែលត្រូវធ្វើបទបង្ហាញ មានរូបភាព ក្រាហ្វិក គូសគំនូសតាង និងដ្យាក្រាម ។

-រៀបចំឲ្យមានការប្រឡងសំណេរ ក្រោមប្រធានបទពាក់ព័ន្ធ និងបញ្ហាប្រឈមនានាលើភាព ជាពលរដ្ឋប្រកបដោយគុណភាព

-នាយកសាលារៀនត្រូវ សម្របសម្រួលជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន រយៈពេល៥ឆ្នាំរំកិល និងប្រចាំឆ្នាំ ដោយកំណត់សូចនាករ ជាតុចូល ជាតុចេញ និងផលសម្រេចព្រមទាំងប្រភពហិរញ្ញប្បទាន ដោយមានការចូលរួមពីគ្រប់ភាគី ពាក់ព័ន្ធទាំងអស់ ។

-នាយកសាលាបញ្ជូនលទ្ធផលវាយតម្លៃលទការបំពេញារការងាររបស់សាលារៀនដែលឆ្លើយតប នឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដល់គណៈកម្មការគ្រប់គ្រងសាលារៀន ។

-នាយកសាលារៀន ប្រមូលពត៌មានជាក់ស្តែងស្តីពីការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្ស ការវាយតម្លៃសមត្ថភាពរបស់គ្រូបង្រៀន និងការវាយតម្លៃការអនុវត្តរបស់សាលារៀន ។

-សាលារៀនបង្កើតវប្បធម៌នៃការចែករំលែក ព័ត៌មានដោយកំណត់បញ្ហាប្រឈម រួមគ្នាជាមួយ ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីបង្កើតការជឿទុកចិត្ត ពីសហគមន៍ បុគ្គលិកសាលារៀន និងមាតាបិតា សិស្សទៅលើគ្រូបង្រៀន និងសាលារៀន ។

-សាលារៀនត្រូវអនុវត្តកម្មវិធីសិក្សាតាមការណែនាំ និងបង្កើតកម្មវិធីសិក្សាបន្ថែម ។

-សាលារៀនរៀបចំផែនការគ្រោងថវិកា រៀបចំរបាយការណ៍ និងគ្រប់គ្រងការបំពេញការងារ របស់បុគ្គលិក ។

-នាយកសាលារៀនត្រូវអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងស្នើរង្វាន់ជូនដល់បុគ្គលិកដែលបំ ពេញការងារបានល្អ ព្រមទាំងស្នើការចាត់វិធានការរដ្ឋបាល សម្រាប់បុគ្គលិកអសកម្មការងារ ។

-នាយកសាលារៀន ផ្តួចផ្តើមបង្កើនគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តសហគមន៍ ឲ្យចូលរួមក្នុងការគ្រប់គ្រងសាលារៀន ។

-នាយកសាលារៀនត្រូវរៀបចំបរិយាកាសការងារនៅក្នុងប្រព័ន្ធគ្រប់គ្រងសាលារៀន ដើម្បីបង្កើន ភាពជឿទុកចិត្ត និងការសហការល្អ ។

- នាយកសាលារៀនត្រូវគ្រោងថវិកា សម្រាប់គាំទ្រជំនួបរវាងមាតាបិតាសិស្ស និងសហគមន៍ មូលដ្ឋានជាមួយគ្រូបង្រៀន និងគាំទ្រសកម្មភាពប្រជុំក្រុមប្រឹក្សាកុមារ និង យុវជន ។

-សាលារៀនផ្សព្វផ្សាយទិន្នន័យ និងពត៌មានរបស់សាលារៀនដល់សហគមន៍ និងអាជ្ញាធរ មូលដ្ឋាន ។

## ២.៨ ការគ្រប់គ្រងថវិកាសាលារៀន

តាមសៀវភៅ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល២០១៧ បានបញ្ជាក់ថា ថវិកា គឺជាបញ្ហាសំខាន់នៅគ្រប់ស្ថាប័ន ហើយការគ្រប់គ្រងថវិកាឲ្យបានល្អគឺជារឿង ដែលត្រូវយកចិត្តទុកដាក់បំផុតដើម្បីជៀសវាងទំនាស់ផលប្រយោជន៍នានាដែលអាចកើតមានឡើងនៅក្នុងគ្រួសារ ឬក្នុងសង្គមភាព ។ ដូចគ្នាផងដែរការគ្រប់គ្រងថវិកា សាលារៀនបានល្អគឺជាតួនាទីនិងភារៈកិច្ចយ៉ាងសំខាន់របស់នាយកសាលារៀន ដូចនេះសាលារៀនត្រូវមានគោលការណ៍គ្រប់គ្រងថវិកាឲ្យបានច្បាស់លាស់ ។

ជាធម្មតានៅក្នុងសាលារៀនមួយ ការគ្រប់គ្រងថវិកាចាំបាច់ទាមទារ ឲ្យមានការចូលរួម ពីគ្រប់ភាគីអ្នកពាក់ព័ន្ធសំខាន់ៗមានដូចជា គណៈកម្មការអភិវឌ្ឍន៍សាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រងនិងប្រើប្រាស់ថវិកា និងអ្នកពាក់ព័ន្ធមួយចំនួនទៀតដែលចាំបាច់ជាអ្នកចូលរួមដឹងឮពីចំណូលការទុកដាក់ និងការចំណាយទាំងឡាយណាដែលសាលារៀនមាន ទៅតាមកាលកំណត់ណាមួយដែលបានព្រមព្រៀងគ្នា។ យុន្តការនៃការគ្រប់គ្រងថវិកាសាលារៀន : ការរៀបចំឲ្យមានយន្តការ ក្នុងការគ្រប់គ្រងថវិកា របស់សាលារៀន គឺជាការបង្ហាញឲ្យភាគីពាក់ព័ន្ធនានាបានចូលរួមក្នុងការទទួលខុសត្រូវតាមតួនាទី និងភារកិច្ចរៀងៗខ្លួន ។ នាយកសាលារៀនត្រូវ រៀបចំ អនុវត្តដំណើរការនៃការរៀបចំគណៈកម្មការគ្រប់គ្រងថវិកា និងរចនាសម្ព័ន្ធអ្នកគ្រប់គ្រងថវិកា សាលារៀនឲ្យបានត្រឹមត្រូវ ។

## ២.៨.១ រចនាសម្ព័ន្ធនៃការគ្រប់គ្រងថវិកាសាលារៀន




(ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល)

សៀវភៅ យុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំយុវជន និងកីឡា ឆ្នាំ២០១៨-២០២៣ ក៏បានសរសេរបញ្ជាក់ផងដែរថា: គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវមានតួនាទី និងភារៈកិច្ចដូចខាងក្រោម៖

-លើកកម្ពស់គណនេយ្យភាព នៃការគ្រប់គ្រង ការពិនិត្យតាមដានការប្រើប្រាស់ ធនធានសុវត្ថិភាពជឿទុកចិត្ត និងតម្លាភាពដែលតម្រូវឲ្យនាយកសាលា ដាក់របាយការណ៍ស្តីពី ការគ្រប់គ្រង ហិរញ្ញវត្ថុ ជូនគណៈកម្មការគ្រប់គ្រងសាលារៀន ។

-ពង្រឹងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង និងប្រព័ន្ធអធិការកិច្ច ដោយផ្អែកលើស្វ័យវាយតម្លៃ សាលារៀន និងការត្រួតពិនិត្យជាប្រចាំ ។

-ផ្តល់របាយការណ៍ជាប្រចាំស្តីពីភាពពេញចិត្ត នៃការគ្រប់គ្រង និងសំណូមពរ ។

-ផ្សព្វផ្សាយរបាយការណ៍ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ ដល់អ្នកពាក់ព័ន្ធសំខាន់ៗដើម្បីធានាបាន នូវតម្លាភាព ។

## ២.៩ ការគ្រប់គ្រងធនធានមនុស្ស

តាមសៀវភៅ យុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំយុវជន និងកីឡា ក្នុងឆ្នាំ ២០១៨-២០២៣ បាន សរសេរបញ្ជាក់បន្ថែមថា គ្រប់អង្គភាពទាំងងអស់ អាចរីកចម្រើនទៅបានគឺអាស្រ័យលើធនធានមនុស្សនៅក្នុង អង្គភាពមានចំណេះដឹង សមត្ថភាព ពេញលេញ ហើយត្រូវទទួលបានការរៀបចំចាត់ចែងយ៉ាង ច្បាស់លាស់ ចំទិសដៅ ស្របតាមសមត្ថភាព ដោយភាពឆ្លាតវៃក្នុងការចាត់ចែងពីប្រធានអង្គភាព ។ ដូចគ្នាផងដែរនៅតាមសាលារៀននាយកសាលារៀន មាននាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងបុគ្គលិក និងសិស្សានុសិស្ស ក្នុងសាលារៀនដែលជាធនធានមនុស្សយ៉ាងសំខាន់ក្នុងសាលារបស់ខ្លួន ដែលត្រូវតែ បង្កើនការយកចិត្តទុកដាក់ ។

ការគ្រប់គ្រងធនធានមនុស្សគឺសំដៅដល់ការគ្រប់គ្រង បុគ្គលិកក្រោមឪវាទរួមមានគ្រូ បង្រៀនដែលជាសេនាទិការរបស់នាយកផ្ទាល់នៅក្នុងសាលារៀន ។ នាយកសាលារៀនមានតួនាទី យ៉ាងសំ ខាន់ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន ដោយនាយកសាលាត្រូវបំពេញការងារ និងអនុវត្តន៍តួនាទីដូចខាងក្រោម៖

- ✓ វាយតម្លៃការបំពេញការងាររបស់បុគ្គលិកបង្រៀន និងមិនបង្រៀនដោយផ្តោតលើ លទ្ធផលការសិក្សារបស់សិស្ស ។
- ✓ ធ្វើការលើកទឹកចិត្តដល់បុគ្គលិកទាំងឡាយដែលបំពេញការងារបានល្អ និងចាត់ វិធានការរដ្ឋបាលចំពោះបុគ្គលិកអសកម្ម ។
- ✓ សាលារៀនត្រូវរៀបចំផែនការ និងប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាពរបស់បុគ្គលិក
- ✓ នាយកសាលារៀនត្រូវផ្តល់ជាតុចូលទាំងអស់ដែលជាតម្រូវការរបស់សាលា
- ✓ នាយកសាលារៀនត្រូវស្វ័យវាយតម្លៃសាលារៀនជាប្រចាំ ដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្សស្របតាមកម្មវិធីសិក្សារបស់សាលារៀន ។

## ២.១០ ការពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រង

យោងតាម សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន ឆ្នាំ២០១៨ បានលើកឡើងថា សមត្ថភាពរបស់បុគ្គលម្នាក់មានមិនដូចគ្នាទេ  បុគ្គលខ្លះមានសមត្ថភាពធាប់ចេះធាប់ ចាំ តាំង ពីកំណើតបុគ្គលខ្លះមានសមត្ថភាពចងចាំខ្សោយឯអ្នកគ្រប់គ្រងនិងដឹកនាំ  ក៏មានលក្ខណៈប្រហាក់ ប្រហែល និងដូចគ្នាផងដែរ អ្នកដឹកនាំ និងគ្រប់គ្រងខ្លះមានសមត្ថភាពដឹកនាំ  និងភាពជាអ្នកគ្រប់គ្រងបានល្អ   និង ផ្ទុយទៅវិញអ្នកដឹកនាំនិងគ្រប់គ្រង មួយចំនួនទៀតមានសមត្ថភាពខ្សោយ នូវភាពជា អ្នកដឹកនាំ និងគ្រប់គ្រង  ក្រោមហេតុផលផ្សេងៗរបស់ពួកគាត់រៀងៗខ្លួន។ ដោយមើលឃើញពីចំណុចខ្វះខាតនេះក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំក្រុមការងារបង្កើនគុណវុឌ្ឍិគ្រូបង្រៀន ក្នុងនោះមានអគ្គនាយករងម្នាក់  នៃអគ្គលេខាធិការដ្ឋានគោលនយោបាយ  និងផែនការជាប្រធានក្រុម ។

ក្រុមការងារនេះនឹងផ្តល់ការណែនាំរួម  និងធ្វើការបំប៉ននៅនឹងកន្លែងសម្រាប់មន្ត្រីថ្នាក់ក្រោម ជាតិ និងសាលារៀនដើម្បីអនុវត្តការបង្រៀនឲ្យមានប្រសិទ្ធភាព  ស្របតាមសេចក្តីណែនាំពីការគ្រប់ គ្រងតាមសាលារៀន និងប្រព័ន្ធត្រួតពិនិត្យតាមដានវាយតម្លៃផ្អែកលើលទ្ធផលផ្អែកលើអនុវិស័យ ។ គ្រូបង្គោលនៅថ្នាក់ជាតិ និងផ្តល់ការបំប៉នក្នុងអំឡុងពី  ពីរទៅបីឆ្នាំដំបូង ដើម្បីធានាថាគ្រូបង្រៀនមាននូវ  ចំណេះ ដឹងពេញលេញចំពោះមុខវិជ្ជាឯកទេស និងមានសមត្ថភាពគរុកោសល្យគ្រប់គ្រាន់ ។

## ២.១១ ប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រង បុគ្គលិក

ការដឹកនាំនិងគ្រប់គ្រងជាការងារមួយដែលតែងតែជួបនូវបញ្ហាប្រឈមជាញឹកញាប់ គ្រប់ៗអង្គ ភាព អ្នកគ្រប់គ្រងនិងដឹកនាំតែងតែខិតខំរកវិធីសាស្រ្តនានាយកមកដោះស្រាយ និងសម្របសម្រួល ដល់រាល់បញ្ហាប្រឈមដែលកើតមានឡើង ។ នៅតាមសាលារៀនជាញឹកញាប់ក៏គេសង្កេតឃើញមាន បញ្ហាផ្សេងៗកើតមានឡើង ដូចជាបញ្ហាអសកម្មការងាររបស់គ្រូ ទំនាស់ផលប្រយោជន៏ក្នុងអង្គភាព បញ្ហាបាត់បង់ទំនុកចិត្ត បាត់បង់ការជឿទុកចិត្តចំពោះរបៀបដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលា រៀនជាដើម ។ ដូចនេះដើម្បីធ្វើឲ្យការដឹកនាំ

និងគ្រប់គ្រងរបស់នាយកសាលា ប្រកបដោយប្រសិទ្ធ ភាព និងមានទំនុកចិត្ត មានភាពជឿជាក់ចំពោះនាយក សាលារៀន  គឺនាយកសាលារៀនត្រូវដើរតួយ៉ាង សំខាន់ក្នុងការអនុវត្តន៍ការងារធ្វើជាគម្រូប្រកបដោយប្រសិទ្ធ ភាព និងមានតម្លាភាព សុក្រិត្តិភាព ទាំង ដំណើការការអនុវត្តការងារប្រចាំថ្ងៃ  ការធ្វើផែនការថវិកា និងជាពិសេសគឺការចំណាយថវិកាសាលា រៀននេះតែម្តង   ។

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១ ពត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំ និងធ្វើឡើងដោយប្រើទិន្នន័យបែបបរិមាណវិស័យ ដែលត្រូវយកមកវិភាគ ដើម្បីស្វែងយល់ពីកម្រឹតខុសគ្នារវាងការអនុវត្តការគ្រប់គ្រងរបស់នាយកសាលានៅមធ្យមសិក្សាទុតិភូមិជាមួយ នឹង ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នៅតាមគ្រឹះស្ថាន សិក្សាដែលជាវិទ្យាល័យក្នុងស្រុក និងជាសាលាគោលដៅត្រូវសិក្សាស្រាវជ្រាវលើប្រធានបទនេះ ។ តែជាទូទៅការធ្វើការប្រៀបធៀបតែងតែអាចចេញជាលទ្ធផល ៤ ប្រភេទគឺ អាចទទួលបានលទ្ធផល កម្រិតល្អប្រសើរជាង កម្រិតល្អ កម្រិតមធ្យម និងកម្រិតខ្សោយជាង ។ លទ្ធផលដែលទទួលបាននេះហើយដែលជា សមតិកម្មចង្អុលបង្ហាញឲ្យអ្នកសិក្សាស្រាវជ្រាវមាន ឳកាសផ្តល់យោបល់ សំណូមពរលើលទ្ធផលដែលបាន សិក្សាស្រាវជ្រាវរកឃើញ និងដើម្បីពាំនាំលទ្ធផលទាំងនោះជូនដល់ថ្នាក់ដឹកនាំក្នុងវិស័យអប់រំ ថ្នាក់ដឹកនាំក្នុង ក្រសួងអប់រំ និងអ្នកពាក់ព័ន្ធផ្សេងទៀត សម្រាប់ជួយកែលម្អ ឬធ្វើការលើកទឹកចិត្តបន្ថែម ក្នុងគោលបំណង ពង្រឹងគុណភាពអប់រំឲ្យកាន់តែល្អ នៅក្នុងប្រទេសកម្ពុជាយើង ។

## ៣.២ ទីកន្លែងត្រូវស្រាវជ្រាវ

ការអនុវត្តការងារគ្រប់គ្រង គឺជារឿងចាំបាច់បំផុតនៅគ្រប់អង្គភាពទាំងអស់ ទោះបីជាស្ថាប័នឯកជនក្តី ឬស្ថាប័នរដ្ឋក្តី ពិសេសគឺការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព សមភាព និងប្រសិទ្ធផល ។ ដូចគ្នាផងដែរនៅក្នុងវិស័យអប់រំ សុទ្ធសឹងតែត្រូវការភាពជាអ្នកដឹកនាំនិងគ្រប់គ្រងល្អយ៉ាងសំខាន់ ទាំងគ្រឹះស្ថានបឋមសិក្សាក្តី ឬគ្រឹះស្ថានមធ្យមសិក្សាក្តី និងគ្រឹះស្ថានឧត្តមសិក្សាក្តី ។ ការគ្រប់គ្រងល្អ មានឥទ្ធិពលយ៉ាងខ្លាំងដល់ការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា ប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងជម្រុញឲ្យមានការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ។ ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សា ទុតិយភូមិ នៅខេត្តស្វាយរៀង ជាពិសេសគឺក្នុងស្រុកស្វាយជ្រំ អ្នកស្រាវជ្រាវបានសម្រេចជ្រើសរើសយក

ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ជាកន្លែង ឬជាសាលាដែលត្រូវចុះសិក្សាស្រាវជ្រាវ ។ អ្នកស្រាវជ្រាវជ្រើសរើសយក វិទ្យាល័យបីមិនស្ថិតនៅក្នុងគម្រោងគាំទ្ររបស់ ស៊ីប រួមមានៈ ១- វិទ្យាល័យ ពោធិ៍ធំ ២- វិទ្យាល័យ ហ៊ុន សែន សាមគ្គី ដូនស និង ៣- វិទ្យាល័យគោកព្រីង ក្នុងចំណោមវិទ្យាល័យទាំងប្រាំ នៅក្នុងស្រុកស្វាយជ្រំ ដោយឡែកមានវិទ្យាល័យពីរស្ថិតនៅក្នុងគម្រោងគាំទ្ររបស់ស៊ីប អ្នកស្រាវជ្រាវមិនត្រូវបានយកមកធ្វើការស្រាយជ្រាវទេ ដោយផ្អែកទៅលើកត្តាពេលវេលា ស្ថានភាពការរីករាលដាល នៃជម្ងឺកូវីដ១៩ កត្តាធនធានមានកំណត់ និងដើម្បីបង្កើនប្រសិទ្ធភាពនៃការស្រាវជ្រាវ ។

### ៣.៣ ក្រុមគោលដៅស្រាវជ្រាវ

ដើម្បីធ្វើឲ្យការស្រាវជ្រាវនេះកាន់តែមានប្រសិទ្ធភាពជាមួយ នឹងប្រធានបទខាងលើ អ្នកស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសយកក្រុមមនុស្ស ដែលពាក់ព័ន្ធសំខាន់ៗ គឺផ្តោតចំពោះតែ គណៈគ្រប់គ្រងសាលារៀន ( នាយក នាយករង បុគ្គលិករដ្ឋបាល ) និង គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិតែប៉ុណ្ណោះ ដោយឡែកចំពោះគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ និងសិស្សានុសិស្ស អ្នកស្រាវជ្រាវសម្រេចចិត្តមិនជ្រើស រើសយកមកធ្វើជាក្រុមគោលដៅដែលត្រូវបំពេញកម្រងសំណួរទេ ។ ចំពោះការសិក្សាស្រាវនេះ អ្នកស្រាវជ្រាវផ្តោតសំខាន់ទៅលើ គណៈគ្រប់គ្រងសាលារៀន បុគ្គលិករដ្ឋបាល និង គ្រូបង្រៀន ដែលកំពុងបម្រើការងារ នៅវិទ្យាល័យក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង (គ្រូបង្រៀនថ្នាក់ទី ១០ ថ្នាក់ទី១១ ដល់ ថ្នាក់ទី១២ ) ។ ចំពោះ លោកគ្រូ អ្នកគ្រូដែលបានធ្វើការជ្រើសរើស អ្នកស្រាវជ្រាវមិនគិតពីក្របខណ្ឌនោះទេ ប៉ុន្តែពួកគាត់គឺត្រូវតែជាបុគ្គលិកដែលកំពុងបង្រៀន ឬកំពុងបម្រើការងារ ក្នុងវិស័យ អប់រំ និង ជ្រើសរើសត្រឹមតែជាបុគ្គលិកមធ្យមសិក្សាទុតិយភូមិតែប៉ុណ្ណោះ ។

### ៣.៣.១ តារាងក្រុមគោលដៅ និងអ្នកចូលរួម

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម | ផ្សេងៗ |
|---|---|---|---|
| ០១ | នាយកសាលា | ០៣នាក់ | |
| ០២ | នាយករងផ្នែកបច្ចេកទេស | ០៣នាក់ | |
| ០៣ | បុគ្គលិករដ្ឋបាល | ០៤នាក់ | |
| ០៤ | គ្រូបង្រៀន | ៥៥នាក់ | |
| សរុប | | ៦៥នាក់ | |

### ៣.៤ ទំហំសំណាក

ដោយផ្អែកទៅលើស្ថានភាពជម្ងឺ កូវីដ ១៩ នៅតែបន្តរីករាលដាលខ្លាំងពេញក្របខណ្ឌទូទាំងប្រទេស ពិសេសគឺស្ថានភាពកូវីដ១៩ នៅក្នុងខេត្តស្វាយរៀងមានការ ចម្លង និងឆ្លងកាន់ច្រើន ព្រមទាំងទទួលបានបម្រាមគោចរណ៍ ពីសំណាក់រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានផង អ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសចំនួនសំណាកត្រឹមតែចំនួនសរុប ៦៥ រូប ។ ភាគសំណាកដែលត្រូវជ្រើសរើសយកមកស្រាវជ្រាវរួមមាន គណៈគ្រប់គ្រងជានាយកសាលាចំនួន០៣ នាក់ គណៈគ្រប់គ្រងជានាយករងផ្នែកបច្ចេកទេស ចំនួន ០៣នាក់ បុគ្គលិកផ្នែករដ្ឋបាលចំនួន០៤នាក់ និង គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ (បង្រៀនថ្នាក់ទី១០ ,ថ្នាក់ទី១១ និងថ្នាក់ទី១២) ចំនួន ៥៥នាក់ សរុប អ្នកត្រូវចូលរួមមាន ៦៥ នាក់ ។ ចំពោះទីតាំងដែលត្រូវចុះទៅស្រាវជ្រាវ គឺស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលអ្នកស្រាវជ្រាវធ្វើការកំណត់យកសំណាកជាមួយសាលាដែលមិនស្ថិតក្នុងគម្រោង របស់ស៊ីបហើយជ្រើសរើសយក ៣ វិទ្យាល័យ ក្នុងចំណោម ៥ វិទ្យាល័យក្នុងស្រុក ដែលពីរសាលាផ្សេងទៀតអ្នកស្រាវជ្រាវសម្រេចចិត្ត ថាមិនជ្រើរើសយកមកសិក្សាទេ ដោយហេតុផលថាជាសាលាស្ថិតក្នុងគម្រោងគាំទ្ររបស់ស៊ីប ។

## ៣.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសតាមបែបបរិមាណវិស័យដោយប្រើប្រាស់កម្មវិធី Excel គណនារកតម្លៃ MEAN (មធ្យម) ដើម្បីរកតម្លៃប្រៀបធៀបអថេរ ។ ចំពោះប្រធានបទ " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែក លើលទ្ធផល (SMB) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " ។ ការសម្រេចចិត្តជ្រើសរើសយកការ ស្រាវជ្រាវតាមបែបបរិមាណវិស័យមកធ្វើជាវិធីសាស្ត្រក្នុងការស្រាវជ្រាវដោយប្រើប្រាស់កម្រងសំណួរដោយចុះ ទៅផ្ទាល់ជូនដល់ភាគសំណាកជួយបំពេញ ប៉ុន្តែអាស្រ័យដោយកាលៈទេសៈ និងស្ថានភាព ជម្ងឺកូវីដ១៩ មិនអំណោយផល ទើបអ្នក ស្រាវជ្រាវសម្រេចចិត្ត ផ្ញើកម្រងសំណួរជូនលោកគ្រូអ្នកគ្រូជួយបំពេញតាម Online (**ផ្ញើតាម Google Form**) សម្រាប់ចុះប្រមូលទិន្នន័យ លើការស្រាវជ្រាវនៃប្រធានបទនេះ ។

## ៣.៦ ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះបានកំណត់ជ្រើសរើសយកវិទ្យាល័យចំនួន០៣ដែលស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង រួមមានៈ ១-វិទ្យាល័យ ហ៊ុន សែន សាមគ្គី ដូនស ២- វិទ្យាល័យ ពោធិ៍ធំ និង ៣- វិទ្យាល័យ គោកព្រីង ។ ដែលសំណាកត្រូវស្រាវជ្រាវសរុប ៦៥ នាក់ ក្នុងនោះរួមមាន គណៈគ្រប់គ្រងចំនួន ០៦ នាក់ បុគ្គលិករដ្ឋបាល ០៤នាក់ គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ( ថ្នាក់ទី១០ , ថ្នាក់ទី១១ , និងថ្នាក់ទី១២ ) ចំនួន ៥៥នាក់ ។

## ៣.៧ ឧបករណ៍ស្រាវជ្រាវ

ក្នុងចំណោមឧបករណ៍ជាច្រើនដែលមានសម្រាប់យកមកអនុវត្តលើការស្រាវជ្រាវ អ្នកស្រាវជ្រាវ បានសម្រេចជ្រើសរើសការប្រើប្រាស់កម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ (ផ្ញើតាម Google Form )ជាគោល ។ តែទោះជាយ៉ាងណាអ្នកស្រាវជ្រាវបានប្រើប្រាស់របៀបផ្សេងៗទៀតជាច្រើនដើម្បីជួយគាំទ្រឧបករណ៍សំខាន់

ខាងលើឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែម ដូចជាការធ្វើការប្រាស្រ័យទាក់ទងជាមួយលោកគ្រូអ្នកគ្រូ តាមរយៈទូរស័ព្ទដៃដោយផ្ទាល់ ការធ្វើទំនាក់ទំនងតាម SMS ក្នុង Telegram , Messenger and Facebook ជាដើម ។

ក្នុងនោះអ្នកស្រាវជ្រាវ បានបែងចែកកម្រងសំណួរជាពីរប្រភេទគឺ ៖ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា ( នាយក នាយករង បុគ្គលិករដ្ឋបាល ) និងកម្រងសំណួរសម្រាប់គ្រូ (បុគ្គលិកបង្រៀន) ។ តាមរយៈប្រធានបទនេះអ្នកស្រាវជ្រាវបានជួបពិភាក្សា និងទទួលបានមតិយោបល់ពីសាស្ត្រាចារ្យដឹកនាំបង្គោល និងដឹកនាំរង សម្រេចនិងកំណត់ថាអាចប្រើប្រាស់កម្រងសំណួរតែមួយប្រភេទគឺកម្រងសំណួរដែល មានអត្ថន័យនិងខ្លឹមសារប្រហាក់ប្រហែលគ្នារវាងកម្រងសំណួរសម្រាប់គ្រូបង្រៀន និងកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀនមាន នាយក នាយករង បុគ្គលិករដ្ឋបាលផងដែរ ។

**កម្រងសំណួរត្រូវបានប្រើរួមគ្នាសម្រាប់គ្រូ និងគណៈគ្រប់គ្រងសាលារៀន៖**

កម្រងសំណួរសម្រាប់គ្រូអ្នកស្រាវជ្រាវចែកជា បីផ្នែកសំខាន់ មានសំណួរសរុប ៤៦ សូចនាករ ។

- ផ្នែកទី១: ព័ត៌មានទូទៅ អ្នកស្រាវជ្រាវចង់ដឹងពី ឈ្មោះសាលា ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ តួនាទី និងទីលំនៅបច្ចុប្បន្ន របស់អ្នកជួយបំពេញ ។
- ផ្នែកទី២: អ្នកស្រាវជ្រាវបានកំណត់សំណួរស្រាវជ្រាវចំនួន ៣៥សូចនាករដោយផ្តោត ទៅលើការវាយតម្លៃរបស់គ្រូចំពោះ ការបំពេញការងារ និងការគ្រប់គ្រងរបស់នាយកសាលារៀន ។ ក្នុងដំណើរការនៃការបំពេញ និងការគ្រប់គ្រងរបស់ នាយក សាលា អ្នកស្រាវជ្រាវ ចង់ដឹងបន្ថែមលើ បួនចំណុចសំខាន់គឺ៖ ក )ការគ្រប់គ្រងការបង្រៀន និងរៀន ខ) ការគ្រប់គ្រងរដ្ឋបាលសាលារៀន គ)ការគ្រប់គ្រងហិរញ្ញវត្ថុ និង ឃ) ការគ្រប់គ្រងធនធានមនុស្ស ។

ក) ការគ្រប់គ្រងការបង្រៀន និងរៀន ៖ ត្រង់ចំណុចនេះមាន០៩ សំណួរសម្រាប់ឆ្លុះ បញ្ចាំងពី សកម្មភាពនៃការអនុវត្ត ការងារគ្រប់គ្រងរបស់នាយកសាលារៀន ពាក់ព័ន្ធ ទៅ នឹងការជួបប្រជុំ ជានាប្រសិទ្ធភាពវត្ត

បំណាងថ្នាក់រៀន ការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន ការជម្រុញ ការស្រាវជ្រាវការបង្កើតបណ្ណាល័យសតវត្សថ្មី ការធ្វើអធិការកិច្ចក្នុងថ្នាក់ ការផ្តល់ឱកាសជូនគ្រូចូលរួមវាយតម្លៃការបង្រៀន និងរៀន និងការលើកទឹកចិត្តដល់មាតាបិតាសិស្សឲ្យតាមដាន លទ្ធផលសិក្សារបស់កូន ។

ខ) ការគ្រប់គ្រងរដ្ឋបាលសាលារៀនៈ មាន០៨ សំណួរ សម្រាប់ឆ្លុះបញ្ចាំងពីសកម្មភាព នៃការអនុវត្តការងារគ្រប់គ្រងរបស់នាយកសាលារៀនដោយផ្តោតទៅលើ ការផ្តល់កិច្ចគាំទ្រ និងសហការលើការអនុវត្តការងារ ការផ្សាភ្ជាប់គោលដៅសិក្សា ជាមួយនឹងសហគមន៍ ការបង្កភាពងាយស្រួលអនុវត្តន៍ វត្ថុបំណាងថ្នាក់រៀនរបស់គ្រូ ជម្រុញការអនុវត្តសម្រេចតាមគោលនយោបាយជាតិ ចូលរួមជានាការបង្រៀនរបស់គ្រូឆ្លើយ តបតាមចក្ខុវិស័យរបស់ក្រសួង ការបង្កើតសំបុត្រតម្លាភាពទទួលព័ត៌មានទាំងក្នុង និងក្រៅអង្គភាព ការផ្សព្វផ្សាយ ព័ត៌មាននានារបស់សាលាជូនសហគមន៍ និង ការលើកទឹកចិត្តសហគមន៍ចូលរួមក្នុងការគ្រប់គ្រង ត្រួតពិនិត្យតាមដានការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ។

គ) ការគ្រប់គ្រងហិរញ្ញវត្ថុៈ មាន០៨ សំណួរ សម្រាប់ឆ្លុះបញ្ចាំងពីសកម្មភាពនៃការអនុវត្តការងារ គ្រប់គ្រងរបស់នាយកសាលារៀនដោយផ្តោតទៅលើ ការរៀបចំផែនការថវិកា ការចំណាយថវិកាប្រចាំឆ្នាំ ការបង្កើតកម្មវិធីកៀងគរមូលនិធិទ្រទ្រង់សាលា ការបង្កើតគណៈកម្មការ គ្រប់គ្រងថវិកាសាលា ការជ្រើសរើសតំណាងសហគមន៍ជាគណៈគ្រប់គ្រងថវិកា ការប្រជុំពិភាក្សាជាមួយគ្រូ ជាមួយសហគមន៍ស្តីពីគណនេយ្យភាពចំណាយ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុជាសាធារណៈ និងការប្រជុំផ្សព្វផ្សាយពីលទ្ធផលប្រចាំឆ្នាំស្តីពីតម្លាភាពនៃការប្រើប្រាស់ថវិកាប្រចាំឆ្នាំ របស់សាលារៀន ។

ឃ) ការគ្រប់គ្រងធនធានមនុស្ស ៖ មាន០៧ សំណួរ សម្រាប់ឆ្លុះបញ្ចាំងពីសកម្មភាព នៃការ អនុវត្តការងារ គ្រប់គ្រងរបស់នាយកសាលារៀនដោយផ្តោតទៅលើ ការបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈបន្ថែម ជូនគ្រូ ការផ្តល់ឱកាសជូនគ្រូបង្កើតវិធីសាស្ត្របង្រៀនថ្មីៗ ការផ្តល់ប្រព័ន្ធលាបការជូនគ្រូ និងបុគ្គលិកមាន ស្នាដៃ

ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកប្រកបដោយតម្លាភាព ការគាំទ្រទាំងសម្ភារទាំង បច្ចេក ទេ្ទសដល់គ្រូក្នុងការអនុវត្តការងារ និង ចំនួនគ្រូសរុបធៀបទៅនឹងនិយាមសិស្ស ។

- ផ្នែកទី៣ ៖ អ្នកស្រាវជ្រាវបានកំណត់សំណួរស្រាវជ្រាវចំនួន ៣៥សូចនាករដោយផ្តោត ទៅលើការវាយតម្លៃលើបញ្ហាប្រឈមរបស់នាយកសាលាលើដំណើរការគ្រប់គ្រងសាលារៀន នៅមធ្យមសិក្សាទុតិយភូមិ ។ ត្រង់ចំណុចបញ្ហាប្រឈមអ្នកស្រាវជ្រាវ បានកំណត់សំណួរស្រាវ ជ្រាវចំនួន ១១ សូចនាករ សម្រាប់ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងការគ្រប់គ្រងរបស់នាយក រួមមាន ការបង្រៀន និងរៀនរបស់គ្រូមិនទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ ការរៀបចំកិច្ចតែងការ របស់គ្រូមិនទាន់បានគ្រប់មុខវិជ្ជា ការបែងចែកបក្សពួកការរើសអើងរបស់បុគ្គលិក គ្រូបង្រៀន អវត្តមានច្រើនពេលប្រជុំបច្ចេកទេស គ្រូបង្រៀនខ្វះការសហការក្នុងការអនុវត្តការងារ ប្រចាំថ្ងៃ សាលារៀនខ្វះមន្ត្រីជំនាញក្នុងការរៀបចំផែនការប្រចាំឆ្នាំ សិស្សមករៀនមិនទៀងទាត់, សិស្សមករៀនយឺត និងបោះបង់ច្រើន ចំណេះដឹងគ្រូក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតទាប ចំណូលថវិកាប្រចាំឆ្នាំរបស់សាលា មានកម្រិតទាបធៀបជាមួយចំណាយ និងមានទំនាស់ផលប្រយោជន៍កើតមានឡើងក្នុងអង្គភាព ។

គ្រប់ផ្នែកទាំងអស់ ទាំងផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ អ្នកស្រាវជ្រាវតម្រូវឲ្យលោកគ្រូអ្នកគ្រូ ដែលជួយបំពេញអាចជ្រើសចម្លើយតែមួយប៉ុណ្ណោះ ក្នុងចម្លើយជាច្រើននៃសំណួរនីមួយៗ ដោយតម្រូវឲ្យអ្នកបំពេញគូសសញ្ញាធីក ☑ ក្នុងប្រអប់ដែលត្រូវតាមការពិតជាក់ស្តែង និងត្រូវតាមស្ថានភាពនៃការអនុវត្តការងារគ្រប់គ្រង និងដឹកនាំរបស់នាយកសាលានៅមធ្យមសិក្សា ទុតិយភូមិ បានត្រឹមត្រូវ តាមសកម្មភាពដែលនាយក សាលារៀនបានអនុវត្តជាក់ស្តែងនៅអង្គភាពរៀងៗខ្លួន ។

## ៣.៨ ការប្រមូលពត៌មាន

បន្ទាប់ពីកម្រងសំណួរបានបង្កើតរួចរាល់ ដោយបានត្រួតពិនិត្យ និងឆ្លងយោបល់សម្រេចពីសាស្ត្រា ចារ្យដឹកនាំបង្គោល និងដឹកនាំរងអ្នកស្រាវជ្រាវបានធ្វើលិខិត ស្នើរពីវិទ្យាស្ថានជាតិអប់រំ ដើម្បី ទទួលបានលិខិតឧទ្ទេសនាមចុះប្រមូលទិន្នន័យ ។

ក្រោយពីទទួបានលិខិតពីវិទ្យាស្ថានជាតិអប់រំ អ្នកស្រាវជ្រាវបានទៅជួបថ្នាក់ដឹកនាំនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីសុំការសហការពាក់ព័ន្ធនឹងការចុះប្រមូលទិន្នន័យនេះ ។ បន្ទាប់ពីទទួលបានលិខិតជួយសហការពីថ្នាក់ដឹកនាំ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តរួចមកអ្នកស្រាវជ្រាវ បានធ្វើដំណើរពាំនាំយកលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យទៅជួបគណៈគ្រប់គ្រងតាមសាលាគោលដៅ ដែលអ្នកស្រាវជ្រាវបានកំណត់ទុក ដើម្បីសុំការអនុញ្ញាតចុះប្រមូលទិន្នន័យពីគណៈគ្រប់គ្រងតាមសាលានីមួយៗ ។ ដោយស្ថានភាពជម្ងឺ កូវីដ ១៩ អ្នកស្រាវជ្រាវបានធ្វើដំណើរទៅជួប និងសុំការអនុញ្ញាតិ ផ្ទាល់ជាមួយលោកនាយកសាលាបានចំនួនពីរវិទ្យាល័យ ដោយឡែកនៅវិទ្យាល័យមួយផ្សេងទៀតអ្នកស្រាវជ្រាវសម្រេចចិត្តសុំការអនុញ្ញាត តាមរយៈការ Call តាមទូរស័ព្ទទៅផ្ទាល់សុំការអនុញ្ញាតសហការ ពីគណៈគ្រប់គ្រងសាលាដោយសុំក្រុម Telegram តាមសាលានីមួយៗ និងសុំការ អនុញ្ញាត Add ចូលក្នុងក្រុម Telegram សាលានីមួយៗ ព្រមទាំងសុំការអនុញ្ញាត ផ្ញើកម្រងសំណួរតាមប្រព័ន្ធ Online ជូនលោកគ្រូអ្នកគ្រូ ជួយបំពេញតាម Google Form។ ការបំបំពេញកម្រងសំណួរតាម Google form នេះគឺមានរយៈពេល ៣០ថ្ងៃ គឺគិតចាប់ពីថ្ងៃទី០១ ខែសីហា រហូតដល់ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ។ ក្រោយពីការបំបេញកម្រង សំណួរតាម Google form បានបញ្ចប់អ្នកស្រាវជ្រាវបានប្រមូលយកទិន្នន័យទាំងនោះត្រៀមយកទៅវិភាគ ។

## ៣.៩ ការវិភាគទិន្នន័យ

ក្រោយពីការប្រមូលព័ត៌មានដែលបានចុះស្រាវជ្រាវមកអ្នកស្រាវជ្រាវ នឹងយកទិន្នន័យដែលប្រមូលបានយកមកវិភាគតាមកម្មវិធី Excel ដើម្បីរកឲ្យឃើញពីចំណុចល្អប្រសើជាង ឬអន់ថយជាងរវាងដំណើរការ គ្រប់

គ្រងនិងដឹកនាំរបស់នាយកសាលារៀនទាំងបីខាងលើ ទៅធៀបជាមួយ នឹងការដឹកនាំនិងគ្រប់គ្រងរបស់ នាយកសាលារៀនផ្ដោលលើលទ្ធផល (SBM) ។ រាល់ទិន្នន័យទាំងអស់នឹងត្រូវវិភាគពន្យល់ដោយមានការប្រៀបធៀបពីទស្សនៈរបស់លោកគ្រូ អ្នកគ្រូលើដំណើរការគ្រប់គ្រងរបស់នាយក និងទស្សនៈរបស់គណៈគ្រប់គ្រងខ្លួនឯងផ្ទាល់លើសកម្មភាពនៃការអនុវត្តប្រចាំថ្ងៃ ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំដោយខ្លួនឯងផ្ទាល់ ។

## ៣.១០ ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ ជាបឋមអ្នកស្រាវជ្រាវបានធ្វើការណែនាំខ្លួន និងជម្រាបជូនពីគោលបំណងក្នុងការចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យ និងធ្វើការសន្យាលើលក្ខខណ្ឌមួយចំនួនដូច ជារក្សាការសម្ងាត់ជូន គាត់ព័ត៌មានដែលប្រមូលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេង ឡើយហើយរាល់ការប្រមូលព័ត៌មានត្រូវបានសុំការអនុញ្ញាត និងមានការឯកភាព ពីអ្នកចូលរួម ។ ក្នុងដំណើរ ការប្រមូលព័ត៌មានគឺត្រូវបានជ្រើសរើសយកទីកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ ។ អ្នកស្រាវជ្រាវបានរៀបចំខ្លួនបានយ៉ាងសមសួន ប្រើប្រាស់សម្ដីទន់ភ្លន់ សុភាពរាបសារ ប្រកបដោយការគោរព រាប់អានឲ្យតម្លៃនិងសុំអនុញ្ញាតជួបតាមពេលវេលាសក្ដិសមបំផុតសម្រាប់ Call ណាត់ជួបធ្វើ Google form ឬ Telegram ជូនលោកគ្រូអ្នកគ្រូ ។ ក្រៅពីការរៀបរាប់ពីនីតិវិធី នៃការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវមិនធ្វើការផ្ដល់យោបល់ ឬ អនុសាសន៍ផ្សេងៗដល់អ្នកចូលរួមជាដាច់ខាត គឺរាល់ព័ត៌មានទាំងអស់អ្នកចូលរួមជាអ្នកសម្រេចចិត្តផ្ដល់ជូនដោយ ខ្លួនឯងយ៉ាងសុក្រិតភាព ។

## ៣.១១ ព្រំដែននៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺផ្ដោតទៅលើការអនុវត្តការការងារគ្រប់គ្រងនិងដឹកនាំរបស់នាយកសាលានៅមធ្យមសិក្សាទុតិភូមិ ដោយផ្ដោតសំខាន់ទៅលើការបំពេញការងារ ៤ ចំណុចរបស់នាយក សាលារៀនរួមមាន ៖ ១) ការគ្រប់គ្រងការបង្រៀន និងរៀន ២) ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣) ការគ្រប់គ្រងថវិកាសាលារៀន និង ៤) ការគ្រប់គ្រងធនធានមនុស្សនៅក្នុងសាលារៀន ។ រាល់ខ្លឹមសារនៃកម្រងសំណួរគឺមិនសំដៅលើ

ខ្លឹមសារដែលប្រាសចាក ឬឃ្លាតឆ្ងាយពីប្រធានបទនោះទេ គឺអ្នកស្រាវជ្រាវជ្រើសរើសសម្រិតសម្រាំងយកតែខ្លឹមសារទាំងឡាយដែលទាក់ទងទៅនឹងប្រធាន បទតែប៉ុណ្ណោះ ។ ព័ត៌មានដែលទទួលបានត្រូវបានអ្នកស្រាវជ្រាវជួយរក្សាសិទ្ធ រក្សាការសម្ងាត់ មិនបានបញ្ជាក់ ឈ្មោះ ឬអ្វីមកបញ្ជាក់អត្តសញ្ញាណរបស់អ្នកចូលរួមនោះឡើយ ។ ការសិក្សាស្រាវជ្រាវនេះគឺគ្រាន់តែចង់ស្វែង យល់បន្ថែមលើដំណើការដឹកនាំនិងគ្រប់គ្រងរបស់នាយកសាលានៅមធ្យមសិក្សាលើរបៀបអនុវត្តន៍ ៤ចំណុច សំខាន់ដើម្បីយកមកប្រៀបធៀបជាមួយ ការដឹកនាំនិងគ្រប់គ្រងដោយផ្អែកលើលទ្ធផល(SBM) ។ ម្យ៉ាងទៀត ចំពោះទំហំ ឬទីតាំងគឺអ្នកស្រាវជ្រាវបានជ្រើសរើសយក ត្រឹមតែបីវិទ្យាល័យក្នុងស្រុកស្វាយជ្រំ ដូចនេះការស្រាវ ជ្រាវនេះមានលក្ខណៈតូចនៅឡើយមិនអាចតំណាងទូទាំងខេត្តស្វាយរៀងបានទេ ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

ជំពូកនេះអ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផល នៃការវិភាគទិន្នន័យលើប្រធានបទ ៖ " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែក លើលទ្ធផល (SMB) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " ។ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានយកមកបកស្រាយតាមរយៈការបំពេញកម្រងសំណួរ ទៅលើក្រុមគោលដៅដែលត្រូវជួយបំពេញរួមមាន ៖ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនមាន នាយក នាយករង បុគ្គលិកផ្នែករដ្ឋបាល ។ លទ្ធផលដែលទទួលបាន នឹងត្រូវយកមកពិភាក្សា និងវិភាគលើការអនុវត្តការងារគ្រប់គ្រងរបស់នាយកសាលាដោយផ្តោតលើការអនុវត្ត ៤ ចំណុច សំខាន់នៃការដឹកនាំ និងគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល គឺ ៖ ១)ការគ្រប់គ្រងការបង្រៀន និងរៀន ២) ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣)ការគ្រប់គ្រងថវិកាសាលារៀន និង ៤) ការគ្រប់គ្រងធនធានមនុស្ស តាមរបៀបដូចខាងក្រោមនេះ៖

### ៤.១ ការកំណត់កម្រិតនៃការវាយតម្លៃ

ការវិភាគនេះអ្នកស្រាវជ្រាវ បានប្រើប្រាស់កម្មវិធី Excel ក្នុងការគណនារកតម្លៃមធ្យម Mean ដើម្បីវាយតម្លៃកម្រិតនៃការអនុវត្តការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលានៅមធ្យមសិក្សាទុតិយភូមិ ដោយធ្វើ ការកំណត់ការវាយតម្លៃចែកជាប្រាំកម្រិត ទៅតាមមធ្យមភាគដូចខាងក្រោម ៖ ១) ខ្សោយណាស់ មានតម្លៃ Mean =1 ដល់ Mean= 1.80 , ២ ) ការអនុវត្តបានខ្សោយមានតម្លៃ Mean =1.81 ដល់ Mean = 2.60, ៣) ការអនុវត្តបានមធ្យមមានតម្លៃ Mean = 2.61 ដល់ Mean = 3.40 , ៤ ) ការអនុវត្តបានល្អ (Mean = 3.41 ដល់ Mean= 4.20 និង ៥) ការអនុវត្តបានល្អណាស់ Mean = 4.21 ដល់ Mean = 5.00 (Best 1970 formulation ) ។

## ៤.២ សំណួរស្រាវជ្រាវទី១ ការចង្អុលបង្ហាញរបស់គ្រូ និងគណៈគ្រប់គ្រង

នៅក្នុងចំណុចនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវសំណួរទី ១ ដែល អ្នកស្រាវជ្រាវបានកំណត់នៅក្នុងជំពូកទី២នៃនិក្ខេបបទ ។ សំណួរស្រាវជ្រាវទី១ ដែលអ្នកស្រាវជ្រាវ ត្រូវយកមកធ្វើការស្រាវជ្រាវគឺ " តើការបំពេញការងារដឹកនាំនិងគ្រប់គ្រង ឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) មាន ប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ ? "

ក្រោយពីបានប្រមូលទិន្នន័យរួចមក អ្នកស្រាវជ្រាវបានកំណត់កម្រិតនៃការចង្អុលបង្ហាញ នៃតម្លៃមធ្យមជាប្រាំកម្រិតដូចខាងក្រោមគឺ៖ ១) កម្រិតខ្សោយមានមធ្យមភាគចន្លោះពី ១-១.៨០ ២)កម្រិតមធ្យមមាន មធ្យមភាគចន្លោះពី ១.៨១-២.៦០ ៣) កម្រិតល្អបង្គួរ មានមធ្យមភាគចន្លោះពី ២.៦១-៣.៤០៣ កម្រិតខ្ពស់ មានមធ្យមភាគចន្លោះពី៣.៤១-៤.២០ និង ៥) កម្រិតខ្ពស់ណាស់ មានមធ្យមភាគចន្លោះពី ៤.២១-៥.០០ ។

**តារាង៤.២.១ ការគ្រប់គ្រងការបង្រៀន និងរៀន**

| ល.រ | ១.ការគ្រប់គ្រង ការបង្រៀន និងរៀន | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | តម្លៃគម្លាត | កម្រិត | មធ្យមភាគ | តម្លៃគម្លាត | កម្រិត |
| ១ | នាយកសាលា បានជួបប្រជុំជាមួយគ្រូ ដើម្បីកំណត់កម្មវិធីសិក្សាឬគោលដៅសិក្សា | 4.18 | 0.55 | ខ្ពស់ | 4.30 | 0.48 | ខ្ពស់ណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | នាយកសាលា ធានាអោយប្រាកដថា វត្ថុបំណងថ្នាក់រៀនរបស់គ្រូ ត្រូវគ្នាជាមួយវត្ថុបំណងរបស់សាលា | 3.89 | 0.71 | ខ្ពស់ | 4.10 | 0.88 | ខ្ពស់ |
| ៣ | នាយកសាលា បានកំណត់ពេលវេលាក្នុងការអនុវត្តកម្មវីធីសិក្សាឱ្យបានសមស្របតាមនិយាម | 3.98 | 0.68 | ខ្ពស់ | 4.10 | 0.32 | ខ្ពស់ |
| ៤ | នាយកសាលា បានជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សាឬគោលដៅសិក្សា | 4.25 | 0.62 | ខ្ពស់ណាស់ | 4.20 | 0.63 | ខ្ពស់ណាស់ |
| ៥ | នាយកសាលា បានជំរុញកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍ ក្នុងស្ថាប័ន | 4.13 | 0.61 | ខ្ពស់ | 4.00 | 0.67 | ខ្ពស់ |
| ៦ | នាយកសាលា បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសំបូរបែបក្នុងការអាន និងសិក្សាស្រាវជ្រាវ | 3.93 | 0.94 | ខ្ពស់ | 4.30 | 0.67 | ខ្ពស់ណាស់ |
| ៧ | នាយកសាលា បានត្រួតពិនិត្យនិងវាយតំលៃ( ធ្វើអធិការកិច្ច )លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ | 3.87 | 0.75 | ខ្ពស់ | 3.90 | 0.32 | ខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | នាយកសាលា បង្កលទ្ធភាព អោយគ្រូពាក់ព័ន្ធក្នុងដំណើរវាយតម្លៃការរៀន និងបង្រៀន | 3.98 | 0.65 | ខ្ពស់ | 3.90 | 0.32 | ខ្ពស់ |
| ៩ | នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឲ្យតាមដានលទ្ធផលសិក្សរបស់កូន | 4.27 | 0.71 | ខ្ពស់ណាស់ | 4.10 | 0.57 | ខ្ពស់ |
| | មធ្យមភាគសរុប | 4.05 | 0.71 | ខ្ពស់ | 4.10 | 0.56 | ខ្ពស់ |

តាមតារាង៤.២.១ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងការបង្រៀន និងរៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួល មធ្យមភាគសរុប 4.05 ស្ថិតក្នុងកម្រិតវាយតម្លៃ កម្រិតខ្ពស់ ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺ « នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឲ្យតាមដានលទ្ធផលសិក្សារបស់កូន » ពិន្ទុមធ្យមភាគគឺ ៤.២៧ (កម្រិតខ្ពស់ណាស់ ) និងសូចនារដែលទទួលបានពិន្ទុទាបបំផុតគឺ « នាយកសាលា បានត្រួតពិនិត្យ និងវាយតំលៃ(ធ្វើអធិការកិច្ច)លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ»ពិន្ទុមធ្យមភាគ ៣.៨៧(កម្រិតខ្ពស់) ។

ទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបង្ហាញថា ការគ្រប់គ្រងការបង្រៀន និងរៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) ទទួលបានមធ្យមភាគពិន្ទុសរុប ៤.១០ (កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ « នាយកសាលា បានជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សាឬគោលដៅសិក្សា » និងសូចនាករ « នាយកសាលា បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសំបូរបែបក្នុងការអាន និងសិក្សា

ស្រាវជ្រាវ » គឺ ពិន្ទុមធ្យមភាគ ៤.៣០ (កម្រិតខ្ពស់ណាស់) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " នាយកសាលា បានត្រួតពិនិត្យនិងវាយតំលៃ(ធ្វើអធិការកិច្ច) លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ" និង" នាយកសាលា បង្កលទ្ធភាពអោយគ្រូពាក់ព័ន្ធក្នុងដំណើរវាយតម្លៃការរៀន និងបង្រៀន " ទទួលបានពិន្ទុ មធ្យមភាគសរុប ៣.៩០ (កម្រិតខ្ពស់) ។

**តារាង៤.២.២ .ការគ្រប់គ្រងរដ្ឋបាលសាលារៀន**

| ល.រ | **ការគ្រប់គ្រងរដ្ឋបាលសាលារៀន** | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | គម្លាតស្តង់ដារ | កម្រិត | មធ្យមភាគ | គម្លាតស្តង់ដារ | កម្រិត |
| ១ | នាយកសាលា ផ្តល់កិច្ចគាំទ្រ សហការ លើដំណើរការអនុវត្តការងារ | 4.07 | 0.47 | ខ្ពស់ | 4.30 | 0.48 | ខ្ពស់ណាស់ |
| ២ | នាយកសាលា ផ្សារភ្ជាប់គោលដៅសិក្សា ទៅកាន់គ្រូ សិស្ស ឪពុកម្តាយ និងសហគមន៍ | 4.05 | 0.65 | ខ្ពស់ | 4.20 | 0.42 | ខ្ពស់ |
| ៣ | នាយកសាលា ធានាប្រាកដថា គោលដៅសិក្សា អាចអនុវត្តបានងាយស្រួលចំពោះគ្រូនៅក្នុងវត្ថុបំណងថ្នាក់រៀន | 3.87 | 0.64 | ខ្ពស់ | 3.80 | 0.63 | ខ្ពស់ |
| ៤ | នាយកសាលា បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ | 3.96 | 0.64 | ខ្ពស់ | 4.30 | 0.67 | ខ្ពស់ណាស់ |
| ៥ | នាយកសាលា ធានាបានថារាល់ចំណុចអាទិភាពនៃការបង្រៀនរបស់គ្រូឧទ្ទេសឆ្លើយតបនឹងផែនការ និងចក្ខុវិស័យរបស់វិទ្យាស្ថាន | 3.78 | 0.71 | ខ្ពស់ | 3.90 | 0.74 | ខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | បានបង្កើតប្រអប់សំបុត្រ តម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ | 3.35 | 0.89 | បង្គួរ | 3.80 | 0.42 | ខ្ពស់ |
| ៧ | មានការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានារបស់សាលា ដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន | 4.22 | 0.42 | ខ្ពស់ណាស់ | 4.30 | 0.48 | ខ្ពស់N ណាស់ |
| ៨ | លើកទឹកចិត្តដល់សហគមន៍ ចូលរួមក្នុងការគ្រប់គ្រងសាលារៀននិងពិនិត្យតាម ដាន ការវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា | 4.04 | 0.67 | ខ្ពស់ | 4.20 | 0.42 | ខ្ពស់ |
| មធ្យមភាគសរុប | | 3.92 | 0.69 | ខ្ពស់ | 4.10 | 0.56 | ខ្ពស់ |

តាមតារាង៤.២.២ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងរដ្ឋបាលសាលារៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួល មធ្យមភាគសរុប ៣.៩២ (កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺ " មានការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានារបស់សាលា ដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន" ទទួលបានពិន្ទុមធ្យមភាគ ៤.២២ (កម្រិតខ្ពស់ណាស់) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " បានបង្កើតប្រអប់សំបុត្រតម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ "ពិន្ទុមធ្យមភាគ ៣.៣៥ (កម្រិតបង្គួរ) ។

ទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបង្ហាញថា ការគ្រប់គ្រងរដ្ឋបាលសាលារៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) ទទួលបានមធ្យមភាគពិន្ទុសរុប ៤.១០ (កម្រិតខ្ពស់) ។

សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ "នាយកសាលា ផ្តល់កិច្ចគាំទ្រ សហការ លើដំណើរការអនុវត្តការងារ " និង "នាយកសាលា បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោ បាយជាតិ " និងសូចនាករ "មានការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានារបស់សាលា ដល់សហគមន៍ និងអាជ្ញា ធរមូលដ្ឋាន " មានពិន្ទុមធ្យមភាគ ៤.៣០ (កម្រិតខ្ពស់ណាស់) និងសូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " នាយកសាលា ជានាប្រាកដថា គោលដៅសិក្សា អាចអនុវត្តបានងាយស្រួលចំពោះគ្រូ នៅក្នុងវត្ថុបំណងថ្នាក់រៀន " និង " បានបង្កើតប្រអប់សំបុត្រ តម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ " ទទួលបានពិន្ទុ មធ្យមភាគសរុប ៣.៨០ (កម្រិតខ្ពស់) ។

**តារាង៤.២.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ**

| ល.រ | ការគ្រប់គ្រងហិរញ្ញវត្ថុ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | គម្លាតគំរូ | កម្រិត | មធ្យមភាគ | គម្លាតគំរូ | កម្រិត |
| ១ | នាយកសាលា បានរៀបចំផែនការកែលម្អសាលា និងថវិកាសាលារៀន | 4.25 | 0.58 | ខ្ពស់ណាស់ | 4.40 | 0.52 | ខ្ពស់ណាស់ |
| ២ | នាយកសាលា បានចំណាយថវិកាសាលារៀនត្រូវតាមខ្ទង់ចំណាយ | 4.00 | 0.54 | ខ្ពស់ | 4.20 | 0.42 | ខ្ពស់ |
| ៣ | នាយកសាលា បានរៀបចំកម្មវិធី ដើម្បីកៀងគរមូលនិធិទ្រទ្រង់សាលារៀន | 3.95 | 0.87 | ខ្ពស់ | 4.40 | 0.52 | ខ្ពស់ណាស់ |
| ៤ | សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន | 4.09 | 0.59 | ខ្ពស់ | 4.60 | 0.52 | ខ្ពស់ណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | មានតំណាងសហគមន៍ធ្វើជាអនុប្រធាននៃគណៈកម្មការ គ្រប់គ្រងថវិកាសាលារៀន | 3.89 | 0.76 | ខ្ពស់ | 4.20 | 0.92 | ខ្ពស់ |
| ៦ | មានការប្រជុំពិភាក្សាជាមួយ គ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ អំពី គណនេយ្យភាពក្នុងការចំណាយរបស់សាលារៀន | 3.95 | 0.78 | ខ្ពស់ | 4.00 | 0.82 | ខ្ពស់ |
| ៧ | បានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ ជូនគណៈកម្មការគ្រប់គ្រងសាលារៀន | 4.04 | 0.58 | ខ្ពស់ | 4.30 | 0.48 | ខ្ពស់ណាស់ |
| ៨ | ប្រជុំផ្សព្វផ្សាយពីលទ្ធផលប្រចាំឆ្នាំស្តីពីតម្លាភាពការប្រើប្រាស់ថវិកាសាលារៀនជូនអ្នកពាក់ព័ន្ធ | 4.00 | 0.72 | ខ្ពស់ | 4.10 | 0.32 | ខ្ពស់ |
| មធ្យមភាគសរុប | | 4.02 | 0.69 | ខ្ពស់ | 4.28 | 0.59 | ខ្ពស់ណាស់ |

តាមតារាង៤.២.៣ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) គឺទទួល មធ្យមភាគសរុប ៤.០២(កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺ "នាយកសាលាបាន រៀបចំផែនការកែលម្អសាលានិងថវិកាសាលារៀន " ទទួលបានពិន្ទុមធ្យមភាគ ៤.២៥(កម្រិតខ្ពស់ណាស់) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " មានតំណាងសហគមន៍ធ្វើជាអនុប្រធាន នៃគណៈកម្មការគ្រប់គ្រងថវិការសាលារៀន " ពិន្ទុមធ្យមភាគ ៣.៨៩ (កម្រិតខ្ពស់) ។

ទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបង្ហាញថា ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀន ផ្អែកលើលទ្ធផល (SBM)ទទួលបានមធ្យមភាគពិន្ទុសរុប ៤.២៨ (កម្រិតខ្ពស់ណាស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ "សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន " មានពិន្ទុមធ្យមភាគ ៤.៦០ (កម្រិតខ្ពស់ណាស់) និង

សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " មានការប្រជុំពិភាក្សាជាមួយ គ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ អំពី គណនេយ្យភាព ក្នុងការចំណាយរបស់សាលារៀន " ទទួលបានពិន្ទុ មធ្យមភាគសរុប ៤.០០ (កម្រិតខ្ពស់) ។

**តារាង៤.២.៤ ការគ្រប់គ្រងធនធានមនុស្ស**

| ល.រ | ការគ្រប់គ្រងធនធានមនុស្ស | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | គម្លាតគំរូ | កម្រិត | មធ្យមភាគ | គម្លាតគំរូ | កម្រិត |
| ១ | នាយកសាលា បានបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈគ្រូ និងបុគ្គលិកស្របតាមលទ្ធផលរំពឹងទុក | 4.25 | 0.73 | ខ្ពស់ណាស់ | 3.80 | 0.63 | ខ្ពស់ |
| ២ | នាយកសាលា ផ្តល់ឱកាសដល់គ្រូ ដើម្បីបង្កើត និងពិសោធន៍ជាមួយវិធីសាស្ត្រថ្មីៗ ដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស | 3.38 | 0.53 | បង្គួរ | 4.50 | 0.53 | ខ្ពស់ណាស់ |
| ៣ | គ្រូមានសមត្ថភាពអាចសម្រេចចិត្តលើដំណើរការបង្រៀន និងស្វ័យភាព | 3.22 | 0.50 | បង្គួរ | 4.30 | 0.48 | ខ្ពស់ណាស់ |
| ៤ | នាយកសាលា បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន និងបុគ្គលិក | 4.15 | 0.81 | ខ្ពស់ | 4.00 | 0.47 | ខ្ពស់ |
| ៥ | នាយកសាលា វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ ដោយតម្លាភាព | 3.30 | 0.65 | បង្គួរ | 4.20 | 0.42 | ខ្ពស់ |
| ៦ | នាយកសាលា បានផ្តល់ការគាំទ្រទាំងសម្ភារៈ និងបច្ចេកទេសដល់គ្រូបង្រៀនក្នុងការអនុវត្តការងារ | 3.25 | 0.62 | បង្គួរ | 4.00 | 0.82 | ខ្ពស់ |
| ៧ | សាលារៀន មានគ្រូបង្រៀនគ្រប់គ្រាន់ស្របតាមនិយាម និងឯកទេស | 2.93 | 1.13 | បង្គួ | 3.20 | 1.03 | បង្គួរ |

| | | | | | | |
|---|---|---|---|---|---|---|
| មធ្យមភាគសរុប | 4.07 | 0.82 | ខ្ពស់ | 4.00 | 0.74 | ខ្ពស់ |

តាមតារាង៤.២.៤ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងធនធានមនុស្ស ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួលមធ្យមភាគសរុប ៤.០៧ (កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺ " នាយកសាលា បានបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈគ្រូ និងបុគ្គលិកស្របតាមលទ្ធផលរំពឹងទុក " ទទួលបានពិន្ទុមធ្យមភាគ ៤.២៥ (កម្រិតខ្ពស់ណាស់) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " សាលារៀន មានគ្រូបង្រៀនគ្រប់គ្រាន់ស្របតាមនិយាម និងឯកទេស" ពិន្ទុមធ្យមភាគ ២.៩៣ (កម្រិតបង្គួរ) ។

ទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបង្ហាញថា ការគ្រប់គ្រងធនធានមនុស្ស ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)ទទួលបានមធ្យមភាគពិន្ទុសរុប ៤.០០ (កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ " នាយកសាលាផ្តល់ឱកាសដល់គ្រូ ដើម្បីបង្កើត និងពិសោធន៍ជាមួយវិធីសាស្រ្តថ្មីៗដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស " មានពិន្ទុមធ្យមភាគ ៤.៥០ (កម្រិតខ្ពស់ណាស់) និងសូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " សាលារៀនមានគ្រូបង្រៀនគ្រប់គ្រាន់ ស្របតាមនិយាម និងឯកទេស " ទទួលបានពិន្ទុ មធ្យមភាគសរុប ៣.២០ (កម្រិតបង្គួរ) ។

ដោយផ្អែកទៅលើលទ្ធផលនៃពិន្ទុមធ្យមភាគនៃការដឹកនាំនិងគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល (SBM) មាន៤ ចំណុចសំខាន់ដូចបានរកឃើញខាងលើ អ្នកស្រាវជ្រាវអាចសរុបជារួមមកក្នុងសំណួរស្រាវជ្រាវទី ១ ដែលអ្នកស្រាវជ្រាវ លើកឡើងថា " តើការបំពេញការងារដឹកនាំនិងគ្រប់គ្រង ឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) មានប្រសិទ្ធភាពយ៉ាងដូចម្តេចខ្លះ? " តាមរយៈលទ្ធផលកម្រងសំណួរ ទាំងលោកគ្រូ

អ្នកគ្រូ  លទ្ធផលកម្រងសំណួរ គណៈគ្រប់គ្រងសាលាជាលទ្ធផលបានបង្ហាញថា ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាធៀបជាមួយ ការគ្រប់គ្រងដោយផ្អែកលើលទ្ធផល (SMB ) បានរកឃើញថានាយកសាលា នៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានអនុវត្តការគ្រប់គ្រង  ទាំងបួនចំណុចសំខាន់គឺ ១) ការគ្រប់គ្រងការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣) ការគ្រប់គ្រងចំណាយថវិកាសាលារៀន និង ៤) ការគ្រប់គ្រងធនធានមនុស្ស  អ្នកស្រាវជ្រាវបានរកឃើញថា នាយកសាលាអនុវត្ត ភាគច្រើនទទួលបានលទ្ធផលល្អ (កម្រិតខ្ពស់) គឺមានតែសកម្មភាពមួយចំនួនតូចប៉ុណ្ណោះដែលនាយកសាលាអនុវត្តបានត្រឹមតែ កម្រិតមធ្យម ។

**តារាង៤.២.៥ ទិន្នន័យមធ្យមភាគរួមសរុបគ្រូបង្រៀន និងគណៈគ្រប់គ្រង**

តារាងមធ្យមភាគរួមសរុបត្រូវបានអ្នកស្រាវជ្រាវ ធ្វើការសង្ខេបរួម រវាងការវាយតម្លៃ  របស់គ្រូ  បង្រៀន និងការវាយតម្លៃរបស់គណៈគ្រប់គ្រងសាលារៀន ទៅលើការអនុវត្តការដឹកនាំ និងគ្រប់គ្រង របស់ នាយកសាលារៀន ធៀបជាមួយការដឹកនាំ និងគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល ។ ក្នុងតារាងនេះផង ដែរ  អ្នកស្រាវជ្រាវបានធ្វើការសង្ខេបរួមលើពិន្ទុមធ្យមភាគនៃការអនុវត្តការងារដឹកនាំ និងគ្រប់គ្រង ៤  ចំណុចសំ  ខាន់របស់ SBM រួមមាន  ៖ ១) ការគ្រប់គ្រងការបង្រៀន និងរៀន  ២ ) ការគ្រប់គ្រងរដ្ឋបាលសាលារៀន ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ  និង ៤) ការគ្រប់គ្រងធនធានមនុស្ស  ។ ខាងក្រោមនេះអ្នកស្រាវជ្រាវនឹងធ្វើសេចក្តីសង្ខេបនៃតារាងមធ្យមភាគរួមរវាងការវាយតម្លៃរបស់គ្រូបង្រៀន និង គណៈគ្រប់គ្រង ដោយពន្យល់លម្អិតបន្ថែមលើលទ្ធផលនៃសំណួរស្រាវជ្រាវទី ១ ដូចខាងក្រោម ៖

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគសរុប គ្រូ | តម្លៃគម្លាត | កម្រិត | មធ្យមភាគសរុប គណៈគ្រប់គ្រង | តម្លៃគម្លាត | កម្រិត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងការបង្រៀន និងរៀន | 4.27 | 0.71 | ខ្ពស់ណាស់ | 4.10 | 0.56 | ខ្ពស់ |
| ២ | ការគ្រប់គ្រងរដ្ឋបាលសាលារៀន | 3.92 | 0.69 | ខ្ពស់ | 4.10 | 0.56 | ខ្ពស់ |
| ៣ | ការគ្រប់គ្រងហិរញ្ញវត្ថុ | 4.02 | 0.69 | ខ្ពស់ | 4.28 | 0.59 | ខ្ពស់ណាស់ |
| ៤ | ការគ្រប់គ្រងធនធានមនុស្ស | 4.07 | 0.82 | ខ្ពស់ | 4.00 | 0.74 | ខ្ពស់ |

តាមតារាង ៤.២.៥ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងការបង្រៀន និងរៀន ការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)គឺទទួល មធ្យមភាគសរុប ៤.២៧ (កម្រិតខ្ពស់ណាស់) និងទិន្នន័យដែលបានពីគណៈគ្រប់គ្រងទទួលបានមធ្យម ភាគសរុប ៤.១០ (កម្រិតខ្ពស់) ។

ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងរដ្ឋបាលសាលារៀន របស់នាយកសាលាធៀបការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួល មធ្យមភាគសរុប ៣.៩២ (កម្រិតខ្ពស់) និងទិន្នន័យដែលបានពីគណគ្រប់គ្រងទទួលបានមធ្យម ភាគសរុប ៤.១០ (កម្រិតខ្ពស់) ។

ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងហិរញ្ញវត្ថុ ធៀបនឹងការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួល មធ្យមភាគសរុប ៤.០២ (កម្រិតខ្ពស់) និងទិន្នន័យដែលបានពីគណគ្រប់គ្រងទទួលបានមធ្យម ភាគសរុប ៤.២៨ (កម្រិតខ្ពស់ណាស់) ។

ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថាការគ្រប់គ្រងធនធានមនុស្ស ធៀបការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) គឺទទួល មធ្យមភាគ

សរុប ៤.០៧ (កម្រិតខ្ពស់) និងទិន្នន័យដែលបានពីគណគ្រប់គ្រង ទទួលបានមធ្យម ភាគសរុប ៤.០០ (កម្រិតខ្ពស់) ។

## ៤.២.៦ ការពិភាក្សាលើកម្រងសំណួរទី១

តារាងខាងក្រោមអ្នកស្រាវជ្រាវនឹងពន្យល់មកស្រាយពីការពិភាក្សាលើខ្លឹមសារតាមលទ្ធផលដែលអ្នកស្រាវជ្រាវបានរកឃើញនៅក្នុងតារាងជាក់ស្តែងនេះ ដោយអ្នកស្រាវជ្រាវនឹងពិភាក្សាទៅលើខ្លឹមសារនៃគោលគំនិតសំខាន់ៗទាំងបួន នៃការដឹកនាំ និងគ្រប់គ្រងផ្អែកលើលទ្ធផល ដែលអ្នកស្រាវជ្រាវបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងកម្រងសំណួរទី១ តាមរយៈលទ្ធផលដែលនឹងត្រូវរៀបរាប់លំអិតបន្ថែម និងមានខ្លឹមសារដូចខាងក្រោម ៖

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគសរុបគ្រូ | គម្លាតគំរូ | កម្រិត | មធ្យមភាគសរុប គណៈគ្រប់គ្រង | គម្លាតគំរូ | កម្រិត |
| ១ | ការគ្រប់គ្រងការបង្រៀន និងរៀន | 4.27 | 0.71 | ខ្ពស់ណាស់ | 4.10 | 0.56 | ខ្ពស់ |
| ២ | ការគ្រប់គ្រងរដ្ឋបាលសាលារៀន | 3.92 | 0.69 | ខ្ពស់ | 4.10 | 0.56 | ខ្ពស់ |
| ៣ | ការគ្រប់គ្រងហិរញ្ញវត្ថុ | 4.02 | 0.69 | ខ្ពស់ | 4.28 | 0.59 | ខ្ពស់ណាស់ |
| ៤ | ការគ្រប់គ្រងធនធានមនុស្ស | 4.07 | 0.82 | ខ្ពស់ | 4.00 | 0.74 | ខ្ពស់ |

តាមតារាង៤.២.៥ ខាងលើនេះបានបង្ហាញថាលទ្ធផលនៃការគណនាកម្រងសំណួរសម្រាប់ គ្រូ និង គណៈគ្រប់គ្រងសាលារៀន ទៅលើគោលគំនិតទី១ " ការគ្រប់គ្រងការបង្រៀន និងរៀន " សម្រាប់គ្រូទទួលពិន្ទុ

មធ្យមភាគសរុប Mean = 4.27 កម្រិតខ្ពស់ណាស់ និងសម្រាប់គណៈគ្រប់គ្រងសាលារៀនទទួលបាន មធ្យមភាគពិន្ទុសរុប Mean = 4.10 កម្រិតខ្ពស់ ។ តាមលទ្ធផលនេះបានបង្ហាញថាការអនុវត្តការងារដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលារៀន គឺទទួលបានប្រសិទ្ធភាពល្អ លើការគ្រប់គ្រងការបង្រៀន និងរៀន បើធៀបជាមួយការដឹកនាំ និងគ្រប់គ្រងផ្អែកលើលទ្ធផល(SMB) ។ ការអនុវត្តមានកម្រិតល្អនេះគឺដោយសារតែលោកនាយកបានរៀបចំផែនការ និងអនុវត្តផែនការសកម្មភាពលើការគ្រប់គ្រងការបង្រៀន និង រៀនបានល្អ ដូចជានាយកសាលា បានជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សា ឬគោលដៅសិក្សាបានល្អ មានសកម្ម ញឹកញាប់ , នាយកសាលា បានប្រាកដថា វត្ថុបំណងថ្នាក់រៀនរបស់គ្រូ ត្រូវគ្នាជាមួយវត្ថុបំណងរបស់សាលា ដែលបានកំណត់ទុក ,នាយកសាលា បានកំណត់ពេលវេលា ក្នុងការអនុវត្តកម្មវិធីសិក្សាឱ្យបានល្អសមស្របតាមនិយាម , នាយកសាលា បានជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សា ឬគោលដៅសិក្សារបស់សាលារៀន បានច្បាស់លាស់ល្អ ,នាយកសាលា បានជំរុញកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍ ការងាររបស់គ្រូបង្រៀននៅក្នុងស្ថាប័នបានល្អ ,នាយកសាលា បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសំបូរបែបក្នុងការអាន និងសិក្សាស្រាវជ្រាវសម្រាប់គ្រូបង្រៀន និងសិស្សានុសិស្ស , នាយកសាលា បានត្រួតពិនិត្យនិងវាយតំលៃ(ធ្វើអធិការកិច្ច) លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ ,នាយកសាលា បង្កលទ្ធភាព អោយគ្រូ ពាក់ព័ន្ធក្នុងដំណើរវាយតម្លៃការរៀន និងបង្រៀននៅក្នុងថ្នាក់រៀន ដោយផ្ទាល់ ,នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឲ្យតាមដានលទ្ធផលសិក្សរបស់កូន ជាដើម ។ សកម្មភាពនៃការអនុវត្តខាងលើជាមូលហេតុចំបងដែលនាយកសាលានៅមធ្យមសិក្សា ទុតិយភូមិ អនុវត្តន៍លើការងារគ្រប់គ្រងការបង្រៀន និងរៀនមានប្រសិទ្ធភាពល្អ ។ ទាំងនេះក៏ជាគំរូរដ៏ល្អរបស់ នាយកសាលានៅស្រុកស្វាយជ្រំ សម្រាប់ឲ្យនាយកសាលាផ្សេងៗ ទាំងក្របខណ្ឌទូទាំង ខេត្តស្វាយរៀងអនុវត្ត តាម ក៏ដូចជា ជាគំរូរល្អសម្រាប់នាយកសាលាទូទាំងប្រទេសកម្ពុជាអនុវត្តតាមចំណុចល្អទាំងនេះ លើដំណើការគ្រប់គ្រងការបង្រៀន និងរៀន ឲ្យស្របតាមកការដឹកនាំ និងគ្រប់គ្រងផ្អែកលើលទ្ធផលធ្វើជាមូលដ្ឋានផងដែរ ។

គោលគំនិតទី២ " ការគ្រប់គ្រងរដ្ឋបាលសាលារៀន" សម្រាប់គ្រូទទួលពិន្ទុ មធ្យមភាគសរុប Mean = 3.92 កម្រិតខ្ពស់ និងសម្រាប់គណៈគ្រប់គ្រងសាលារៀនទទួលបាន មធ្យម ភាគពិន្ទុសរុប Mean = 4.10 កម្រិតខ្ពស់ ។ តាមលទ្ធផលនេះអ្នកស្រាវជ្រាវសង្កេតឃើញថា គោលគំនិតទី២នេះគឺទទួលបានមធ្យមភាគពិន្ទុ សរុបទាបជាងគេក្នុងចំណោមគោលគំនិតសំខាន់ៗទាំង៤នៃការដឹកនាំ និងគ្រប់គ្រងផ្អែកលើលទ្ធផល ដែលអ្នក ស្រាវជ្រាវបានលើកយកមកសិក្សាស្រាវជ្រាវ ។ អ្នកស្រាវជ្រាវបានរកឃើញទៀតថា ក្នុងចំណោមសូចនាករ ដែលនាយកសាលាអនុវត្តន៍លើការងាររដ្ឋបាលសាលារៀនទាំងអស់ គឺមានសូចនាករ ពីរដែលទទួលបានពិន្ទុ មធ្យមភាគតិចជាងគេ គឺ ៖ " នាយកសាលា ជានាប្រាកដថា គោលដៅសិក្សា អាចអនុវត្តបានងាយស្រួលចំពោះគ្រូ នៅក្នុងវត្ថុបំណងថ្នាក់រៀន " ដែលទទួលបានពិន្ទុមធ្យម ៣.៨៧ ទាបជាងសូចនាករផ្សេងៗទៀត នេះបញ្ជាក់ថា នាយកសាលារៀនត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើកិច្ចការគាំទ្រដល់ដំណើរការបង្រៀន និងរៀនរបស់គ្រូបង្រៀនបន្ថែមទៀត គឺជួយសម្រួលលើដំណើរការបង្រៀន និងរៀនដោយជានាឲ្យប្រាកដថា ដល់ម៉ោងបង្រៀន ថ្នាក់រៀនមិនជាប់សោរ នាយកជួយផ្គត់ផ្គង់សម្ភារពេលបង្រៀន និងរៀនឲ្យបានគ្រប់គ្រាន់ ដល់គ្រូបង្រៀន រួមមាន ហ្វឺត ទឹកហ្វឺត (ចំពោះក្តាខៀនប្រើហ្វឺត) ដីស (ក្តាខៀនប្រើដីស) ឲ្យបានគ្រប់គ្រាន់ គ្រប់ម៉ោងបង្រៀន ក្នុងបន្ទប់រៀនត្រូវមានកន្សែងជូតដៃ ធុងទឹកលាងដៃ និងសម្ភារសំអាតអនាម័យផ្សេងៗ ក្នុងថ្នាក់រៀន បន្ទប់រៀនមានអនាម័យ មានផាសុខភាព និងមានសុវត្ថិភាពក្នុងការបង្រៀន និងរៀន លើសពីនេះទៀតនាយកយកសាលារៀនគួរមាន LCD សម្រាប់បង្ករភាពងាយស្រួលដល់ការបង្រៀន និងរៀនរបស់គ្រូប្រសិន បើនាយកសាលារៀនអាចមានលទ្ធភាព ។ សូចនាករមួយទៀតនៅក្នុងគោលគំនិតទី២ នេះ (ការគ្រប់គ្រប់រដ្ឋ បាល) ដែលអ្នកស្រាវជ្រាវបានរកឃើញថា មានពិន្ទុមធ្យមភាគតិចជាងគេគឺ ៖ " បានបង្កើតប្រអប់សំបុត្រ តម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ " ទទួលបានពិន្ទុមធ្យមភាគសរុបត្រឹមតែ ៣.៣៥ គឺទទួលបានមធ្យមភាគទាបជាងគេបំផុត តាមលទ្ធផលនេះនាយកសាលារៀនគួរតែយកចិត្តទុកដាក់ លើព័ត៌ មានត្រឡប់ពីអ្នកពាក់ព័ន្ធ រួមមានគ្រូបង្រៀន និងសហគន៍ ។ លោកនាយកត្រូវធ្វើការ

ពិនិត្យឡើងវិញដូចជាព័ត៌ មាន ដែលគ្រូបង្រៀនបានលើកឡើងថា  សិស្សានុសិស្សមួយចំនួនមករៀន មិនទាន់ពេលវេលា ចូលរៀនក្រោយ គ្រូ មានសិស្សអវត្តមានច្រើននៅក្នុងថ្នាក់រៀន និងមានសិស្សមួយចំនួនទៀតបានបោះបង់ការសិក្សា ។ លោកនាយក ក៏ត្រូវយកចិត្តទុកដាក់ផង  ដែរនូវព័ត៌មានត្រឡប់ របស់អាណាព្យាបាលរបស់ សិស្សដែលតែងមើលឃើញថា សិស្សានុសិស្សមួយចំនួន ខ្វះក្រមសីលធម៌ ការប្រើបរាស់ពាក្យសម្តីមិនសមរម្យ មានអាកប្បកិរិយាមិនល្អ មិនសមជាអ្នកទទួលបានការអប់រំល្អពីលោកគ្រូអ្នកគ្រូ ជាដើម ។  ក្រៅពីនេះនាយកសាលារៀនត្រូវត្រួតពិនិត្យឡើងវិញ នូវព័ត៌មានត្រឡប់ផ្សេងទៀតពីមាតាបិតាសិស្ស   ដូចជា   ការផ្តល់ព័ត៌មានពីសាលារៀនជូនដល់សហគមន៍ ឬជូន ដល់មាតាបិតាមានការយឺតយ៉ាវ  ដូចជាព័ត៌មាននៃការចូលរៀនព័ត៌មាននៃការឈប់សម្រាកពីការសិក្សា និង ព័ត៌ពីអវត្តមានកូនៗ  របស់ពួកគាត់មិនបានចូលរៀន   ជាពិសេសព័ត៌មានស្តីពីលទ្ធផលសិក្សារបស់កូនៗ ដែលអាណាព្យាបាលតែងតែទទួល បានព័ត៌មានទាំងនោះមានការយឺតយ៉ាវ    ឬស្ទើរតែមិនទទួលបានពីសាលារៀន  ដូចនេះនាយកសាលារៀនត្រូវគ្រប់គ្រង និងត្រួតពិនិត្យ  ព័ត៌មានត្រឡប់ទាំងនេះឲ្យមានប្រសិទ្ធភាពបន្ថែម ជាពិសេសត្រូវធ្វើការកែប្រែ ចំណុចខ្វះខាតក្នុងការគ្រប់គ្រងរបស់ខ្លួន ដោយព្យាយាមផ្តល់ព័ត៌ មានទាំង ឡាយ ពាក់ព័ន្ធជាមួយមាតាបិតាសិស្សឲ្យបានលឿន តាមដែលអាចធ្វើទៅបាន ដើម្បីបង្កភាពងាយស្រួលក្នុងការ ជួយ សហការណ៍លើការសិក្សារបស់កូនពីសំណាក់អាណាព្យាបាលសិស្ស ឬឪពុកម្តាយសិស្ស  ។ នាយកសាលារៀន ត្រូវយក ចិត្តទុកដាក់ផងដែរអំពីបញ្ហាបរិស្ថានសាលារៀន    គឺនាយកសាលាត្រូវយកចិត្តទុកដាក់បន្ថែមលើការ បង្កើតបន្ទប់ទឹក (បង្គន់អនាម័យ) សម្រាប់សិស្សប្រុស និងសិស្សស្រីដាច់ដោយឡែកពីការ ជាពិសេសត្រូវរៀប ចំវេនសិស្សសម្រាប់សម្អាតបន្ទប់ទឹក ឬបន្ទាប់អនាម័យឲ្យបានស្អាតល្អ ប្រកបដោយផាសុខភាព និងមានទំនុក ចិត្តពីសិស្ស ដោយមិនមានក្តីបារម្ភ ចំពោះការខ្វះខាត ឬពិបាកក្នុងការប្រើបន្ទប់ទឹកឡើយ ។ ចំពោះគោលគំនិត សំខាន់ទី ៣ " ការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន " សម្រាប់គ្រូទទួលពិន្ទុ មធ្យមភាគសរុប Mean = 4.02 កម្រិតខ្ពស់និងសម្រាប់គណៈគ្រប់គ្រងសាលារៀនទទួលបានមធ្យម ភាគពិន្ទុសរុប Mean = 4.28 កម្រិតខ្ពស់ណាស់។ តាមលទ្ធផលនៃពិន្ទុមធ្យមភាគនេះបង្ហាញថាការ

អនុវត្តការងារដឹកនាំ និងគ្រប់គ្រងហិរញ្ញវត្ថុសាលារៀនគឺ លោក នាយកអនុវត្តទទួលបានប្រសិទ្ធភាពល្អ ។ លទ្ធផលល្អនេះផ្ដើមចេញពីលោកនាយកបានរៀបចំផែនការ និងការ អនុវត្តផែនការសកម្មភាពក្នុងការធ្វើចំណាយថវិកាសលារៀនបានល្អ ដោយលោកនាយក  បានរៀបចំផែនការកែលម្អសាលា និងថវិកាសាលារៀន បានល្អ និងអនុវត្តមានប្រសិទ្ធភាព,  នាយកសាលា បានចំណាយថវិកាសាលារៀន ត្រូវតាមខ្ទង់ចំណាយ   ដែលបានកំណត់ទុក   , នាយកសាលា   បានរៀបចំកម្មវិធី ដើម្បីកៀរគមូលនិធិទ្រទ្រង់សាលារៀន ពីសហគមន៍ និងដៃគូរអភិវឌ្ឍន៍នានាបានល្អ , សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន ដោយមានតំណាងសហគមន៍ធ្វើជាអនុប្រធាន ,នាយកសាលារៀនបានបង្កើតការប្រជុំពិភាក្សាជាមួយ គ្រូបង្រៀន មាតាបិតាសិស្សសហគមន៍ អំពី   គណនេយ្យភាព   ក្នុងការចំណាយរបស់សាលារៀនបាន ទៀងទាត់ , នាយកសាលារៀនបានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ ជូនគណៈកម្មការគ្រប់គ្រងសាលារៀន, និងនាយកសាលាបានប្រជុំផ្សព្វផ្សាយពីលទ្ធផលប្រចាំឆ្នាំស្ដីពី  តម្លាភាពការប្រើប្រាស់ថវិកាសាលារៀនជូនអ្នកពាក់ព័ន្ធ មានគ្រូបង្រៀន      និងសហគមន៍     បានញឹកញាប់   ។  តាមលទ្ធផលនៃមធ្យមភាគដែលទទួលបានអ្នក ស្រាវជ្រាវបានរកឃើញថា នាយកសាលានៅមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង គឺអនុវត្ត ការងារដឹកនាំ និងគ្រប់គ្រងថវិកាសាលារៀនទទួលបានប្រសិទ្ធភាពល្អ ជាគំរូល្អសម្រាប់នាយកសាលារៀនផ្សេងៗ ទៀតអនុវត្តតាមនូវចំណុចល្អទាំងនោះនៅក្នុងអង្គភាពរបស់ខ្លួនដើម្បីពង្រឹង   ការប្រើប្រាស់ហិរញ្ញវត្ថុសាលារៀន បានល្អ ក៏ដូចជាព្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ចំពោះគោលកគំនិតសំខាន់ទី ៤ ‟ ការគ្រប់គ្រងធនធានមនុស្ស ″    សម្រាប់គ្រូទទួលពិន្ទុ    មធ្យមភាគសរុប   Mean = 4.07 កម្រិតខ្ពស់  និងសម្រាប់គណៈគ្រប់គ្រងសាលារៀនទទួលបានមធ្យម ភាគពិន្ទុសរុប Mean = 4.00 កម្រិតខ្ពស់ ។ តាមលទ្ធផលនៃមធ្យមភាគនេះបង្ហាញថាការគ្រប់គ្រងធនធានមនុស្សរបស់នាយកសាលារៀន  នៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកស្វាយជ្រំ  ខេត្តស្វាយរៀង អនុវត្តន៍ការគ្រប់គ្រងធនធានមនុស្សមានប្រសិទ្ធភាពល្អ    បើធៀបជាមួយការដឹកនាំ  និងគ្រប់គ្រងផ្អែកលើលទ្ធផល ។  លទ្ធផលល្អនេះដោយហេតុផលថា លោកនាយកបានរៀបចំផែនការ

ច្បាស់ លាស់ និងបានអនុវត្តផែនការទាំងនោះបានល្អ ដោយនាយកសាលា បានបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈគ្រូ និងបុគ្គលិកស្របតាមលទ្ធផលរំពឹងទុក , នាយកសាលា ផ្តល់ឱកាសដល់គ្រូ ដើម្បីបង្កើត និងពិសោធន៍ជាមួយវិធីសាស្ត្រថ្មីៗដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស ធ្វើឲ្យសិស្សងាយយល់  ព្រមទាំងគ្រូងាយស្រួលក្នុងការ បង្រៀន ,  នាយកសាលាបានផ្តល់ឪកាសជូនគ្រូមានសមត្ថភាពអាចសម្រេចចិត្តលើដំណើរការបង្រៀន និងស្វ័យភាពផ្ទាល់ខ្លួន , នាយកសាលា បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន និងបុគ្គលិកដែលមាន ស្នាដៃល្អ  ឬជាបុគ្គលិកដែលសកម្មក្នុងការងាររបស់អង្គភាព , នាយកសាលា វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ ដោយតម្លាភាពដោយមិនលម្អៀង មិនរើសអើងចំពោះបុគ្គលិក មិនប្រកាន់បក្សពួក , ការរៀបចំផែនការ  និង ការអនុវត្តសកម្មភាពខាងលើនេះបានល្អ   ជាប្រភពដែលធ្វើឲ្យ  ការគ្រប់គ្រងធនធានមនុស្សរបស់នាយកសាលា រៀននៅមធ្យមសិក្សាទុតិភូមិ មានប្រសិទ្ធភាពល្អគួរជាទីចាប់អារម្មណ៏ និងអាចចាត់ទុកថាជាបទពិសោធន៍ល្អ ជា គំរូ ដ៏ល្អរបស់នាយកសាលារៀនផ្សេងទៀតអនុវត្តន៍តាមរបៀបនៃការគ្រប់គ្រងធនធានមនុស្សក្នុង ស្រុកស្វាយជ្រំ  ខេត្តស្វាយរៀង ដើម្បីពង្រឹងគុណភាពអប់រំក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

**តារាងទិន្នន័យលទ្ធផលមធ្យមភាគរួមសរុប គ្រូ និងគណៈគ្រប់គ្រង**

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ សរុបគ្រូ | ប្រែប្រួល | កម្រិត | មធ្យមភាគសរុប គណៈគ្រប់គ្រង | ប្រែប្រួល | កម្រិត |
| ១ | ការគ្រប់គ្រងការបង្រៀន និងរៀន | 4.27 | 0.71 | ខ្ពស់ណាស់ | 4.10 | 0.56 | ខ្ពស់ |
| ២ | ការគ្រប់គ្រងរដ្ឋបាលសាលារៀន | 3.92 | 0.69 | ខ្ពស់ | 4.10 | 0.56 | ខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ការគ្រប់គ្រងហិរញ្ញវត្ថុ | 4.02 | 0.69 | ខ្ពស់ | 4.28 | 0.59 | ខ្ពស់ណាស់ |
| ៤ | ការគ្រប់គ្រងធនធានមនុស្ស | 4.07 | 0.82 | ខ្ពស់ | 4.00 | 0.74 | ខ្ពស់ |

តាមតារាង ៤.២.៦ បង្ហាញថាពិន្ទុមធ្យមភាគសរុបនៃការដឹកនាំ និងគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល អ្នកស្រាវជ្រាវរកឃើញថា ការគ្រប់គ្រងរដ្ឋបាលទទួលបានពិន្ទុមធ្យមភាគសរុបទាបជាងគេគឺ ៣.៩២(កម្រិតខ្ពស់) ។ អ្នកស្រាវជ្រាវ បានរកឃើញបន្ថែមទៀតថា សូចនាករក្នុងដំណើរការ ការដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលាមានពីដែលទទួល បាន ពិន្ទុ មធ្យមភាគទាបជាងគេគឺ " នាយកសាលាធានាប្រាកដថា គោលដៅសិក្សាអាចអនុវត្តបានងាយស្រួលចំពោះគ្រូ នៅ ក្នុងវត្ថុបំណងថ្នាក់រៀន " ទទួលបានមធ្យមភាគពីគ្រូបានត្រឹមតែ ៣.៨៧ និង ទទួលបានពីគណៈគ្រប់ គ្រងទទួលបានត្រឹមតែ ៣.៨០ តែ ប៉ុណ្ណោះ ។ ដោយឡែកសូចនាករ " បានបង្កើតប្រអប់សំបុត្រតម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកាពាក់ ព័ន្ធ " ទទួលបានមធ្យមភាគពីគ្រូបានត្រឹមតែ ៣.៣៥ និង ទទួលបានមធ្យមភាគពីគណៈគ្រ់គ្រងសាលារៀនត្រឹម តែ ៣.៨០ ។

ដូចនេះសរុបជារួមមកដើម្បីធ្វើឲ្យការគ្រប់គ្រងរដ្ឋបាលរបស់នាយកសាលាទទួលបានប្រសិទ្ធភាពដូចទៅនឹង ការគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល (SBM) អ្នកស្រាវជ្រាវបានរកឃើញនូវ ចំណុចខ្វះខាតពីរសំខាន់របស់ នាយកសាលារៀន ដែលត្រូវពង្រឹងបន្ថែមគឺត្រូវះ

- ផ្តល់កិច្ចគាំទ្រដល់ដំណើរការបង្រៀន និងរៀន ។ នាយកសាលាត្រូវសម្រួលដល់ដំណើរការបង្រៀន និងរៀនរបស់គ្រូ ដូចជាធានាឲ្យប្រាកដថាថ្នាក់រៀនអាចដំណើរការបង្រៀនបានរាល់ពេលដល់ ម៉ោងសិក្សា ដូចជា បន្ទប់រៀនមិនជាប់សោរ មានដីស ហ្វឺត ធុងទឹកលាងដៃ សម្ភារផ្សេងទៀត(ឧបករណ៍បច្ចេកវិទ្យា LCD បើអាច) សម្រួលដល់ដំណើរការបង្រៀន នៅក្នុងថ្នាក់ បរិស្ថានថ្នាក់រៀនស្អាតមានអនាម័យ ...។ តាមសៀវភៅ" ផែនទីបង្ហាញផ្លូវ ការតម្រង់ទិសនៅកម្ពុជា ក្នុងឆ្នាំ ២០៣០ " បានកំណត់ចក្ខុវិស័យសាលារៀននៅកម្ពុជា នៅឆ្នាំ២០៣០ថា " សាលារៀនគឺជាគ្រឹះស្ថានសិក្សាដែលធានាបាននូវ ការអប់រំប្រែកបដោយគុណភាពខ្ពស់ សម្រាប់

ទាំងអស់គ្នា ″ ដើម្បី សម្រេចតបតាម ចក្ខុវិស័យដែលក្រសួងអប់រំកម្ពុជាបានកំណត់នេះ នាយកសាលារៀន ត្រូវពង្រឹងបន្ថែម លើការគ្រប់គ្រងសាលារៀន ជាពិសេសការគ្រប់គ្រងរដ្ឋបាល ដោយផ្តោតសំខាន់ចំពោះការផ្តល់កិច្ចគាំទ្រដល់ណើរការបង្រៀន និងរៀន ។ ដូចនេះនាយកសាលារៀនត្រូវរៀបចំផែនការ និងអនុវត្តន៍ផែនការទាំងឡាយណាដែលគាំទ្រដល់កិច្ចគាំទ្រ ដល់ការបង្រៀនឲ្យបានកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតលើ កិច្ចគាំទ្រដល់ដំណើរការបង្រៀន និងរៀនជូនដល់គ្រូ បើធៀបជាមួយ ការដឹកនាំ និងគ្រប់គ្រងបែបស្តង់ដាផ្អែកលើកលទ្ធផល (SBM) ។

- ការទទួលយកព័ត៌មានត្រឡប់របស់អ្នកពាក់ព័ន្ធរួមមាន គ្រូបង្រៀន និងមាតាបិតាសិស្ស ឬសហគមន៍លើដំណើការដឹកនាំ និងគ្រប់គ្រងរបស់នាយក ។ នាយកសាលារៀនត្រូវប្រាកដថាបានទទួលព័ត៌មានពិតពីអ្នកពាក់ព័ន្ធ(គ្រូ ,សហគមន៍)ដែលបានវាយតម្លៃលើ ដំណើរ ការដឹកនាំ និងគ្រប់គ្រងសាលារៀន ដែលព័ត៌មានទាំងនោះរួមមាន៖ គ្រូបង្រៀនអាចមើលឃើញថា សិស្សមួយចំនួនមិនគោរពវិន័យសាលារៀន ,មានសិស្សមួយចំនួនខ្វះវិន័យ ពេលកំពុងបង្រៀន និងរៀន,មានសិស្សមួយចំនួនទៀតមករៀនយឺត និងចូលរៀនយឺត, សិស្សានុសិស្សមិនបានជួយសម្អាតបន្ទប់រៀន និងបរិស្ថានសាលារៀន ជាដើម ។ ដោយឡែកសហគមន៍ ឬ មាតាបិតាអាណាព្យាបាលសិស្ស សង្កេតឃើញថាមាន សិស្សមួយចំនួនខ្វះក្រមសីលធម៌រស់នៅ ទាំងពាក្យសម្តី និងកាសម្តែងចេញ នូវ ឥរិយាបថនានា , មាតាបិតាសិស្សភាគច្រើនមិនបានទទួលព័ត៌ មានច្បាស់លាស់ពីថ្ងៃចូលរៀន ឬថ្ងៃឈប់សម្រាក , កូនរៀនខ្សោយទទួលបានចំណាត់ថ្នាក់ទាប ឬ ប្រឡងធ្លាក់ , បរិស្ថានសាលារៀនមិនល្អ បន្ទប់ទឹកគ្មាននាម័យជាដើម ។ ដូចនេះនាយកសាលារៀនត្រូវតែរៀបចំផែនការ ក្នុងការចុះប្រមូលព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ តាមរយៈការបង្កើតអង្គប្រជុំពិភាក្សាបញ្ហាប្រឈមជាមួយអ្នកពាក់ព័ន្ធមានគ្រូបង្រៀននិងសហគមន៍ដើម្បីទទួលបានព័ត៌មានត្រឡប់មកវិញនូវបញ្ហាប្រឈមទាំងឡាយ និងត្រូវរៀបចំផែនការអនុវត្ត ព្រមទាំងដោះស្រាយនូវរាល់ចំណុចខ្វះខាតទាំងនោះឲ្យបានល្អប្រសើរបើធៀបជាមួយការដឹកនាំ និងគ្រប់គ្រងបែបស្តង់ដាផ្អែកលើលទ្ធផល (SBM) ។ ដូចគ្នាផងដែរជាមួយលទ្ធផលដែលអ្នកស្រាវជ្រាវបានឃើញនេះនាយកសាលា រៀនត្រូវ

ពង្រឹងសកម្មភាពនៃការគ្រប់គ្រងរដ្ឋបាលសាលា ឲ្យកាន់តែទទួលបានលទ្ធផលល្អ ដោយផ្តោតលើខ្លឹមសារនៃការដឹកនាំ និងគ្រប់គ្រងរដ្ឋបាលសាលារៀនស្តង់ដាផ្អែកលើលទ្ធផល ជាគោល និងស្របទៅតាមការកំ ណត់ជាយុទ្ធសាស្ត្រអប់រំរបស់ក្រសួងអប់រំ ដែលលើកឡើង ក្នុងសៀវភៅយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ បានលើកឡើងពីកំណែទម្រង់ ការគ្រប់គ្រងរដ្ឋបាល គឺយុទ្ធសាស្ត្ររងទី២ គឺការអនុវត្តការគ្រប់គ្រងរដ្ឋបាលតាមសាលារៀនគឺ ″ បង្កើនការគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាល លើកកម្ពស់ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យា ដើម្បីបង្កើន យុទ្ធសាស្ត្រសម្រាប់ជៀសវាង ការគំរាមកំហែង និងពង្រឹងភាពខ្លាំង នៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមាន គុណភាពនៅកម្រិតថ្នាក់ជាតិ ″ ។( យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ២០១៨-២០២៣) ។

## ៤.៣ បញ្ហាប្រឈមក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនរបស់នាយកសាលា

ពាក្យថាភាពជាអ្នកដឹកនាំ និងគ្រប់គ្រងល្អ ជាពាក្យសាមញ្ញមួយដែលមនុស្សគ្រប់គ្នាបាននិយាយ និងលើកឡើងថាមានភាពងាយស្រួល ប៉ុន្តែការអនុវត្តរបស់អ្នកគ្រប់គ្រងផ្ទាល់ពិតជាការងារដ៏លំបាក និងមានភាពស្មុគស្មាញជាច្រើន ដែលត្រូវជួបប្រទះក្នុងការអនុវត្តប្រចាំថ្ងៃ ។ ដូចគ្នាផងដែរការគ្រប់គ្រង សាលារៀនរបស់នាយកសាលាតែងតែជួបបញ្ហាប្រឈមក្នុងការអនុវត្ត គ្រាន់តែតាមស្ថានភាពជាក់ស្តែងថា បញ្ហាប្រឈមខ្លះ ធំពិបាកក្នុងការរកដំណោះស្រាយ ហើយបញ្ហាប្រឈមខ្លះទៀតមានតិចតួចងាយស្រួលក្នុង ការសម្របសម្រួល និង ងាយស្រួលក្នុងការរកដំណោះស្រាយជាង ។ ខាងក្រោមនេះអ្នកស្រាវជ្រាវ នឹង សិក្សាស្រាវជ្រាវ ព្រមទាំងបង្ហាញពីបញ្ហាប្រឈម របស់នាយកសាលារៀននៅមធ្យមសិក្សាទុតិយភូមិ ធៀបជាមួយការគ្រប់គ្រងស្តង់ដាផ្អែកលើលទ្ធផល ដែលជាសំណួរស្រាវជ្រាវទីពីរតម្រូវឲ្យអ្នកស្រាវជ្រាវយកមកសិក្សា ដូចខាងក្រោម ៖

អ្នកស្រាវជ្រាវបានកំណត់សំណួរស្រាវជ្រាវទិ២មានខ្លឹមសារថា″តើការដឹកនាំនិងគ្រប់គ្រង របស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានជួបបញ្ហាប្រឈមអ្វីខ្លះ ?″

ផ្អែកទៅលើសំណួរស្រាវជ្រាវទី២ នេះអ្នកស្រាវជ្រាវបានកំណត់កម្រិតនៃការចង្អុលបង្ហាញ នៃតម្លៃមធ្យមជាប្រាំកម្រិតដូចគ្នាទៅនឹងការកំណត់ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរទីមួយដែរ គឺះ ១) កម្រិតខ្សោយមានមធ្យមភាគ ចន្លោះពី ១-១.៨០ ២)កម្រិតមធ្យមមានមធ្យមភាគចន្លោះពី១.៨១-២.៦០ ៣) កម្រិតល្អបង្គួរមានមធ្យមភាគ ចន្លោះពី ២.៦១-៣.៤០ ៤)កម្រិតខ្ពស់មានមធ្យមភាគចន្លោះពី ៣.៤១-៤.២០ និង ៥) កម្រិត ខ្ពស់ណាស់ មានមធ្យមភាគចន្លោះ ពី ៤.២១-៥.00 ។អ្នកស្រាវជ្រាវបានធ្វើការវាយតម្លៃលើបញ្ហាប្រឈម តាមរបៀបដូចខាងក្រោម ៖

### ៤.៣.១ សំណួរស្រាវជ្រាវទី២ បញ្ហាប្រឈម

**តារាង៤.៣.១ ទិន្នន័យបញ្ហាប្រឈមរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិក្នុងការអនុវត្តការគ្រប់គ្រង**

| ល.រ | បញ្ហាប្រឈមរបស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគ | គម្លាតគំរូ | កម្រិត | មធ្យមភាគ | គម្លាតគំរូ | កម្រិត |
| ១ | ការបង្រៀន និងរៀនរបស់គ្រូមិនទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ | 3.24 | 1.00 | បង្គួរ | 3.10 | 0.99 | បង្គួរ |
| ២ | ការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូមិនទាន់បានគ្រប់មុខវិជ្ជា | 2.89 | 1.03 | បង្គួរ | 2.90 | 0.99 | បង្គួរ |
| ៣ | មានការបែងចែក ក្រុមការងារ និងរើសអើងរបស់បុគ្គលិកក្នុងសាលារៀន | 2.25 | 0.90 | មធ្យម | 2.40 | 0.84 | មធ្យម |
| ៤ | គ្រូបង្រៀនអវត្តមានច្រើនពេលមានការប្រជុំបច្ចេកទេស និងការប្រជុំនានា | 2.85 | 1.27 | បង្គួរ | 2.80 | 1.03 | បង្គួរ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | គ្រូបង្រៀនខ្វះការសហការក្នុងការអនុវត្តការងារប្រចាំថ្ងៃ | 2.62 | 1.10 | បង្គួរ | 2.40 | 0.84 | មធ្យម |
| ៦ | សាលារៀនខ្វះមន្ត្រីជំនាញក្នុងការរៀបចំផែនការប្រចាំឆ្នាំ | 2.73 | 1.08 | បង្គួរ | 2.80 | 1.03 | បង្គួរ |
| ៧ | សិស្សមករៀន មិនបានទៀងទាត់ និងមានសិស្សរៀនយឺតច្រើន | 3.07 | 1.14 | បង្គួរ | 2.80 | 1.03 | បង្គួរ |
| 8 | ចំណេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត | 3.22 | 1.13 | បង្គួរ | 3.30 | 0.95 | បង្គួរ |
| 9 | ការចូលរួមរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមានកម្រិតទាបនៅឡើយ | 3.20 | 1.10 | បង្គួរ | 3.20 | 1.03 | បង្គួរ |
| 10 | ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ | 3.55 | 0.88 | ខ្ពស់ | 3.60 | 0.84 | ខ្ពស់ |
| 11 | មានទំនាស់ផលប្រយោជន៍ការងាររបស់គ្រូកើតមានឡើងនៅក្នុងអង្គភាព | 2.42 | 1.15 | មធ្យម | 1.90 | 0.57 | មធ្យម |
| មធ្យមភាគសរុប | | 2.91 | 1.13 | បង្គួរ | 2.84 | 1.00 | បង្គួរ |

តាមតារាង៤.៣.១ ទិន្នន័យដែលទទួលបាន ពីគ្រូបង្រៀនបង្ហាញថា បញ្ហាប្រឈម ក្នុងការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺទទួល មធ្យម

ភាគសរុប ២.៩១ (កម្រិតបង្គួរ) ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺ " ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ " ទទួលបានពិន្ទុមធ្យមភាគ ៣.៥៥ (កម្រិតខ្ពស់) ។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " មានការបែងចែក ក្រុមការងារ និងរើសអើង  របស់បុគ្គលិកក្នុងសាលារៀន  " ពិន្ទុមធ្យមភាគ ២.២៥ (កម្រិតមធ្យម)  ។

ទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបង្ហាញថា   បញ្ហាប្រឈមក្នុងការបំពេញការងារដឹកនាំ និងគ្រប់គ្រងឆ្លើយតបស្តង់ដារការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)ទទួល បានមធ្យមភាគពិន្ទុសរុប ២.៨៤  (កម្រិតបង្គួរ)  ។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ "ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ ″  មានពិន្ទុមធ្យមភាគ ៣.៦០  (កម្រិតខ្ពស់) និងសូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ " មានទំនាស់ផលប្រយោជន៍ការងាររបស់គ្រូ  កើតមានឡើងនៅក្នុងអង្គភាព ″ ទទួលបានពិន្ទុ មធ្យមភាគសរុប១.៩០(កម្រិតមធ្យម)។

## ៤.៣.២ ការពិភាក្សាលើកម្រងសំណួរទី២

តាមលទ្ធនៃការស្រាវជ្រាវនៃសំណួរស្រាវជ្រាវទី២ បញ្ហាប្រឈមរបស់នាយកសាលា  ឃើញថាការអនុវត្តការដឹកនាំ និង គ្រប់គ្រង របស់នាយកយកនៅមធ្យមសិក្សាទុតិយភូមិ នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ធៀបជាមួយការដឹកនាំ   និងគ្រប់គ្រងស្តង់ដារផ្អែកលើលទ្ធផល   (SBM)  អ្នកស្រាវជ្រាវបានរកឃើញមានបញ្ហាប្រឈមបីដែល ទទួលបានមធ្យមភាគខ្ពស់ជាងគេ គឺ៖

១)  ការចូលរួមរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមានកម្រិតទាបនៅឡើយ ។ ដោយផ្អែកលើលទ្ធផលស្រាវជ្រាវនេះនាយកសាលាត្រូវផ្សព្វផ្សាយពីផែនការសាលារៀន ជូនដល់សហគមន៍ និងបន្តលើកទឹកចិត្តឲ្យ  សហគមន៍ចូលរួម ប្រកបដោយតម្លាភាព , នាយកសាលាត្រូវអញ្ជើញសហគមន៍ចូលរួមស្តីពីការប្រជុំផ្សព្វផ្សាយ របាយការណ៍ផលសម្រេចប្រចាំឆ្នាំរបស់សាលារៀន ជូនដល់សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត , រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយមាតាបិតាសិស្ស  និងចុះតាមខ្នងផ្ទះដើម្បីផ្តល់ព័ត៌មាន

ស្តីពី ការអប់រំ និងទទួលព័ត៌មានត្រឡប់ពីមាតាបិតាសិស្សមកវិញ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣) ។

២) ចំណេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត ។ តបតាមលទ្ធផល នៃការស្រាវជ្រាវនេះ នាយកសាលាត្រូវធ្វើសុពលភាពឯកសារបណ្តុះបណ្តាល ផ្តោតលើវិធីសាស្ត្រ និងការបណ្តុះបណ្តាលរបស់គ្រូ , នាយកសាលាត្រូវរៀបចំកម្មវិធីចែករំលែកបទពិសោធន៍ និងនវានុវត្តន៍ពីបុគ្គលឹកអប់រំឆ្នើម , នាយកសាលាត្រូវរៀបចំថវិកាគាំទ្រ (INSET/ONSET) និងបញ្ចូលនៅក្នុងថវិកាដំណើរការ សាលារៀន ,និង នាយកសាលាត្រូវលើកកម្ពស់វប្បធម៌នៃការចែករំលែកឧត្តមានុវត្តន៍ជាមួយគ្រូបង្រៀនទាំងអស់ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣) ។

៣)ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ ។ ដូចនេះនាយកដ្ឋានសវនកម្មត្រូវចុះធ្វើវនកម្មសាលារៀនឲ្យបានទៀងទាត់ ដើម្បីធានាថាធនធានថវិកា សាលាតម្រូវបានប្រើប្រាស់ប្រកបដោយតម្លាភាព , ក្រសួងត្រូវពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកាសាលារៀន , នាយកសាលាត្រូវរៀបចំកម្មវិធីកៀរគចំណូលសាលារៀនពីសហគមន៍ , នាយកសាលាស្នើសុំថវិកាអភិវឌ្ឍន៏សាលារៀនបន្ថែម តាមផែនការចំណាយរបស់សាលា ( ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣) ។

ជាការឆ្លើយតបជាមួយលទ្ធផលនៃបញ្ហាប្រឈមរបស់ នាយកសាលារៀនធៀបជាមួយការដឹកនាំ និងគ្រប់គ្រងរបស់ ស្តង់ដាផ្អែកលើលទ្ធផល នាយកសាលារៀនត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតលើការដឹក នាំ និងគ្រប់គ្រងដោយផ្តោតសំខាន់លើ បីចំណុចបន្ថែមទៀតដែលជាសូចនាករទទួលបានពិន្ទុមធ្យមទាបជាងគេគឺ ៖ " ការចូលរួមរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមាន កម្រិតទាបនៅឡើយ " , " ចំណេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត " និង " ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ " ដោយ នាយកសាលារៀនត្រូវរៀបចំផែនការ និង

អនុវត្តផែនការដែលពាក់ព័ន្ធ ឲ្យកាន់តែមានប្រសិទ្ធភាព ល្អបន្ថែម ។ ក្រៅពីនេះនាយកសាលារៀនត្រូវទទួលយក ព័ត៌មានត្រឡប់ពីបណ្ដាលអ្នកពាក់ព័ន្ធ មានគ្រូបង្រៀន និងសហគមន៍ស្ដីពីចំណុចខ្វះខាតលើដំណើរការអនុវត្តការងារដឹកនាំ និងគ្រប់គ្រងរបស់ខ្លួន ដោយទទួលព័ត៌មានពិត មានប្រសិទ្ធភាព និងចេះកែលម្អចំណុចខ្វះខាតលើដំណើរការគ្រប់គ្រងរបស់ខ្លួនឲ្យបានកាន់តែប្រសើជាងមុនបន្ថែមទៀត ។

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន និងសូមណូមពរ

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន និងសូមណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង" គឺមាន គោលបំណងពីរគឺ ៖១) សិក្សាពីរការអនុវត្តលើដំណើរការបំពេញការងាររបស់នាយក មធ្យមសិក្សាទុតិយភូមិ ធៀបជាមួយការឆ្លើយតបស្តង់ដាការគ្រប់គ្រងសាលារៀន ដោយផ្អែកលើលទ្ធផល (SBM) នៅក្នុងស្រុកស្វាយ ជ្រំ ខេត្តស្វាយរៀង ២) សិក្សាស្វែងយល់ពីបញ្ហាប្រឈម នៃការដឹកនាំ និងគ្រប់គ្រង របស់នាយកសាលាមធ្យម សិក្សាទុតិយភូមិក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ គឺប្រើប្រាស់បរិមាណវិស័ យ ក្នុងការប្រមូលទិន្នន័យពីគ្រូចំនួន ៥៥នាក់ គណៈគ្រប់គ្រង៦នាក់ និងបុគ្គលិករដ្ឋបាល៤នាក់ ដើម្បីរកមធ្យម ភាគពិន្ទុ និងគម្លាតស្តង់ដា។ ជាលទ្ធផលលើសំណួរស្រាវជ្រាវទី១ គឺទទួលបានពីការវិភាគទិន្នន័យរកតម្លៃមធ្យម ភាគ គឺ ការគ្រប់គ្រងការបង្រៀន និងរៀន ទទួលបានមធ្យមភាគពីគ្រូ ៤.២៧ និងគម្លាតស្តង់ដា ០.៧១ កម្រិត

ល្អណាស់ និងពីគណៈ គ្រប់គ្រង ៤.១០ កម្លាតស្តង់ដា ០.៥៦ កម្រិតខ្ពស់ ។ ការគ្រប់គ្រងរដ្ឋបាល ទទួលបានពិន្ទុ មធ្យម ភាគ សរុប ពីគ្រូ ៣.៩២ គម្លាតសតង់ដា ០.៦៩ កម្រិតខ្ពស់ និងពីគណៈគ្របគ្រង ៤.១០ និងគម្លាតស្តងដា ០.៥៦ កម្រិត ខ្ពស់ ។ ការ គ្រប់គ្រងហិរញ្ញវត្ថុ ទទួលបានមធ្យមភាគពីគ្រូ ៤.០២ និងគម្លាតស្តង់ដា ០.៦៩ កម្រិតខ្ពស់ និង ពីគណៈគ្រប់គ្រង ៤.១០ កម្លាតស្តង់ដា ០.៥៦ កម្រិតល្អណាស់ ។ ការគ្រប់គ្រងធនធានមនុស្ស ទទួលបានពិន្ទុមធ្យមភាគសរុបពីគ្រូ ៤.០៧ គម្លាតស្តងដា ០.៨២ កម្រិតខ្ពស់ និងពីគណៈគ្រប់គ្រង ៤.00 កម្រិតខ្ពស់ ។

ក្នុងនោះ ការអនុវត្តលើដំណើរការដឹកនាំគ្រប់គ្រង របស់បស់នាយកសាលានៅមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានល្អ លើចំណុច ការគ្រប់គ្រងការបង្រៀន និងរៀន, ការគ្រប់គ្រងហិរញ្ញវត្ថុ, ការគ្រប់គ្រងធនធានមនុស្ស និងត្រូវពង្រឹងបន្ថែម ទៅលើការគ្រប់គ្រង រដ្ឋបាលសាលារៀន ដោយសារតែការគ្រប់គ្រងរដ្ឋបាលទទួលបានមធ្យមភាគពិន្ទុទាបជាងគេ ដូចនេះនាយកសាលាត្រូវពង្រឹងការគ្រប់គ្រងរដ្ឋបាលបន្ថែមទៀត លើការកំណត់វត្ថុបំណងថ្នាក់រៀនរបស់គ្រូ ឲ្យស្របតាមគោលដៅសិក្សា ដោយនាយកត្រូវតែផ្តល់កិច្ចគាំទ្រលើដំណើរ ការបង្រៀន និងរៀនរបស់គ្រូឲ្យបានល្អជាបរចាំ នូវអ្វីដែលគ្រូបង្រៀនត្រូវការពីនាយកលើដំណើរការបង្រៀន និងរៀន ។ លទ្ធផលសំណួរស្រាវជ្រាវទី២ តាមលទ្ធផលបានបង្ហាញថាបញ្ហាប្រឈមដែលនាយកសាលានៅមធ្យមសិក្សាទុតិយភូមិក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀងជួបប្រទះសំខាន់ជាងគេមានបីគឺ " ចំនេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានក្រិត " ទទួលបានពិន្ទុមធ្យមភាគសរុបពីគ្រូ ៣.២២ គម្លាតស្តង់ដា ១.១៣ កម្រិតបង្គួរ និងពីគណៈគ្រប់គ្រងទទួលបាន ៣.៣០ គម្លាតស្តងដា ០.៩៥ កម្រិតបង្គួរ ។ " ការចូលរួមរបស់ សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមានកម្រិតទាបនៅឡើយ " ទទួបានពិន្ទុមធ្យមភាគ សរុបពីគ្រូ ៣.២០ គម្លាតស្តង់ដា ១.១០ កម្រិតបង្គួរ និងពីគណៈគ្រប់គ្រងទទួលបាន ៣.២០ គម្លាតស្តងដា ១.០៣ កម្រិតបង្គួរ ។ " ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាមានកម្រិតទាបប្រៀបធៀបជាមួយចំនាយ " ទទួបានពិន្ទុមធ្យមភាគសរុបពីគ្រូ ៣.៥៥ គម្លាតស្តង់ដា ០.៨៨ កម្រិតខ្ពស់ និងពីគណៈគ្រប់គ្រងទទួល

បាន ៣.៦០ គម្លាតស្តងដា ០.៨៤ កម្រិតខ្ពស់ ។ ក្នុងន័យនេះនាយកសាលារៀនត្រូវបង្កើតកម្មវិធីបណ្តុះបណ្តាលចំ ណេះដឹងផ្នែកការប្រើប្រាស់បច្ចេកវិទ្យា ជូនគ្រូបង្រៀនបន្ថែម លើកទឹកចិត្តដល់បុគ្គលិកក្នុងការចែករំលែកចំណេះដឹងផ្នែកបច្ចេកវិទ្យា , បន្តផ្សព្វផ្សាយ និងលើកទឹកចិត្តដល់សហគមន៍ ស្តីពីការដឹកនាំ និងគ្រប់គ្រងសាលារៀន ឲ្យបានទូលំទូលាយ ច្បាស់លាស់ ញឹកញាប់ជូនដល់សហគមន៍ , នាយកសាលារៀនត្រូវរៀបចំ និងអនុវត្តផែនការកៀរគរ ចំណូលថវិកាជូនសាលារៀន និងលើកទឹកចិត្តដល់សហគមន៍ជួយគាំទ្រ ផ្តល់ថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀនឲ្យបានកាន់តែច្រើន តាមដែលអាចធ្វើទៅបាន ។

## ៥.២ សំណូមពរ

### ក្រសួងអប់រំ យុវជន និងកីឡា

- បន្តបើកវគ្គបំប៉នផ្នែកជំនាញគ្រប់គ្រង និងផ្នែកជំនាញរៀបចំផែនការជូនដល់គណៈគ្រប់គ្រងសាលាឲ្យបានញឹកញាប់ ជាពិសេសគឺជំនាញគ្រប់គ្រងរដ្ឋបាល ។
- ពង្រឹងគោលការណ៍ផ្ទៃក្នុង នឹងផ្ទៃក្រៅបន្ថែមទៀតឲ្យបានច្បាស់លាស់ ។
- រៀបចំសិក្ខាសិលា បង្កើនសមត្ថភាពគ្រូជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យា និងបង្កើនគ្រូជំនាញព័ត៌មានវិទ្យានៅតាមសាលារៀន ។
- បង្កើនសមត្ថភាពនាយកសាលារៀន តាមរយៈការកំណត់គុណវុឌ្ឍិរបស់នាយក នៅមធ្យមសិក្សាទុតិយភូមិយ៉ាងទាបបំផុតត្រូវមានសញ្ញាបត្រ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់លើជំនាញគ្រប់គ្រងអប់រំ ។

ក្រសួងអប់រំ យុវជន និងកីឡា ជួយបង្កើនចំណូលថវិកា ប្រចាំឆ្នាំន្ថែមជូនដល់គ្រប់សាលារៀនបន្ថែមទៀត ដើម្បីបង្កើនការអភិវឌ្ឍតាមសាលារៀនកាន់តែប្រសើរ ។

### មន្ទីរអប់រំ យុវជន នងកីឡា ខេត្ត និង ការិយាល័យអប់រំ យុវជន និង កីឡាស្រុក

- បន្តបង្កើតកម្មវិធីបណ្តុះបណ្តាល ,លើកទឹកចិត្ត , និងចែករំលែកបទពិសោធន៍ លើការគ្រប់គ្រងរដ្ឋបាលសាលារៀន ជូនដល់នាយកសាលា ។
- ធ្វើការវាយតម្លៃការធ្វើអធិការកិច្ចផ្ទៃក្នុង និងរកឲ្យឃើញនូវចំណុចខ្វះខាតដើម្បីកែលម្អឲ្យបានទាន់ពេលវេលា លើដំណើការដឹកនាំគ្រប់គ្រងរបស់នាយកសាលា ជាពិសេសការគ្រប់គ្រងរដ្ឋបាល ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

## សាលារៀន

- នាយកសាលាត្រូវពង្រឹងការគ្រប់គ្រងរដ្ឋបាលសាលារៀនបន្ថែមទៀត
- នាយកសាលាត្រូវបង្កើតកម្មវិធីបណ្តុះបណ្តាល និងលើទឹកចិត្តការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា( TCT ) ដល់គ្រូបង្រៀនឲ្យបានញឹកញាប់
- នាយកសាលត្រូវរៀបចំផែនការ និងអនុវត្តផែនការកម្មវិធីកៀរគរ ចំណូលថវិកាពីអ្នកពាក់ព័ន្ធបន្ថែមពិសេស ពីសហគមន៍ ។

## សម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត

- ត្រូវពង្រីកសំណាកបន្ថែមឲ្យបានកាន់តែច្រើន
- បង្កើនចំនួនសាលាដែលត្រូវសិក្សាស្រាវជ្រាវ ឲ្យបានច្រើនទូទាំងខេត្តស្វាយរៀង ឬទូទាំងប្រទេសកម្ពុជា
- បង្កើននូវឧបករណ៍ស្រាវជ្រាវឲ្យបានកាន់តែច្រើនជាងនេះ

# ឯកសារយោង

ក្រសួងអប់រំយុជន និង កីឡា(២០១៩), ឯកសារស្តីពី យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ

២០១៨ -២០២៣.រាជធានីភ្នំពេញ: ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៧) , បទបង្ហាញស្តីពីការគ្រប់គ្រងតាមសាលារៀន (School Bassed Management – SBM) បង្ហាញដោយលោក ព្រីង មរកត ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះ ទូទៅវិទ្យាស្ថាន:បច្ចេកវិទ្យាកម្ពុជា (ថ្ងៃទី២៥-២៧ ខែមិនា ឆ្នាំ២០២៩) ។

ក្រសួងអប់រំយុវជន និងកីឡា (២០១៧), ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (,ឯកសារប្រតិបត្តិ ការ

គ្រប់គ្រងថវិកាសាលារៀន ) រាជធានីភ្នំពេញ: ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩). ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២ រាជធានីភ្នំពេញ:

ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩), របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ: រាជធានីភ្នំពេញ: ក្រសួងអប់រំ

យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដានាយកសាលារៀន (២០១៧). រាជធានីភ្នំពេញ: ក្រសួងអប់រំយុវជន

និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា(២០១២ ) , គោលនយោបាយស្តីពីសៀវភៅសិក្សា និងមគ្គុទេសក៍សម្រាប់ការ

អភិវឌ្ឍសៀវ ភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា(២០១៨) , សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (គម្រោង

កែលម្អការអប់រំនៅមធ្យមសិក្សា) .រាជធានីភ្នំពេញ: ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ( ខែកុម្ភៈ ឆ្នាំ២០១៩) , ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០, គោលដៅ អភិវឌ្ឍន៍ ប្រកបដោយចីរភាពទី ៤ .រាជធានីភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦), ស្ថិតិ និងសូចនាករអប់រំសាធារណៈ (២០១៦- ២០១៧) រាជធានីភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា( ២០១៨) , ស្ថិតិ និងសូចនាករអប់រំសាធារណៈ( ២០១៨-២០១៩) រាជធានីភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកិឡា (២០០៩ ),ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិត ការ រាជធានីភ្នំពេញៈ ក្រសួងអប់រំយុវជន និងកីឡា ។

វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួនណាត បោះពុម្ពគ្រទី៥ ព.ស.២៥១១ គ.ស. ១៩៦ ។

កម្រងសង្ខេបពរិត្តិការណ៍អប់រំពិភពលោក (២០១៦) បណ្ឌិត វ៉ា វ៉ាន់ថន ។

ដកស្រង់ទ្រស្តីការគ្រប់គ្រងសាលារៀន(២០០៨) របស់លោក Robinson , Lioyd , and Rowe ,

ដកស្រង់សម្តីរបស់រដ្ឋបុរសអាហ្វ្រិកខាងត្បូង (២០០៨) លោក Nelson Mandela

បុគ្គលិកលក្ខណៈទាំង៥របស់បុគ្គលិក និងកត្តាដែលអ្នកគ្រប់គ្រងគួរប្រតិបត្តិ គង់ ឆាយឡេង( May 15, 2020) https://www.thehrdaily.com/hr/fivepersonalitiesofemployee/

-

# ឧបសម្ព័ន្ធ

## កម្រងសំណួរស្ទាបស្ទង់សម្រាប់គ្រូ

បាទឈ្មោះ រស់  សារ៉ែង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " ដើម្បីបញ្ចប់ការសិក្សា ។

គោលបំណងនៃការស្រាវជ្រាវនេះ  គឺសិក្សាស្វែងយល់ពី  ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាធៀបនឹងការគ្រប់គ្រប់សាលារៀនផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងយកទិន្នន័យទៅវិភាគ កែលម្អ  លើកម្ពស់  លើចំណុចខ្វះខាតមួយចំនួនដើម្បីធ្វើឲ្យការគ្រប់គ្រង របស់នាយកសាលារៀននៅមធ្យមសិក្សាកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការ  ជួយពង្រឹងវិស័យអប់រំ នៅកម្ពុជា ។ ចំពោះទិន្នន័យដែលប្រមូលបាននេះគឺប្រើប្រាស់សម្រាប់ តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ  ។ ក្នុងន័យនេះ សូមលោកគ្រូ អ្នកគ្រូ ជួយផ្តល់ព័ត៌មានពិត ជាក់ស្តែងតាមការសង្កេត លើការគ្រប់គ្រងរបស់នាយកសាលារៀន ដើម្បីឲ្យខ្ញុំបាទទទួលបានទិន្នន័យពិតប្រាកដយកមកសិក្សាវិភាគ  ព្រមទាំងអាចឆ្លើយតបទៅនឹង  សំណួរស្រាវជ្រាវដែលខ្ញុំបាទបានកំណត់ ។

ខ្ញុំបាទសូមថ្លែងអំគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមផ្តល់ព័ត៌មានពិតរបស់លោកគ្រូ -អ្នកគ្រូ  ។

## ផ្នែកទី១៖ ពត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូគូសសញ្ញា (✓) ក្នុងប្រអប់និមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែង៖

១. ជាគ្រូបង្រៀននៅមធ្យមសិក្សាទុតិភូមិ ដែលកំពុងបង្រៀន ☐ បាទ/ចាស ☐ ទេ

២.បម្រើការងារនៅ៖..........ឃុំ/សង្កាត់.............ស្រុក/ក្រុង/ខណ្ឌ..................ខេត្ត.............

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ១៨-២៣ឆ្នាំ ☐ ២៤-២៩ឆ្នាំ ☐ ៣០-៣៥ឆ្នាំ ☐ លើសពី៣៥ឆ្នាំ

៥. កម្រិតវប្បធម៌ ☐មធ្យមសិក្សាទុតិយភូមិ ☐ បរិញ្ញាបត្រ ☐បរិញ្ញាបត្រជាន់ខ្ពស់

☐ ផ្សេងៗ

៦. បទពិសោធន៍បង្រៀន៖ ☐ ១ ដល់ ៥ឆ្នាំ ☐ ៦ ដល់ ១០ ឆ្នាំ ☐ ១១ ដល់១៥ឆ្នាំ

☐ លើសពី១៥ឆ្នាំ

៧.មុខវិជ្ជាឯកទេសបង្រៀន៖......................................បង្រៀនថ្នាក់ទី៖...........................

៨. ទីលំនៅបច្ចុប្បន្ន៖ ភូមិ.................ឃុំ...................ស្រុក...................ខេត្ត..................

**ផ្នែកទី២ ៖ ការបំពេញការងារនិងការគ្រប់គ្រងដឹកនាំរបស់នាយកសាលារៀន**

ការណែនាំ៖ សំណួរខាងក្រោមគឺ ចង់ឆ្លុះបញ្ចាំងពីសកម្មភាពនៃការអនុវត្តការងារគ្រប់គ្រង របស់នាយកសាលារៀននៅមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង រួមមាន៖១)ការគ្រប់គ្រងការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាល ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤) ការគ្រប់គ្រងធនធានមនុស្ស ។ សូមអានចំណុចនីមួយៗ ឲ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ-អ្នកគ្រូ ។

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របសោះ

២. មិនយល់ស្រប

៣. គ្មានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| ក.ការគ្រប់គ្រងកាបង្រៀន និងរៀន | | ១ | ២ | ៣ | ៤ | ៥ |
| ១ | នាយកសាលា បានជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សាឬគោលដៅសិក្សា | | | | | |
| ២ | នាយកសាលា ធានាអោយប្រាកដថា វត្ថុបំណងថ្នាក់រៀនរបស់គ្រូ ត្រូវគ្នាជាមួយវត្ថុបំណងរបស់សាលា | | | | | |
| ៣ | នាយកសាលា បានកំណត់ពេលវេលាក្នុងការអនុវត្តកម្មវីធីសិក្សាឱ្យបានសមស្របតាមនិយាម | | | | | |
| ៤ | គ្រូបានប្រើបច្ចេកវិទ្យា ក្នុងការបង្រៀន និងរៀន ដើម្បីសម្រេចបានខ្លឹមសារមេរៀន | | | | | |
| ៥ | នាយកសាលា បានជំរុញកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍ ក្នុងស្ថាប័ន | | | | | |
| ៦ | នាយកសាលា បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសំបូរបែបក្នុងការអាន និងសិក្សាស្រាវជ្រាវ | | | | | |
| ៧ | នាយកសាលា បានត្រួតពិនិត្យនិងវាយតំលៃ ( ធ្វើអធិការកិច្ច ) លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ | | | | | |
| ៨ | នាយកសាលា បង្កលទ្ធភាព អោយគ្រូ ពាក់ព័ន្ធក្នុងដំណើរវាយតម្លៃការរៀន និងបង្រៀន | | | | | |
| ៩ | នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឲ្យតាមដានលទ្ធផលសិក្សរបស់កូន | | | | | |
| ខ.ការគ្រប់គ្រងរដ្ឋបាលសាលារៀន | | | | | | |
| ១ | នាយកសាលា ផ្តល់កិច្ចគាំទ្រ សហការ លើដំណើរការអនុវត្តការងារ | | | | | |
| ២ | នាយកសាលា ផ្សារភ្ជាប់គោលដៅសិក្សា ទៅកាន់គ្រូ សិស្ស ឪពុកម្តាយ និងសហគមន៍ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | នាយកសាលា ធានាប្រាកដថា គោលដៅសិក្សា អាចអនុវត្តបានងាយស្រួលចំពោះគ្រូ នៅក្នុងវគ្គបំណងថ្នាក់រៀន | | | | | |
| ៤ | នាយកសាលា បានអនុវត្តការងារឆ្លើយតបទៅតាមគោលនយោបាយជាតិ | | | | | |
| ៥ | នាយកសាលា ធានាបានថារាល់ចំណុចអាទិភាពនៃការបង្រៀនរបស់គ្រូឧទ្ទេសឆ្លើយតបនឹងផែនការ និងចក្ខុវិស័យរបស់វិទ្យាស្ថាន | | | | | |
| ៦ | បានបង្កើតប្រអប់សំបុត្រ តម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្ដឹងពីអ្នកពាក់ព័ន្ធ | | | | | |
| ៧ | មានការផ្សព្វផ្សាយទិន្នន័យ  និងព័ត៌មាននានារបស់សាលា  ដល់សហគមន៍ និង អាជ្ញា ធរមូលដ្ឋាន | | | | | |
| ៨ | លើកទឹកចិត្តដល់សហគមន៍ ចូលរួមក្នុងការគ្រប់គ្រងសាលារៀននិងពិនិត្យតាម ដានការវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា | | | | | |
| **គ.ការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | | | |
| ១ | នាយកសាលា បានរៀបចំផែនការកែលម្អសាលា និងថវិកាសាលារៀន | | | | | |
| ២ | នាយកសាលា បានចំណាយថវិកាសាលារៀន ត្រូវតាមខ្ទង់ចំណាយ | | | | | |
| ៣ | នាយកសាលា បានរៀនចំកម្មវិធី ដើម្បីកៀងគរមូលនិធីទ្រទ្រង់សាលារៀន | | | | | |
| ៤ | សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន | | | | | |
| ៥ | មានតំណាងសហគមន៍ធ្វើជាអនុប្រធាននៃគណៈកម្មការ គ្រប់គ្រងថវិការសាលារៀន | | | | | |
| ៦ | មានការប្រជុំពិភាក្សាជាមួយ គ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ អំពីគណនេយ្យភាព ក្នុងការចំណាយរបស់សាលារៀន | | | | | |
| ៧ | បានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ ជូនគណៈកម្មការគ្រប់គ្រងសាលារៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ប្រជុំផ្សព្វផ្សាយពីលទ្ធផលប្រចាំឆ្នាំស្តីពីតម្លាភាពការប្រើប្រាស់ថវិកាសាលារៀនជូនអ្នកពាក់ព័ន្ធ | | | | | |
| **ឃ.ការគ្រប់គ្រងធនធានមនុស្ស** | | | | | | |
| ១ | នាយកសាលា បានបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈគ្រូ និងបុគ្គលិកស្របតាមលទ្ធផលរំពឹងទុក | | | | | |
| ២ | នាយកសាលា ផ្តល់ឱកាសដល់គ្រូ ដើម្បីបង្កើត និងពិសោធន៍ជាមួយវិធីសាស្ត្រថ្មីៗ ដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស | | | | | |
| ៣ | គ្រូ មានសមត្ថភាពអាចសម្រេចចិត្តលើដំណើរការបង្រៀន និងស្វ័យភាព | | | | | |
| ៤ | នាយកសាលា បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន និងបុគ្គលិក | | | | | |
| ៥ | នាយកសាលា វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ ដោយតម្លាភាព | | | | | |
| ៦ | នាយកសាលា បានផ្តល់ការគាំទ្រទាំងសម្ភារៈ និងបច្ចេកទេសដល់គ្រូបង្រៀនក្នុងការអនុវត្តការងារ | | | | | |
| ៧ | សាលារៀន មានគ្រូបង្រៀនគ្រប់គ្រាន់ ស្របតាមនិយាម និងឯកទេស | | | | | |

**មតិយោបល់បន្ថែមៈ**

...................................................................................................................................................

...........................................................................................................................

...................................................................................................................................................

..........................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

**ផ្នែកទី៣៖បញ្ហាប្រឈមរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ**

ការណែនាំ៖ សូមអាន ឃ្លាខាងក្រោមអោយបានច្បាស់លាស់ ជ្រើសរើសកម្រិតសូចនាករ ដែលឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងតួនាទីជាអ្នកគ្រប់គ្រងសាលារៀនរបស់នាយក ដែលលោកគ្រូ-អ្នកគ្រូយល់ឃើញទៅតាមកម្រិតចង្អុលបង្ហាញ រួចគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗ។ សូមធ្វើការគូសយកក្នុងកម្រិតណាមួយដែលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ន នៃបញ្ហាប្រឈមក្នុងតួនាទីជាអ្នកគ្រប់គ្រងសាលារៀនរបស់នាយក នៅខេត្តស្វាយរៀង។

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របសោះ

២. មិនយល់ស្រប

៣. គ្មានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ការបង្រៀន និងរៀនរបស់គ្រូមិនទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ | | | | | |
| ២ | ការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូមិនទាន់បានគ្រប់មុខវិជ្ជា | | | | | |
| ៣ | មានការបែងចែក ក្រុមការងារ និងរើសអើង របស់បុគ្គលិកក្នុងសាលារៀន | | | | | |
| ៤ | គ្រូបង្រៀនអវត្តមានច្រើនពេលមានការប្រជុំបច្ចេកទេស និងការប្រជុំនានា | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | គ្រូបង្រៀនខ្វះការសហការក្នុងការអនុវត្តការងារប្រចាំថ្ងៃ | | | | | |
| ៦ | សាលារៀនខ្វះមន្ត្រីជំនាញក្នុងការរៀបចំផែនការប្រចាំឆ្នាំ | | | | | |
| ៧ | សិស្សមករៀន មិនបានទៀងទាត់ និងមានសិស្សរៀនយឺតច្រើន | | | | | |
| 8 | ចំណេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត | | | | | |
| 9 | ការចូលរួមរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមានកម្រិតទាបនៅឡើយ | | | | | |
| 10 | ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ | | | | | |
| 11 | មានទំនាស់ផលប្រយោជន៍ការងាររបស់គ្រូ កើតមានឡើងនៅក្នុងអង្គភាព | | | | | |

**មតិយោបល់បន្ថែម៖**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

**សូមអរគុណ**!

## កម្រងសំណួរស្រាវជ្រាវសម្រាប់គណៈគ្រប់គ្រងសាលា

ខ្ញុំបាទឈ្មោះ រស់ សារ៉ែង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាត់អប់រំ កំពុងសរសេរនិក្ខេបបទស្តីពី " **ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង** " ដើម្បីបញ្ចប់កា រសិក្សា ។

គោលបំណងនៃការស្រាវជ្រាវនេះ គឺសិក្សាស្វែងយល់ពី ការអនុវត្តការគ្រប់គ្រងរបស់នាយកសាលាមធ្យម សិក្សាធៀបនឹងការគ្រប់គ្រប់សាលារៀនផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងយកទិន្នន័យទៅវិភាគ ដើម្បីឆ្លុះបញ្ចាំង លើប្រធានបទដែលកំពុងសិក្សា។ ចំពោះទិន្នន័យដែលប្រមូលបាននេះគឺប្រើប្រាស់សម្រាប់ តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោក-លោកស្រី ជួយផ្តល់ព័ត៌មានពិត ដាក់ស្តែងតាមសកម្មភាពកន្លងមក លើការគ្រប់គ្រងរបស់នាយកសាលារៀន ដើម្បីឲ្យខ្ញុំបាទទទួលបានទិន្នន័យពិតប្រាកដ យកមកសិក្សាវិភាគព្រមទាំងអាចឆ្លើយតបទៅ នឹងសំណួរស្រាវជ្រាវដែលខ្ញុំបាទបានកំណត់។

ខ្ញុំបាទសូមថ្លែងអំគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមផ្តល់ព័ត៌មានពិតរបស់លោក-លោកស្រី ដែលបានជួយចូល រួមសហការ និងផ្តលព័ត៌មានពិតដាក់ស្តែង ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោក-លោកស្រី មេត្តាជួយគូសសសញ្ញា (✓) ក្នុងប្រអប់និមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែង៖

១.បម្រើការងារនៅ៖...................ឃុំ/សង្កាត់................ស្រុក/ក្រុង/ខណ្ឌ...................ខេត្ត....

២. ភេទ ☐ ប្រស ☐ ស្រី

៣. អាយុ ☐ ២៥-៣០ឆ្នាំ ☐ ៣១-៣៥ឆ្នាំ ☐ ៣៦-៤០ឆ្នាំ ☐ លើសពី៤០ឆ្នាំ

៤. កម្រិតវប្បធម៌ ☐ មធ្យមសិក្សាទុតិយភូមិ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ

៥. បទពិសោធន៍ជាអ្នកគ្រប់គ្រង៖ ☐ ១ដល់៥ឆ្នាំ ☐ ៦ដល់១០ឆ្នាំ ☐ ១១ដល់១៥ឆ្នាំ

☐ លើសពី១៥ឆ្នាំ

៦. មានតួនាទីជា: ☐ នាយក/នាយិកា ☐ នាយករង/នាយិការង

៧. ទីលំនៅបច្ចុប្បន្ន៖ ភូមិ................ឃុំ....................ស្រុក...............ខេត្ត......................

## ផ្នែកទី២ ៖ ការបំពេញការងារនិងការគ្រប់គ្រងដឹកនាំរបស់នាយកសាលារៀន

ការណែនាំ៖ សំណួរខាងក្រោមគឺ ចង់ឆ្លុះបញ្ចាំងពីសកម្មភាពនៃការអនុវត្តការងារគ្រប់គ្រង របស់នាយកសាលារៀននៅមធ្យមសិក្សាទុតិយភូមិ ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង រួមមាន៖១)ការគ្រប់គ្រងការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាល ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤) ការគ្រប់គ្រងធនធានមនុស្ស ។ សូមលោកនាយក / នាយិកា លោកនាយករង/ នាយិការង មេត្តាជួយអានចំណុចនីមួយៗ ឲ្យបានច្បាស់លាស់បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោក-លោកស្រី។

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របសោះ

២. មិនយល់ស្រប

៣. គ្មានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| **ល.រ** | **បរិយាយ** | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| **ក.ការគ្រប់គ្រងកាបង្រៀន និងរៀន** | | ១ | ២ | ៣ | ៤ | ៥ |
| ១ | បានរៀបចំជួបប្រជុំជាមួយគ្រូដើម្បីកំណត់កម្មវិធីសិក្សា ឬគោលដៅសិក្សា | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បានជានាអោយប្រាកដថា វត្ថុបំណងថ្នាក់រៀនរបស់គ្រូ ត្រូវគ្នាជាមួយវត្ថុបំណងរបស់សាលា | | | | | |
| ៣ | បានកំណត់ពេលវេលាក្នុងការអនុវត្តកម្មវិធីសិក្សារបស់គ្រូឱ្យបានសមស្របតាមនិយាម | | | | | |
| ៤ | បានជម្រុញគ្រូឲ្យប្រើបច្ចេកវិទ្យា ក្នុងការបង្រៀន និងរៀន ដើម្បីសម្រេចបានខ្លឹមសារមេរៀន | | | | | |
| ៥ | ជួយជម្រុញកិច្ចការស្រាវជ្រាវ និងនវានុវត្តន៍ ក្នុងស្ថាប័នដល់គ្រូបង្រៀន | | | | | |
| ៦ | បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសំបូរបែបក្នុងការអាន និងសិក្សាស្រាវជ្រាវ របស់គ្រូ និងសិស្ស | | | | | |
| ៧ | បានត្រួតពិនិត្យនិងវាយតំលៃ ( ធ្វើអធិការកិច្ច ) លើការបង្រៀនរបស់គ្រូបង្រៀនជាប្រចាំ | | | | | |
| ៨ | បង្កលទ្ធភាពឲ្យគ្រូ ពាក់ព័ន្ធក្នុងដំណើរវាយតម្លៃការរៀន និងបង្រៀន | | | | | |
| ៩ | តែងតែលើកទឹកចិត្តមាតាបិតាសិស្សឲ្យតាមដានលទ្ធផលសិក្សរបស់កូន | | | | | |
| **ខ.ការគ្រប់គ្រងរដ្ឋបាលសាលារៀន** | | | | | | |
| ១ | ជួយ ផ្តល់កិច្ចគាំទ្រ សហការ លើដំណើរការអនុវត្តការងាររបស់គ្រូបង្រៀន | | | | | |
| ២ | បានផ្សារភ្ជាប់គោលដៅសិក្សា ទៅកាន់គ្រូ សិស្ស ឪពុកម្តាយ និងសហគមន៍ | | | | | |
| ៣ | ចូលរួមជានាប្រាកដថា គោលដៅសិក្សា អាចអនុវត្តបានងាយស្រួលចំពោះគ្រូ នៅក្នុងវត្ថុបំណងថ្នាក់រៀន | | | | | |
| ៤ | ខិតខំ ព្យាយាមអនុវត្តការងារឲ្យសម្រេច និងឆ្លើយតបទៅតាមគោលនយោបាយជាតិ | | | | | |
| ៥ | ចូលរួមជានាបានថារាល់ចំណុចអាទិភាពនៃការបង្រៀនរបស់គ្រូឧទ្ទេសឆ្លើយតបនឹងផែនការ និងចក្ខុវិស័យរបស់វិទ្យាស្ថាន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | បានបង្កើតប្រអប់សំបុត្រ តម្លាភាពដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ ទាំងក្នុង និងក្រៅអង្គភាព | | | | | |
| ៧ | បានការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មាននានារបស់សាលា ដល់សហគមន៍ និងអាជ្ញា ធរមូលដ្ឋាន | | | | | |
| ៨ | បានលើកទឹកចិត្តដល់សហគមន៍ ចូលរួមក្នុងការគ្រប់គ្រងសាលារៀននិងពិនិត្យតាមដាន ការវាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលា | | | | | |
| **គ.ការគ្រប់គ្រងហិរញ្ញវត្ថុ** | | | | | | |
| ១ | បានរៀបចំផែនការកែលម្អសាលា និងថវិកាសាលារៀន | | | | | |
| ២ | បានចំណាយថវិកាសាលារៀន ត្រូវតាមខ្ទង់ចំណាយប្រចាំឆ្នាំរបស់សាលារៀន | | | | | |
| ៣ | បានរៀបចំកម្មវិធី ដើម្បីកៀងគរមូលនិធីទ្រទ្រង់ដល់សាលារៀន | | | | | |
| ៤ | សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន | | | | | |
| ៥ | មានតំណាងសហគមន៍ធ្វើជាអនុប្រធាននៃគណៈកម្មការ គ្រប់គ្រងថវិការសាលារៀន | | | | | |
| ៦ | មានការប្រជុំពិភាក្សាជាញឹកញាប់ជាមួយ គ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ អំពី គណនេយ្យភាព ក្នុងការចំណាយរបស់សាលារៀន | | | | | |
| ៧ | បានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ ជូនគណៈកម្មការគ្រប់គ្រងសាលារៀន | | | | | |
| ៨ | ប្រជុំផ្សព្វផ្សាយពីលទ្ធផលប្រចាំឆ្នាំស្តីពីតម្លាភាពការប្រើប្រាស់ថវិកាសាលារៀនជូនអ្នកពាក់ព័ន្ធ | | | | | |
| **ឃ.ការគ្រប់គ្រងធនធានមនុស្ស** | | | | | | |
| ១ | បានបណ្តុះបណ្តាលសមត្ថភាពវិជ្ជាជីវៈគ្រូ និងបុគ្គលិកស្របតាមលទ្ធផលរំពឹងទុក | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បានផ្តល់ឱកាសដល់គ្រូ ដើម្បីបង្កើត និងពិសោធន៍ជាមួយវិធីសាស្ត្រថ្មីៗដើម្បីលើកកម្ពស់ការសិក្សារបស់សិស្ស | | | | | |
| ៣ | ផ្តល់ឱកាសឲ្យគ្រូដែលមានសមត្ថភាពអាចសម្រេចចិត្តលើដំណើរការបង្រៀន និងស្វ័យភាព | | | | | |
| ៤ | បានអនុវត្តការផ្តល់ប្រព័ន្ធលាភការដល់គ្រូបង្រៀន និងបុគ្គលិកដែលមានស្នាដៃ | | | | | |
| ៥ | ធ្វើការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ ដោយតម្លាភាព | | | | | |
| ៦ | ជួយផ្តល់ការគាំទ្រទាំងសម្ភារៈ និងបច្ចេកទេសដល់គ្រូបង្រៀនក្នុងការ អនុវត្តការងារ | | | | | |
| ៧ | សាលារៀន មានគ្រូបង្រៀនគ្រប់គ្រាន់ ស្របតាមនិយាម និងឯកទេស | | | | | |

**មតិយោបល់បន្ថែមៈ**

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

**ផ្នែកទី៣៖បញ្ហាប្រឈមរបស់នាយកសាលាមធ្យម សិក្សាទុតិយភូមិនៅក្នុងស្រុកស្វាយជ្រំ**

ការណែនាំ៖ សូមលោកនាយក/នាយិកា នាយករង/នាយិការងមេត្តាអាន ឃ្លាខាងក្រោមអោយបានច្បាស់លាស់ និងធ្វើការជ្រើសរើសកម្រិតសូចនាករ ដែលឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងតួនាទីជាអ្នកគ្រប់គ្រងសាលារៀនរបស់លោក/លោកស្រី តាមកម្រិតចង្អុលបង្ហាញ បន្ទាប់មេត្តាជួយគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗ ។ សូមសូម

មេត្តាគូសយកក្នុងកម្រិតណាមួយដែលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ន នៃបញ្ហាប្រឈមក្នុងតួនាទីជាអ្នកគ្រប់គ្រងសាលារៀនរបស់លោក-លោកស្រី នៅខេត្តស្វាយរៀង។

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របសោះ

២. មិនយល់ស្រប

៣. គ្មានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | **កម្រិតចង្អុលបង្ហាញ** | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | ការបង្រៀន និងរៀនរបស់គ្រូមិនទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ | | | | | |
| ២ | ការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូមិនទាន់បានគ្រប់មុខវិជ្ជា | | | | | |
| ៣ | មានការបែងចែក ក្រុមការងារ និងរើសអើង របស់បុគ្គលិកក្នុងសាលារៀន | | | | | |
| ៤ | គ្រូបង្រៀនអវត្តមានច្រើនពេលមានការប្រជុំបច្ចេកទេស និងការប្រជុំនានា | | | | | |
| ៥ | គ្រូបង្រៀនខ្វះការសហការក្នុងការអនុវត្តការងារប្រចាំថ្ងៃ | | | | | |
| ៦ | សាលារៀនខ្វះមន្ត្រីជំនាញក្នុងការរៀបចំផែនការប្រចាំឆ្នាំ | | | | | |
| ៧ | សិស្សមករៀន មិនបានទៀងទាត់ និងមានសិស្សរៀនយឺតច្រើន | | | | | |
| 8 | ចំណេះដឹងរបស់គ្រូបង្រៀន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត | | | | | |
| 9 | ការចូលរួមរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រង និងដឹកនាំសាលារៀននៅមានកម្រិតទាបនៅឡើយ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 10 | ចំណូលថវិកាប្រចាំឆ្នាំរបស់សាលាបានកម្រិតទាបប្រៀបធៀបជាមួយការចំណាយ | | | | | |
| 11 | មានទំនាស់ផលប្រយោជន៍ការងាររបស់គ្រូ កើតមានឡើងនៅក្នុងអង្គភាព | | | | | |

**មតិយោបល់បន្ថែម៖**

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

**សូមអរគុណ**!

## ព័ត៌មានទូទៅរបស់គ្រូបង្រៀន នៅមធ្យមសិក្សាទុតិយភូមិ

| ល.រ | បរិយាយ | | សរុបរួម | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចំនួន | ភាគរយ | |
| ១ | ភេទ | ប្រុស | 38 | 69.09% | |

| | | | | | |
|---|---|---|---|---|---|
| | | ស្រី | 17 | 30.91% | |
| | | សរុប | 55 | 100% | |
| ២ | អាយុ | ១៨ ទៅ ២៣ | 02 | 3.63% | |
| | | ២៤ ទៅ ២៩ | 27 | 49.09% | |
| | | ៣០ ទៅ៣៥ | 21 | 38.18% | |
| | | លើសពី ៣៥ | 05 | 9.10% | |
| | | សរុប | 55 | 100% | |
| ៣ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 04 | 7.27% | |
| | | បរិញ្ញាបត្រ | 45 | 81.81% | |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 06 | 10.92% | |
| | | ផ្សេងៗ | 00 | 0.00% | |
| | | សរុប | 55 | 100% | |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ឆ្នាំ | 26 | 47.27% | |
| | | ៦ ដល់ ១០ឆ្នាំ | 16 | 29.09% | |
| | | ១១ ដល់ ១៥ឆ្នាំ | 09 | 16.36% | |
| | | លើសពី ១៥ ឆ្នាំ | 04 | 7.28 | |
| | | សរុប | 55 | 100% | |

## ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង នៅមធ្យសិក្សាទុតយភូមិ

| ល.រ | បរិយាយ | | សរុបរួម | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចំនួន | ភាគរយ | |
| ១ | ភេទ | ប្រុស | 10 | 100% | |

| | | | | | |
|---|---|---|---|---|---|
| | | ស្រី | 00 | 0.00% | |
| | | សរុប | 10 | 100% | |
| ២ | អាយុ | ១៨ ទៅ ២៣ | 00 | 0.00% | |
| | | ២៤ ទៅ ២៩ | 00 | 0.00% | |
| | | ៣០ ទៅ៣៥ | 00 | 0.00% | |
| | | លើសពី ៣៥ | 10 | 100% | |
| | | សរុប | 10 | 100% | |
| ៣ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 02 | 20% | |
| | | បរិញ្ញាបត្រ | 07 | 70% | |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 01 | 10% | |
| | | ផ្សេងៗ | 00 | 0.00% | |
| | | សរុប | 10 | 100% | |
| ៤ | បទពិសោធន៍ក្នុងការងារគ្រប់គ្រង | ១ ដល់ ៥ឆ្នាំ | 01 | 10% | |
| | | ៦ ដល់ ១០ឆ្នាំ | 05 | 50% | |
| | | ១១ ដល់ ១៥ឆ្នាំ | 04 | 40% | |
| | | លើសពី ១៥ ឆ្នាំ | 00 | 0.00% | |
| | | សរុប | 10 | 100% | |




# សូមជូនដំណឹង

វិទ្យាស្ថានជាតិអប់រំសូមជូនដំណឹងដល់និស្សិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ជ្រាបថា៖

- ផែនការបណ្តុះបណ្តាលរបស់វិទ្យាស្ថានបានកំណត់យកពីថ្ងៃទី១៣ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ ជាថ្ងៃការពារបញ្ចប់និក្ខេបបទ ។

ផ្សេងៗ

- និស្សិតម្នាក់ៗតម្រូវឱ្យធ្វើរបាយការណ៍ប្រចាំខែចាប់ពីខែកុម្ភៈ ឆ្នាំ២០២១ស្តីពីវឌ្ឍនភាពនៃការសរសេរនិក្ខេបបទ។
- ដាក់ជូននិក្ខេបបទតាមដំណាក់កាលដូចខាងក្រោម៖
  - សេចក្តីផ្តើម (ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១)
  - រំលឹកទ្រឹស្តី (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១)
  - វិធីសាស្ត្រស្រាវជ្រាវ (ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១)
  - ការប្រមូលទិន្នន័យ វាយបញ្ចូល សំអាត (ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១)
  - វិភាគស៊ីសម្រៅលើលទ្ធផលរបកគំហើញ(ថ្ងៃទី០១ សីហា ២០២១)
  - សេចក្តីសន្និដ្ឋាន (ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០២១)
- ថ្ងៃទី១៦-១៧ ខែតុលា ឆ្នាំ២០២១ ការពារសាកល្បង
- រាល់ការយឺតយ៉ាវរបស់និស្សិត ការិយាល័យបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សានៃដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការមិនទទួលខុសត្រូវ ឡើយ។ បើមានចម្ងល់សូមទំនាក់ទំនងមកដេប៉ាតឺម៉ង់។ អរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :........✓.........វជអ.

## កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ កាលបរិច្ឆេទទទួលនិក្ខេបបទ និងការការពារបញ្ចប់វគ្គសិក្សា

| ល.រ | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | ការទទួលនិក្ខេបបទ | ចាប់ពីថ្ងៃទី១៨-៣០ ខែតុលា ឆ្នាំ២០២១ (ពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ វេលាម៉ោង៨:០០ ដល់១៧:00នាទី) | ៣០ តុលា ២០២១ (ម៉ោង១៧:00នាទី) |
| ២ | បទបង្ហាញសាកល្បងការពារនិក្ខេបបទ | ចាប់ពីថ្ងៃទី២៥-៣០ ខែតុលា ឆ្នាំ២០២១ (ពីថ្ងៃចន្ទដល់ថ្ងៃសៅរ៍ វេលាម៉ោង៨:០០ ដល់១៧:00នាទី) | |
| ៣ | ការការពារនិក្ខេបបទបញ្ចប់វគ្គសិក្សា | ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ (ពីម៉ោង៧:៣០ ដល់១៧:00នាទី) | |

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវ សូមទាក់ទងផ្នែកបណ្តុះបណ្តាលក្រោយឧត្តមសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំរបស់វិទ្យាស្ថានជាតិអប់រំ។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ២៤០៩ **អយក.** វិនវ

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :.....✓.........ខជអ.

# លិខិតអញ្ជើញ

| | | |
|---|---|---|
| សូមអញ្ជើញ | ៖ | និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ និស្សិតថ្នាក់ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៤ |
| ដើម្បីចូលរួម | ៖ | ការធ្វើបទបង្ហាញពីរបៀបបង្កើតទម្រង់វាយបញ្ចូលទិន្នន័យ បង្កើតតារាង និងវិភាគតាមកម្មវិធី SPSS ដែលបង្រៀន ដោយលោក **ថៃ ហោខ** នាយករងវិទ្យាស្ថានជាតិអប់រំ។ និស្សិតតម្រូវឱ្យមានកុំព្យូទ័រកម្មវិធី SPSS Version ចុងក្រោយ សម្របសម្រួលដោយ លោក សៀង វាសនា លោក ចាប រតនា លោក លឹម វ៉ាន់។ |
| កាលបរិច្ឆេទ | ៖ | ថ្ងៃអាទិត្យ ៦រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១។ |
| ពេលវេលា | ៖ | ម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង១១:៣០ថ្ងៃត្រង់។ |
| ទីកន្លែង | ៖ | តាមរយៈប្រព័ន្ធអនឡាញ (Google Meeting) |

ថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ៖ www.nie.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១៤៣៥ អយក.[illegible]

## លិខិតឧទ្ទេសនាម

យោង ៖ - លិខិតលេខ៣៣៦២ អយក.វជអ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩។
- បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា២០១៩-២០២១ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គ្រូដឹកនាំបណ្តាល | គ្រូដឹកនាំរង | ប្រធានបទស្រាវជ្រាវ | និស្សិត |
|---|---|---|---|---|
| ១ | លោកបណ្ឌិត ឈាង សង្វាត | លោក សៀង វាសនា | គំរូនៃភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀនរបស់នាយកមធ្យមសិក្សាទុតិយភូមិក្រោមគម្រោងកែលម្អការអប់រំមធ្យមសិក្សាក្នុងខេត្តបន្ទាយមានជ័យ | លោក ចាន់ សុភាព |
| ២ | ឯកឧត្តមបណ្ឌិត ឌី ខាំប៉ូលី | លោក សៀង វាសនា | ពង្រឹងការបង្រៀនរបស់គ្រូ តាមរយៈការអភិវឌ្ឍវិធីសាស្ត្របង្រៀន មុខវិជ្ជាជីវវិទ្យា ករណីសិក្សាស្រុករំដួលខេត្តស្វាយរៀង | លោក ជឹម សំហៃ |
| ៣ | លោក ឡុច ចាន់ថន | លោកបណ្ឌិត នី វដ្ឋា | ទស្សនៈនាយកសាលា និងប្រធានក្រុមបច្ចេកទេសស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ «ករណីសិក្សាសាលាវិទ្យាល័យដែលបណ្តុះបណ្តាលដោយវិទ្យាស្ថានជាតិអប់រំនៅខេត្តកណ្តាល» | លោក ធឿង យន |
| ៤ | លោកបណ្ឌិត នូវ វីរ៉ា | លោក ចាន់ ធឿន | ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង | លោក ផាន់ សំអាត |


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | | |
|---|---|---|---|---|
| ៥ | លោក<br>ប៉ូ បុន្នន | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | សមត្ថភាពនាយកសាលាបឋមសិក្សាក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ករណីសិក្សាក្នុងរាជធានីភ្នំពេញ | លោក មូល ម៉ង់ |
| ៦ | លោកស្រី<br>ប៊ុន សុផានី | លោកបណ្ឌិត<br>ឈាង សង្វាត | ការអនុវត្តការគ្រប់គ្រង របស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | លោក រស់ សារ៉េង |
| ៧ | លោក<br>លន លីណា | លោកបណ្ឌិត<br>នី វង្ឃា | ស្ថានភាពការគ្រប់គ្រងបរិស្ថានសាលារៀន នៅមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តព្រៃវែង | លោក រឹម សារាត់ |
| ៨ | លោកបណ្ឌិត<br>កាង ស៊ីងឆាង | លោក<br>ម៉ែន សុខសុន្នី | ការយល់ឃើញរបស់គ្រូទៅលើភាពជាអ្នកដឹកនាំបង្ហាត់បង្រៀននៅសាលា WESTERN ក្នុងរាជធានីភ្នំពេញ | ល.ស ស៊ា គឹមលី |
| ៩ | លោកបណ្ឌិត<br>ឈូក ច័ន្ទឆាយា | លោក<br>ចាប រតនា | ការដឹកនាំគ្រប់គ្រងថ្នាក់រៀនរបស់គ្រូឧទ្ទេសមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល | ល.ស សុខ ផល្លី |
| ១០ | លោក<br>ឱ បុណ្ណា | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀនៈករណីសិក្សាខេត្តឧត្តរមានជ័យ | លោក អ៊ឹម សានី |
| ១១ | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | លោក<br>លន លីណា | ទស្សនៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិចំពោះការអនុវត្តការសិក្សាពីចម្ងាយនៅរាជធានីភ្នំពេញ | លោក សំ ហន |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួលៈ**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

" ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន " ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ រៀងរ

លេខ:......៩១..........អយក.ចល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអ.គ......១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ស្វាយរៀង,ថ្ងៃទី....២២...ខែមិថុនា ឆ្នាំ២០២១

**ជ.ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត**

**អនុប្រធាន**

**សុខ_ស៊ីដេត**